P01 - 14

ថ្វេលក៏នៅតំបន់វាលឆ្ពោះទៅស្គាល់

# សត្វស្លាបនៃប្រទេសកម្ពុជា





រៀបរៀងដោយលោក តាន់ សេដ្ឋា & លោក កូលីន ភូល

មគ្គុទ្ទេសក៍នៅតំបន់វាលឆ្ពោះទៅស្គាល់

# សត្វស្លាប

## នៃ

# ប្រទេសកម្ពុជា

ដោយ លោក តាន់ សេដ្ឋា និង លោក កូលីនភូល

បោះពុម្ពដោយកម្មវិធីរបស់អង្គការសមាគមអភិរក្សសត្វព្រៃនៅកម្ពុជា

ក្រោមកិច្ចសហប្រតិបត្តិការជាមួយនាយកដ្ឋានរុក្ខា-ប្រមាញ់

នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

WILDLIFE CONSERVATION SOCIETY

ក្រោមជំនួយឧបត្ថម្ភច្រើនជាងគេពីស្ថានទូតអង់គ្លេសប្រចាំព្រះរាជាណាចក្រកម្ពុជា

ភ្នំពេញ

BRITISH AID

ពាន់ សេដ្ឋា និង កូលីន ភូល (២០០៣)

មគ្គុទ្ទេសក៏នៅតំបន់វាលភ្លោះទៅស្គាល់

សត្វស្លាបនៃប្រទេសកម្ពុជា

កម្មវិធីរបស់អង្គការសមាគមអភិរក្សសត្វព្រៃនៅកម្ពុជា ភ្នំពេញ

រូបភាពដោយ *Craig Robson* (២០០០) *A Field guide to the Birds of South-east Asia* ។ *New Holland Publishers (UK) Ltd* ។

ក្រោមការអនុញ្ញាតអោយប្រើប្រាស់រូបភាពពីអ្នកនិពន្ធ និង អ្នកបោះពុម្ពផ្សាយ ។

រចនា និង បញ្ចូលរូបភាពដោយ កញ្ញា សុត សុភ័ណ្ឌ

សហការកែសំរួលដោយ លោក លិ វុឌ្ឍី លោក កែវ អូម៉ាលីស្ស និង លោក សេង គីមហ៊ាត់

បោះពុម្ពដោយរោងពុម្ព *JSRC* ភ្នំពេញ

ការផ្សាយរបស់

អង្គការសមាគមអភិរក្សសត្វព្រៃ

អាស័យដ្ឋាន ផ្ទះលេខ ២១ ផ្លូវលេខ ២១ សង្កាត់ទន្លេបាសាក់

ប្រអប់សំបុត្រលេខ ១៦២០ ភ្នំពេញ

ទូរស័ព្ទ ទូរសា ០២៣ ២១៧ ២០៥

*Email: cambodia@wcs.org*

*www.wcs.org*

*A Field Guide to the*

# BIRDS
## *of*
# CAMBODIA

*Tan Setha and Colin Poole*

*Published by Wildlife Conservation Society Cambodia Program in collaboration with the Department of Forestry and Wildlife of the Ministry of Agriculture, Forestry and Fisheries.*

WILDLIFE CONSERVATION SOCIETY

*Primary Funding from the British Embassy, Phnom Penh.*

BRITISH AID

*Tan Setha and Poole, C. M. (2003)*
*A Field Guide to the Birds of Cambodia.*
*Wildlife Conservation Society Phnom Penh (WCS)*
*Cambodia Program.*

*Pictures © Craig Robson (2000) A Field Guide to the Birds of South-east Asia. New Holland Publishers (UK) Ltd. Used with kind permission of the author and publishers.*

*Designed by: Soth Sophorn*

*Edited and proof read by: Lic Vuthy, Keo Omaliss and Seng Kim Hout*

*Printed by JSRC Printing House, Phnom Penh*

*Copies available from:*
*Wildlife Conservation Society (WCS) Cambodia Program,*
*21 Street 21, Tonle Bassac,*
*PO Box 1620,*
*Phnom Penh*

*Tel./fax 023 217205*
*Email: cambodia@wcs.org*
*www.wcs.org*
*2003*

# មាតិកា


មាតិកា..............................................................ទំព័រ

សេចក្តីថ្លែងអំណរគុណ.....................................................១

សេចក្តីផ្តើម :..............................................................៣

វិធីប្រើប្រាស់សៀវភៅ :.....................................................៤

ផ្នែកផ្សេងៗនៃសត្វស្លាប :.................................................៥

ការអភិរក្សសត្វស្លាបនៅក្នុងប្រទេសកម្ពុជា :.............................៦

តំបន់សត្វស្លាបសំខាន់ៗមួយចំនួននៅក្នុងប្រទេសកម្ពុជា ......................៧

ការកត់ត្រាសត្វស្លាប : ....................................................១០

ប្រភេទសត្វស្លាបរស់នៅទីក្រុងនិងជនបទ :..................................១២
ប្រភេទសត្វស្លាបរស់នៅតំបន់ដីសើម :......................................៤០

ប្រភេទសត្វស្លាបរស់នៅតំបន់ព្រៃ :..........................................៩៤

បញ្ជីឈ្មោះសត្វស្លាបប្រទេសកម្ពុជា :........................................១៤៩
- ស្ថានភាពគំរាមកំហែង :
- លេខកូដសំគាល់ស្ថានភាពផ្លាស់ប្តូររបស់សត្វស្លាប :......................១៥០
- សន្ទានុក្រម :
- បណ្ណាល័យសាស្ត្រ :

# សេចក្តីថ្លែងអំណរគុណ

ដំបូងយើងខ្ញុំសូមថ្លែងអំណរគុណដល់ ឯកឧត្តម **ចាន់ សារុន** រដ្ឋមន្ត្រីក្រសួង កសិកម្មរុក្ខា-ប្រមាញ់ និងនេសាទ ដែលជានិច្ចកាលឯកឧត្តមតែងតែលើកស្ទួយគាំទ្រ និង លើកទឹកចិត្តដល់អ្នកសិក្សាស្រាវជ្រាវ ក៏ដូចជាបញ្ញវន្តនិស្សិតទាំងឡាយដែលមានចិត្តអំណត់តស៊ូក្នុងការងារដើម្បីជួយជាប្រយោជន៍ដល់ប្រជាជនខ្មែរក៏ដូចជាប្រយោជន៍ដើម្បីប្រទេសជាតិ យើងបានរីកចំរើនហើយខ្ញុំសង្ឃឹមថាសៀវភៅនេះពិតជាធ្វើអោយឯកឧត្តមពេញចិត្តនូវស្នាដៃដែលជាលទ្ធផលរបស់មន្ត្រីនាយកដ្ឋានរុក្ខា-ប្រមាញ់កក្នុងកិច្ចសហការជាមួយអង្គការ *WCS* ប្រចាំប្រទេសកម្ពុជា។

យើងខ្ញុំសូមថ្លែងអំណរគុណជាពិសេសដល់ លោក **ទី សុគន្ធ** ប្រធាននាយក ដ្ឋានរុក្ខា-ប្រមាញ់ ដែលបានបញ្ជូនរូបខ្ញុំបាទមករួម សហការជាមួយអង្គការ *WCS* លើការសិក្សាស្រាវជ្រាវសត្វព្រៃ ពិសេសសត្វស្លាបនៅកម្ពុជា។

សូមរំលឹកដល់មនសិកាលោក **ឡៅ គឹមសុខ** អតីតប្រធានការិយាល័យការពារសត្វព្រៃដែលបានផ្តួចផ្តើមរៀបចំកម្មវិធីការពារសត្វព្រៃកម្ពុជាដំបូងបង្អស់ក្រោយថ្ងៃ៧មករា ១៩៧៩ និងជាមនុស្សទីមួយដែលបានចូលរួមក្នុងការស្ថាបនាសួនសត្វភ្នំតាម៉ៅ។

យើងខ្ញុំសូមថ្លែងអំណរគុណផងដែរដល់លោក **អ៊ុក ស៊ីផាន** អនុប្រធាននាយកដ្ឋានរុក្ខា-ប្រមាញ់ ទទួលបន្ទុកវិទ្យាស្ថានស្រាវជ្រាវព្រៃឈើ និងសត្វព្រៃ។ ព្រមទាំងលោក **ខៀវ សារុន** ប្រធានវិទ្យាស្ថានសិក្សាស្រាវជ្រាវព្រៃឈើ និងសត្វព្រៃ និងលោក **ឈោក ម៉ែន គិមឿន** ប្រធានការិយាល័យការពារសត្វព្រៃ ដែលបានគាំទ្រដល់សកម្ម ភាពការងាររបស់ខ្ញុំបាទដោយសុទ្ធចិត្ត។ សេចក្តីថ្លែងអំណរគុណពិសេសដល់លោក **លិ ខុន្នី** ដែលបានតាមដាន-និង ជួយជ្រោមជ្រែងរាល់សកម្មភាពការងារដែលមានប្រយោជន៍ទាំងឡាយរបស់ខ្ញុំបាទក្នុងន័យស្ថាបនាអោយបានរីកចំរើន។

សូមថ្លែងអំណរគុណយ៉ាងជ្រៅលជ្រៅដល់ **កញ្ញា សុត សុភ័ណ្ឌ** ដែលបានរៀបចំរចនាកែលំអរ និងបញ្ចូលរូបភាពក្នុងសៀវភៅនេះអោយកាន់តែមានភាពរស់រវើកសំរាប់ជាចំណីអារម្មណ៍របស់មិត្តអ្នកអាន។

ក្នុងនាមជាអ្នករៀបរៀងសៀវភៅ **"សត្វស្លាបនៃប្រទេសកម្ពុជា"** ជាលើកទី២នេះយើងខ្ញុំសូមថ្លែងអំណរគុណដល់ក្រុមអ្នករៀបរៀងសៀវភៅសត្វស្លាបលើកទីមួយរួមមាន : លោក **ស៊ុន ហ៊ាន** លោក **កែវ អូម៉ាលីស្ស** លោក **សេង គីមហ៊ត់** លោក **ហេង មុនីនាថ** និង លោក Colin Poole ដែលបានពុះពាររាល់ការងារលំបាកទាំងឡាយ ពីដំបូងបើមិនដូច្នេះទេសៀវភៅសត្វ ស្លាបលើកទី២នេះក៏មិនអាចកើតមានឡើងបានដែរ។

សូមថ្លែងអំណរគុណដល់មិត្តរួមការងារទាំងអស់ដែលពុំបានរាប់ឈ្មោះក្នុងការរួមគ្នាសិក្សាស្រាវជ្រាវរាល់ប្រភេទសត្វស្លាបជាច្រើនដែលមានវត្តមាននៅតំបន់ជាច្រើនក្នុងព្រះរាជាណាចក្រកម្ពុជា។

ចុងក្រោយសូមថ្លែងអំណរគុណដល់មិត្តរួមការងារអន្តរជាតិរួមមានលោក **Pete Davidson** និង លោក **Frédéric Goes** ចំពោះការផ្តល់នូវទស្សនៈទានល្អៗជាច្រើនលើរាល់ប្រភេទសត្វស្លាបទាំងឡាយដើម្បី អោយសៀវភៅនេះកាន់តែមានភាពសុក្រឹត្យ ។

ជាចុងក្រោយសូមថ្លែងអំណរដល់ក្រុមសប្បុរសជនអន្តរជាតិរួមមានលោក **Craig Robson** និង លោក **Jo Hemmings** ដែលបានផ្តល់ការអនុញ្ញាតអោយប្រើប្រាស់រូបភាពក្នុងសៀវភៅ "*A Field Guide to the Birds of South-east Asia*" បោះពុម្ពដោយរោងពុម្ព *New Holland Publishers ltd* សំរាប់ដាក់បញ្ចូលក្នុងសៀវភៅនេះ។ សូមថ្លែងអំណរគុណដល់ អស់លោកវិចិត្រករទាំងអស់ដែលមានក្នុងសៀវភៅ **Craig Robson** នេះរួមមានលោក: **Richard Allen, Tim Worfolk, Stephen Message, Jan Wilczur, Clive Byers, Mike Langman, Ian Lewington, Christopher Schmidt, Andrew Mackay, John Cox, Anthony Disley, Hilary Burn, Daniel Cole and Martin Elliot.** យើងសូមអរគុណផងដែររោងពុម្ព *Christopher Helm Ltd* លើសៀវភៅដែលមានឈ្មោះ ថា " *Pipits and Wagtails* " និពន្ធដោយលោក **Per Alström** និង លោក **Krister Mild** ចំពោះរូបភាពសត្វស្លាបខ្ញប់ដីមេគង្គលើ (*Motacilla samveasnae*) ។ និងសូមថ្លែងអំណរគុណផងដែរដល់លោក **Nigel Redman** និងវិចិត្រករ លោក **Bill Zetterström** ក្នុងបេសកកម្មស្រាវជ្រាវសត្វស្លាបនេះ។

រូបភាពផែនទី ដោយលោក **Etienne Delattre** ។

អ្នកឧបត្ថម្ភថវិការដ៏ច្រើនជាងគេលើការបោះពុម្ពផ្សាយសៀវភៅនេះដោយស្ថានទូតអង់គ្លេសប្រចាំព្រះរាជាណាចក្រកម្ពុជា។ អ្នកឧបត្ថម្ភថវិការផ្សេងទៀតលើការបោះពុម្ពសៀវ-ភៅនេះដែររួមមាន *UNDP-GEF* នៃគំរោងអភិរក្ស និងគ្រប់គ្រងតំបន់ទេសភាពនៅភូមិភាគខាងជើង និង *Danida* នៃគំរោងអភិវឌ្ឍន៍សមត្ថភាពថ្នាក់ជាតិ និង *World Bank-GEF* នៃគំរោងគ្រប់គ្រងជីវៈចំរុះ និងតំបន់ការពារ ។

ភ្នំពេញ ខែ សីហា ឆ្នាំ ២០០៣

## សេចក្តីផ្តើម:

សៀវភៅ **ចក្ខុទេ្ចកំនៅតំបន់វាលឆ្កោះទៅស្គាល់ "សត្វស្លាបនៃប្រទេសកម្ពុជា"** ត្រូវបានបោះពុម្ពឡើងជាលើកទី២ក្រោមការជួយឧបត្ថម្ភបោះពុម្ពដោយមូលនិធិរបស់ស្ថានទូតអង់គ្លេសតាមរយៈអង្គការសមាគមអភិរក្សសត្វព្រៃ (WCS)។ សូមបញ្ជាក់ផងដែរថាសៀវភៅសត្វស្លាបប្រទេសកម្ពុជានេះត្រូវបានបោះពុម្ពឡើងលើកទី១នៅឆ្នាំ១៩៩៨មានចំនួន២០០០ក្បាលហើយដោយសារតែសៀវភៅនេះជាទីចាប់អារម្មណ៍ និងជក់ចិត្តសំរាប់មិត្តអ្នកសិក្សាក៏ដូចជាមិត្តអ្នកអានផងនោះទើបសៀវភៅនេះត្រូវបានចែកចាយអស់តាំងពីឆ្នាំ២០០០មកម្លេះ។ ការចេញផ្សាយសៀវភៅសត្វស្លាបលើកទី២នេះមានគោលបំណងផ្តល់ជាបច្ច័យលើការយល់ដឹងពីសត្វស្លាបនៅក្នុងប្រទេសកម្ពុជាជាពិសេសផ្សព្វផ្សាយនូវចំណេះដឹងថ្មីៗថែមទៀតដល់ស្រទាប់អ្នកសិក្សាទាំងឡាយក៏ដូចជាយុវវ័យសម័យថ្មីដែលជាទំពាំងស្នងឬស្សីសំរាប់ប្រទេសជាតិទៅអនាគត។ ជាមួយនេះដែរការបោះពុម្ពផ្សាយសៀវភៅ **ចក្ខុទេ្ចកំនៅតំបន់វាលឆ្កោះទៅស្គាល់ "សត្វស្លាបនៃប្រទេសកម្ពុជា"** លើកទី២នេះយើងបានកែប្រែ និងបញ្ចូលបន្ថែមនូវលក្ខណៈជាច្រើនដូចជា :

-រាល់លក្ខណៈជីវសាស្ត្រនៃប្រភេទសត្វស្លាបនិមួយៗត្រូវបានផ្ទៀងផ្ទាត់ និងកែសំរួលយ៉ាងម៉ត់ចត់អំពីអត្តសញ្ញាណកម្ម ប្រភេទទីជំរក របាយ រដូវពងកូន ដើម្បីអោយមិត្តអ្នកស្រាវជ្រាវ ឬមិត្តអ្នកអានបានទទួលព័តមានកាន់តែច្រើន។

-បានបញ្ចូលបន្ថែមនូវប្រភេទសត្វស្លាបថ្មីៗ និងផ្សេងៗទៀតជាច្រើនដែលទើបកត់ត្រាបានក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ។

-បានបញ្ចូលបន្ថែមនូវរូបភាពសត្វស្លាបប្រភេទសំខាន់ៗមួយចំនួនថែមទៀតដែលយើងទើបកត់ត្រាបាន។

-បានកែប្រែ និងបញ្ចូលបន្ថែមនូវឈ្មោះប្រភេទសត្វស្លាបនិមួយៗ ជាភាសាខ្មែរស្ទើរតែទាំងអស់។

នៅក្នុងប្រទេសកម្ពុជាអ្នកយល់ដឹងពីសត្វស្លាបនៅមានតិចតួចណាស់ ហើយការសិក្សាស្រាវជ្រាវក៏មិនទាន់មានលក្ខណៈទូលំទូលាយនៅឡើយដែរ។ ដូច្នេះការស្រាវជ្រាវបន្ថែមជារៀងរាល់ថ្ងៃ គឺជាតម្រូវការមួយដ៏មានតម្លៃបំផុតចំពោះការយល់ដឹងពីសត្វស្លាបនៅក្នុងប្រទេសយើងនេះ។ សត្វស្លាបដែលមានគ្រប់ទីកន្លែងនៃប្រភេទទីជំរកចំនួន ៣០៣ ប្រភេទត្រូវបានបង្ហាញជារូបភាពពណ៌នៅក្នុងសៀវភៅនេះ។ ទាំងនេះគឺសំរាប់ជាជំនួយដល់សំណាក់មនុស្សគ្រប់រូបដើម្បីងាយស្រួលក្នុងការធ្វើអត្តសញ្ញាណកម្ម និងរៀនបន្ថែមអំពីប្រភេទសត្វស្លាប។ ក្នុងនោះមានសត្វស្លាបចំនួន ៥២ ប្រភេទដែលជាប្រភេទទទួលការគំរាមកំហែងហើយដែលកំពុងឈាន ទៅ រកការផុតពូជទាំងនៅក្នុងតំបន់ និងក្នុងពិភពលោក។

កម្ពុជាគឺជាប្រទេសមួយដែលសំបូរព្រៃឈើគ្រប់ប្រភេទដែលផ្តល់ជំរកដល់ប្រភេទ

សត្វស្លាបសំខាន់ៗជាច្រើន ហើយយើងសង្ឃឹមថា វត្តមាននៃទីជំរកទាំងនេះនឹងជួយក្នុងការចាត់ទុកប្រទេសកម្ពុជាគឺជាប្រទេសសំខាន់មួយសំរាប់ផ្តល់ជំរកដល់ប្រភេទសត្វស្លាបជាច្រើនទៀតដែលកំពុងទទួលការគំរាមកំហែង ក្នុងទិសដៅដើម្បីអភិរក្សប្រភេទទាំងនោះទៅថ្ងៃអនាគត។

**សៀវភៅនេះត្រូវបាន បែងចែកជាបីជំពូក រួមមានៈ**

**ក-ជំពូកទី ១:** សេចក្តីផ្តើម ដែលនិយាយអំពីវិធីប្រើប្រាស់សៀវភៅ និងគំនូសបំព្រួញដែលបង្ហាញពីផ្នែកសំខាន់ៗរបស់សត្វស្លាប។

**ខ-ជំពូកទី២:** គឺជាផ្នែកសំខាន់បំផុតដែលមានរូបភាពពណ៌ និងអត្ថបទដែលនិយាយអំពីប្រភេទសត្វស្លាបនិមួយៗ។ ជំពូកនេះចែក ចេញជាបីក្រុមទៅតាមប្រភេទទីជំរកនិមួយៗ រួមមាន :

១-ក្រុមទី១: ប្រភេទសត្វស្លាបរស់នៅទីក្រុង និងជនបទ។

២-ក្រុមទី២: ប្រភេទសត្វស្លាបរស់នៅតំបន់ដីសើម (តំបន់ទឹកសាប និងតំបន់ឆ្នេរ)។

៣-ក្រុមទី៣: ប្រភេទសត្វស្លាបរស់នៅតំបន់ព្រៃ។

**គ-ជំពូកទី ៣:** ជាផ្នែកចុងក្រោយនៃសៀវភៅគឺជាបញ្ជីឈ្មោះសត្វស្លាបទាំងអស់ដែលមានក្នុងប្រទេសកម្ពុជា ជាភាសាអង់គ្លេសឡាតាំង និងភាសាខ្មែរ។

## វិធីប្រើប្រាស់សៀវភៅ:

### ១-តើត្រូវរកឈ្មោះប្រភេទសត្វនិមួយៗយ៉ាងដូចម្តេច?

ដើម្បីធ្វើអត្តសញ្ញាណកម្មសត្វស្លាបប្រភេទណាមួយត្រូវអនុវត្តតាមបណ្តាជំហានដូចខាងក្រោម :

**I-**ត្រូវសំរេចថា តើប្រភេទណាមួយនៅក្នុងជំពូកទាំង ៣ នេះដែលបានពិពណ៌នាអំពីជំរករបស់សត្វដែលអស់លោកអ្នកបានឃើញ។ ឧទាហរណ៍: ប្រសិនបើឃើញនៅក្នុងទីក្រុងដូច្នេះយើងត្រូវរកមើលក្រុមប្រភេទសត្វស្លាបដែលរស់នៅតាមទីក្រុង និង ទីជនបទ។

**II-**បើករកទំព័រដែលមានរូបភាពពណ៌សំរាប់ជំពូកនិមួយៗ។ សត្វស្លាបទាំងអស់នោះត្រូវបានដាក់ក្នុងក្រុមជាមួយគ្នា ដែលមានបណ្តោយខ្លួន និងពណ៌ប្រហាក់ប្រហែលគ្នារួចហើយរកមើលប្រភេទសត្វស្លាបនោះនៅលើសន្លឹករូបភាពពណ៌ដោយផ្ទៀងផ្ទាត់ទៅ នឹងសត្វស្លាបដែលអស់លោកអ្នកបានឃើញ។ ឧទាហរណ៍ : សត្វស្លាបដែលមានបណ្តោយខ្លួនមធ្យម ពណ៌ស និង ខ្មៅ សំលេងពិរោះរណ្តំរស់នៅក្នុងភូមិវាអាចជាសត្វឡាចេកដែលមានលេខរៀងទី ២៥ ។

**III-** កំណត់សំគាល់លេខរៀងរបស់សត្វ រួចពិនិត្យឈ្មោះវាដែលមានលេខរៀងដូចគ្នានៅក្នុងអត្ថបទមាននៅទំព័រខាងឆ្វេងដៃលោកអ្នក។ ចូរក្រលេកមើលប្រសិនបើអស់លោកអ្នកបានឃើញសត្វដែលបានពិពណ៌នានៅក្នុងអត្ថបទ សូមយកចិត្តទុកដាក់ជាពិសេសទៅលើមាឌសត្វស្លាប និងការពណ៌នាអំពីលក្ខណៈសំខាន់ៗរបស់វា។ ឧទាហរណ៍: លេខរៀងទី២៥ជាសត្វឡាចេក ហើយតាមអត្ថបទបង្ហាញថាវាមានសំលេងពិរោះរណ្តំ។

សូមចងចាំថា សត្វស្លាបទាំងអស់មិនមែនរាប់បញ្ចូលសំរាប់តែជំរកពិសេសណាមួយនោះទេ តែផ្ទុយទៅវិញសត្វស្លាបដែលគេឃើញញឹកញាប់នៅក្នុងទីក្រុង និង តាមភូមិស្រុកនានាក៏អាចឃើញមាននៅទីជំរកផ្សេងៗទៀតផងដែរ ។ ប្រសិនបើអស់លោកអ្នកមិនអាចស្គាល់ឈ្មោះសត្វស្លាបនោះ លោកអ្នកគ្រាន់តែកំណត់គ្រួសារឱ្យបានជាមុនសិន ថាតើសត្វស្លាបប្រភេទនោះនៅក្នុងក្រុមគ្រួសារណា នោះយើងនឹងអាចដឹងប្រភេទណាមួយនោះនៅក្នុងគ្រួសារតាមរយៈបញ្ជីឈ្មោះសត្វស្លាបកម្ពុជានៅទំព័រខាងក្រោយនៃសៀវភៅនេះហើយយើងក៏អាចដឹងវិធីដើម្បីរកឈ្មោះសត្វស្លាបទាំងនោះនៅក្នុងសៀវភៅដទៃទៀតដែរ ។

**២ -<u>ការកែប្រែ:</u>**

យើងបានកែប្រែនូវឈ្មោះសត្វស្លាបមួយចំនួនជាភាសាខ្មែរអាស្រ័យទៅតាមឈ្មោះដែលប្រជាជនមូលដ្ឋានបានហៅ ប្រភេទសត្វខ្លះអាចមានឈ្មោះពីរឬបីអាស្រ័យទៅតាមតំបន់ តែក្នុងសៀវភៅនេះខ្ញុំយកតែឈ្មោះពីរយ៉ាងច្រើនតែប៉ុណ្ណោះ ឧទាហរណ៍ ក្នុងតារាងខាងក្រោម :

| ល.រ | ឈ្មោះជាភាសាអង់គ្លេស | ឈ្មោះជាភាសាឡាតាំង | ឈ្មោះចាស់ | ឈ្មោះថ្មី |
|---|---|---|---|---|
| ១ | White-shouldered Ibis | *Pseudibis davisoni* | កុក្កូនខ្មៅ | ត្រយ៉ងចំកំកស |
| ២ | Great Slaty Woodpecker | *Mulleripicus pulverulentus* | ត្រសេះធំប្រផេះ | ត្រសេះដរី |
| ៣ | Woolly-necked Stork | *Ciconia episcopus* | សត្វកស | ត្រុំ ឬ កុកពាក់អំបោះ |
| ៤ | Giant Ibis | *Pseudibis gigantea* | កុយក្ស | ត្រយ៉ងយក្សឬឪលើក |
| ៥ | Chestnut–headed Partridge | *Arborophila cambodiana* | ក្រួចសំពៅ | ក្រួចសំពៅឬមាន់ក្រិច |
| ៦ | Common Hoopoe | *Upupa epops* | បាគូ | បាគូ ឬ កាពុតញើង |
| ៧ | Japanese Quail | *Coturnix japonica* | ក្រួចសំពៅ | ក្រួចទ្រូងស |
| ៨ | Green Peafowl | *Pavo muticus* | ក្ងោកបៃតង | ក្ងោក |

<u>ផ្នែកផ្សេងៗនៃសត្វស្លាប:</u>









## ការអភិរក្សសត្វស្លាបនៅក្នុងប្រទេសកម្ពុជា:

### ១-ការគំរាមកំហែង:

មានការគំរាមកំហែងជាចំបង ២ ករណីចំពោះសត្វស្លាបនៅក្នុងប្រទេសកម្ពុជា :

**I- ការបរបាញ់:** សត្វស្លាបជាច្រើនប្រភេទនៅក្នុងប្រទេសកម្ពុជា ត្រូវបានគេបរបាញ់ធ្វើជាអាហារ ឬ ធ្វើពាណិជ្ជកម្ម ជាពិសេសគឺពពួកសត្វស្លាបទឹកធំៗដូចជា ត្រដក់ រនាល ក្រៀល ... ។ល។ ឬត្រូវបានគេប្រមូលយកពង-កូនពីសំបុក។ ប្រសិនបើសកម្មភាពនេះ នៅតែបន្តប្រភេទសត្វស្លាបទាំងនេះនឹងពិបាកជួយស្រោចស្រង់ហើយអាចនឹងផុតពូជនៅក្នុងប្រទេសកម្ពុជា។

**II- ការបំផ្លាញទីជំរក:** បណ្តាប្រភេទសត្វជាច្រើនត្រូវបានគំរាមកំហែង នឹងអាចឈានទៅរកការផុតពូជនៅក្នុងប្រទេសកម្ពុជាដោយសារការបំផ្លាញទីជំរករបស់វា។ ជាពិសេសចំពោះប្រភេទសត្វស្លាបព្រៃប្រភេទសត្វស្លាបដែលពងនៅក្នុងរន្ធឈើធំៗ ដូចជាកេងកង ដែលក្រោយពីការកាប់ព្រៃឈើអស់វាមិនអាចមានដើមឈើតទៅទៀតសំរាប់ពងកូនឡើយហើយវានឹងអាចផុតពូជ។ បញ្ហាស្រដៀងគ្នានេះដែរដែលប្រឈមមុខជាមួយសត្វស្លាបទឹកនោះ គឺការបាត់បង់តំបន់ដីសើមដោយសារការអភិវឌ្ឍន៍ហួសកំរិត។

**២-សកម្មភាពអភិរក្ស:**

ពេលថ្មីៗនេះនាយកដ្ឋានរុក្ខា-ប្រមាញ់បានសហការជាមួយអង្គការអន្តរជាតិនានាជាច្រើនដូចជា: អង្គការ(*WCS*) អង្គការ (*WWF*) អង្គការ (*FFI*) អង្គការ (*CI*) អង្គការ (*ICF*) អង្គការ (*BirdLife International*) និងអង្គការ (*WildAid*) ។ល។ បានចុះសិក្សាស្រាវជ្រាវតំបន់សំខាន់ៗ ជាច្រើនទូទាំងប្រទេសកម្ពុជា។ រាល់កំណត់ត្រាទាំងអស់ ដែលបានពីការសិក្សាស្រាវជ្រាវលើប្រភេទសត្វស្លាបត្រូវបានប្រមូលយកមកបញ្ចូលក្នុងការបោះពុម្ពផ្សាយសៀវភៅសត្វស្លាបកម្ពុជាលើកទីពីរនេះ។

យើងសង្ឃឹមថាពតិមានទាំងនេះអាចជាជំនួយដ៏ធំធេងសំរាប់អ្នកសិក្សាស្រាវជ្រាវលើប្រភេទសត្វស្លាបទាំងពេលបច្ចុប្បន្ន និងទៅអនាគតក៏ដូចជាជួយដាស់អារម្មណ៏ដល់ប្រជាជនខ្មែរគ្រប់រូបបានស្គាល់ពីសត្វព្រៃនៅក្នុងស្រុកយើង និងមានគំនិតស្រឡាញ់ និងថែរក្សាសម្បត្តិធម្មជាតិនេះសំរាប់កូនខ្មែរជំនាន់ក្រោយៗទៀត។

## តំបន់សត្វស្លាបសំខាន់ៗមួយចំនួននៅក្នុងប្រទេសកម្ពុជា

មានកន្លែងសំខាន់ៗ ចំនួន១៥កន្លែងនៅក្នុងប្រទេសកម្ពុជា ដែលអាចអោយលោកអ្នកអង្កេតសត្វស្លាបទាំងឡាយបានដូចជា :

**១-តំបន់ខ្ពង់រាបភាគខាងជើង:** ភាគច្រើនជាតំបន់ព្រៃរបោះ ក្រៅពីនោះមានព្រៃពាក់កណ្តាលស្រោង និង ព្រៃស្រោងគឺជាតំបន់ទេសភាពតែមួយគត់ដែលនៅសេសសល់ធំបំផុតក្នុងបណ្តាប្រទេសឥណ្ឌូចិនភាគខាងត្បូង និងប្រទេសថៃ។ តំបន់នេះទ្រទ្រង់ប្រភេទសត្វស្លាបសំខាន់ៗជាច្រើនដែលមានតែមួយគត់ក្នុងភូមិភាគអាស៊ីអាគ្នេយ៍យើងនេះ។ ប្រភេទសំខាន់ៗដែលត្រូវអភិរក្សក្នុងតំបន់នេះរួមមាន: ប្រភេទត្រយ៉ងយក្ស ត្រយ៉ងចំកំកស ត្មាតទាំងបីប្រភេទ អង្កត់ខ្មៅ ត្រដក់ធំ ត្រដក់តូច ក្រៀល ទាព្រៃស្លាបស និង ក្ងោក ដែលសត្វទាំង នេះភាគច្រើនពងកូននៅក្នុងតំបន់នេះតែម្តង។

**២-តំបន់ព្រៃលិចទឹកបឹងទន្លេសាប:** ជាតំបន់ដ៏ល្អបំផុតសំរាប់សត្វស្លាបទឹកភាគច្រើនរកស៊ី និងពងកូននៅតំបន់នេះដែលព័ទ្ធជុំវិញទៅដោយព្រៃលិចទឹក។ តំបន់នេះបង្កើតបានជាតំបន់សំខាន់បំផុតក្នុងភូមិភាគអាស៊ីអាគ្នេយ៍សំរាប់សត្វស្លាបទឹកធំៗពងកូនដែលប្រភេទទាំងនេះភាគច្រើនកំពុងទទួលរងការគំរាមកំហែងក្នុងពិភពលោករួមមាន : ទុងប្រផេះ ត្រដក់ធំ ត្រដក់តូច រនាលពណ៌ រនាលស ស្មោញ ត្រយ៉ងខ្លួនស ពពូលទឹក និង អកត្រីក្បាលប្រផេះ។

**៣-តំបន់ទំនាបវាលស្មៅលិចទឹកបឹងទន្លេសាប:** ក្រៅពីតំបន់ដែលស្ថិតនៅជុំវិញ និងក្បែរបឹង គឺជាតំបន់វាលស្មៅ និង ព្រៃគុម្ពោតលិចទឹកតាមរដូវកាល ព្រមទាំងវាលស្រែ។ តំបន់ទាំងនេះមានសារ:សំខាន់ដែលផ្តល់ទីជំរកដ៏ល្អសំរាប់ពពួកសត្វស្លាបដែលទទួលរងការគំរាមកំហែងមួយចំនួន និងជាតំបន់សំរាប់សត្វស្លាបទាំងនេះពងកូនទៀតផង រួមមាន: សត្វខ្សឹប ឬ

ទ្រមាក់អណ្តើក ចាបដូនតាវាលស្រែ (ជាប្រភេទអន្តោប្រវេសន៍) និងឥន្ទ្រីយ៍ជាដើម។ ព្រមទាំងជាតំបន់សំខាន់សំរាប់សត្វស្លាបទឹកដទៃទៀតរកចំណើផងដែរ។

**៤-ផ្លូវទឹកទន្លេមេគង្គ:** ផ្លូវទឹកទន្លេមេគង្គ និង ដៃរបស់វាចាប់ពីព្រំដែនឡាវ និងព្រំដែនវៀតណាមចុះមក គឺជាតំបន់ដែលមានទីជំរកដ៏ល្អដូចជា វាលខ្សាច់លិចទឹកតាមរដូវកាល គ្រួស និងផ្ទាំងថ្មដែលមានរុក្ខាជាតិដុះ ហើយបានផ្តល់អំណោយផលដ៏ល្អសំរាប់ប្រភេទសត្វស្លាបសំខាន់ៗមួយចំនួនរស់នៅ និងពងកូនដូចជា: ខ្ទប់ដីមេគង្គលើ រំពេរពោះខ្មៅ សត្វជង្គង់ក្រាស់ចំពុះខ្មៅ ទន្រ្ទីតទន្លេ ត្រចៀកកាំកន្ទុយខ្សែពីរ ត្រចៀកកាំទន្លេត្នោតលាត ត្រដេវវិចទន្លេ។

**៥-តំបន់ជួរភ្នំអាណាមភាគខាងត្បូង:** តំបន់ខ្ពង់រាបទាំងនេះគ្របដណ្តប់ទៅដោយព្រៃស្រោង និងពាក់កណ្តាលស្រោងដែលស្ថិតនៅភូមិភាគឦសាននៃប្រទេសរួមមានខេត្តរតនៈគិរី និងមណ្ឌលគិរី។ ប្រភេទសត្វស្លាបសំខាន់ៗ ដែលទទួលរងការគំរាមកំហែងក្នុងពិភពលោកក្នុងតំបន់នេះដូចជា: ទទាទ្រូងលឿង និងមាន់ទោប្រាក់ពណ៌ប្រផេះបៃតងជាដើម។

**៦-តំបន់ព្រៃកោងកាងចាត់ចាច:** ជាតំបន់មានព្រៃកោងកាង និងតំបន់វាលភក់ដែលទទួលទឹកជំនោរនាចស្ថិតនៅតាមឆ្នេរសមុទ្រនៃប្រទេសកម្ពុជា។ សារៈសំខាន់នៃតំបន់ទាំងនេះគឺជាទីជំរករបស់ពពួកសត្វស្លាបសមុទ្រដែលភាគច្រើនជាប្រភេទអន្តោប្រវេសន៍ទៀតផង។ ហើយតំបន់ទាំងនេះក៏អាចជាជំរកពងកូនរបស់ពពួក ត្រដក់តូច និងរនាលស។

**៧-តំបន់កោះក្នុងសមុទ្រ:** តំបន់កោះមួយចំនួនក្នុងសមុទ្របានផ្តល់ជាកន្លែងពងកូនដ៏សំខាន់សំរាប់សត្វស្លាបសមុទ្រ ដូចជា ពពួក: សត្វក្បាលធំខ្សាច់ ព្រាបកោះ ព្រាបស-ខ្មៅ និងពពួក រំពេផ្សេងៗទៀត។

**៨-តំបន់ជួរភ្នំក្រវាញ:** ជាតំបន់ព្រៃស្រោងខ្ពង់រាបនៃជួរភ្នំក្រវាញ រួមបញ្ចូលទាំងជួរភ្នំដំរីនៅភាគនិរតីនៃប្រទេស ដែលត្រូវបានការចាប់អារម្មណ៍យ៉ាងខ្លាំងក្នុងពេលថ្មីៗនេះអំពីវត្តមានសត្វស្លាបសំខាន់ៗក្នុងតំបន់នេះ។ មានសត្វស្លាបពីរប្រភេទដែលជាប្រភេទស្ថានិក ដែលរស់នៅក្នុងតំបន់ជួរភ្នំនេះគឺ ក្រួចសំពៅ ឬ មាន់ក្រិច និងកម្ពុជាចកវិក ។

**<u>តំបន់តូចៗសំខាន់ផ្សេងទៀត:</u>**

**៩-តំបន់ឧទ្យានជាតិរាម**

**១០-តំបន់ឧទ្យានជាតិបូកគោ**

**១១-តំបន់ឧទ្យានជាតិគិរីរម្យ**

**១២-តំបន់អភិរក្សសត្វក្រៀលអាងត្រពាំងថ្ម**

**១៣-តំបន់ទន្លេមេគង្គលើ**

**១៤-តំបន់វាលភក់បាសិត**

**១៥-តំបន់វាលភក់បាសាក់**

# តំបន់សត្វស្លាបសំខាន់ៗមួយចំនួននៅក្នុងប្រទេសកម្ពុជា



## ការកត់ត្រាសត្វស្លាប

កំណត់ត្រាគឺមានសារៈប្រយោជន៍ខ្លាំងណាស់ប្រសិនបើអស់លោកអ្នកអាចកត់ត្រាសត្វស្លាបទាំងឡាយនៃការអង្កេតណាមួយរបស់អស់លោកអ្នក ជាពិសេសប្រភេទសត្វស្លាបដែលកំពុងទទួលការគំរាមកំហែង ។ ពត៌មានដែលត្រូវកត់ត្រាចូលមានជាគំរូដូចខាងក្រោម :

- ឈ្មោះប្រភេទសត្វស្លាប ( ជាភាសាខ្មែរ ហើយបើមានលទ្ធភាពអាចជាភាសាអង់គ្លេសផងដែរ) ។
- ទីកន្លែង ( ទាំងនៅក្នុងស្រុក និង ខេត្ត)
- កាលបរិច្ឆេទ
- លេខកូអរដោនេ ( *UTM* )
- ចំនួនសត្វដែលអស់លោកអ្នកបានឃើញ
- ប្រភេទទីជំរក
- ឥរិយាបថរបស់សត្វស្លាប ។ <u>ឧទាហរណ៍</u>: វាកំពុងរកស៊ីនៅលើដី ឬ លើដើមឈើ ? វាស្រែក? វាកំពុងធ្វើសំបុក? ... ។ល ។
- ឬអ្នកអាចគូររូបសត្វស្លាបនោះដោយបញ្ជាក់លើចំនុចសំខាន់ទាំងឡាយដែលអ្នកចាប់អារម្មណ៍ ។

យើងខ្ញុំជឿជាក់ថាកង្វះខាតទាំងឡាយប្រាកដជាកើតមានឡើងដោយមិនអាចប្រកែកបាន ក្នុងនាមជាអ្នករៀបរៀងកែសំរួល និងបោះពុម្ពផ្សាយនៃសៀវភៅសត្វស្លាបប្រទេសកម្ពុជាលើកទីពីរនេះ យើងខ្ញុំសូមខន្តីអភ័យទោសពីសំណាក់មិត្តអ្នកអានទាំងឡាយនឹងរង់ចាំទទួលគ្រប់ពេលវេលានូវមតិកែលំអរក្នុងន័យស្ថាបនាជានិច្ច នោះគឺក្នុងគោលដៅតែមួយគត់គឺអភិរក្ស សត្វព្រៃនៅកម្ពុជាដើម្បីកូនចៅយើងទៅជំនាន់ក្រោយៗទៀត ។

# ប្រភេទសត្វស្លាបរស់នៅទីក្រុង និងជនបទ



# Birds of Town and Countryside





**1 -ក្រួចអ៊ីត:** Barred Buttonquail *Turnix suscitator* ១៥-១៧,៥ ស.ម
ជាទូទៅសត្វស្លាបមានចំពុះ និងជើងពណ៌ប្រផេះ ពោះពណ៌ត្នោតទុំ ទ្រូងអង្កន់ខ្មៅញឹក។ ញី: បំពង់ក និងទ្រូងផ្នែកខាងលើពណ៌ខ្មៅ។ ទីជំរក: វាលស្មៅស្ងួត គុម្ពោតព្រៃ និងដំណាំកសិកម្ម។ សភាព: វត្តមានគ្រប់រដូវ សំបូរនៅតំបន់វាលទំនាប។ រដូវបន្តពូជ: ចាប់ពីខែ ធ្នូ ដល់ខែ កញ្ញា។

**2 -ក្រួចតូច:** Small Buttonquail *Turnix sylvatica* ១៣-១៤ ស.ម
ញី: ផ្នែកខ្នងមានពណ៌ត្នោតខ្ចី និងមានឆ្នូតខ្មៅ។ ឈ្មោល: ខ្នងពណ៌ទឹកក្រូចចាស់។ ទីជំរក: វាលស្មៅស្ងួត គុម្ពោតព្រៃ។ សភាព: វត្តមានពេញមួយឆ្នាំ មានគ្រប់ទីកន្លែង។ រដូវបន្តពូជ: ចាប់ពីខែ មិថុនា ដល់ កញ្ញា។

**3 -ក្រួចទ្រូងខៀវ:** Blue-breasted Quail *Coturnix chinensis* ២០ ស.ម
មាឌល្អិត ឈ្មោល: ផ្នែកខ្នងប្រផេះស្រ អាប់ជាងក្រួចដទៃបំពង់កខ្មៅទ្រូងស ពោះឈាមជ្រូក។ ញី: ពណ៌លឿងក្រម៉ៅ។ ទីជំរក: វាលស្មៅ វាលស្រែ។ សភាព: វត្តមានពេញមួយឆ្នាំ មានគ្រប់ទីកន្លែង។ រដូវបន្តពូជ: ពេញមួយឆ្នាំ។

**4 -លលកទ្រាំង:** Red Collared Dove *Streptopelia tranquebarica* ២៣-២៤,៥ ស.ម
ឈ្មោល: មាឌមធ្យម ក្បាលមានពណ៌ខៀវខ្ចី មានចំកំកលើខ្មៅ ដងខ្លួនជាទូទៅពណ៌ត្នោតទុំ ចុងខ្នងនិងលើកន្ទុយពណ៌ប្រផេះ។ ញី: ស្រដៀងឈ្មោលដែរតែសំបុរដងខ្លួនជាទូទៅពណ៌ត្នោតខ្ចី ពេលហើរកន្ទុយឆ្លាស់ក្រៅពណ៌ស។ ទីជំរក: តំបន់វាលលំហស្ងួត ព្រៃគុម្ពោត និងតំបន់ កសិកម្ម។ សភាព: វត្តមានពេញមួយឆ្នាំមានគ្រប់ទីកន្លែង។ រដូវបន្តពូជ: ពេញមួយឆ្នាំ។

**5 -លលកបាយ:** Spotted Dove *Streptopelia chinensis* ៣០-៣១ ស.ម
ពេលពេញវ័យ: បន្ទុលក្បាលពណ៌ប្រផេះ ខ្នងពណ៌ត្នោតចាស់ និងមានឆ្នូតៗខ្មៅពាសពេញ។ មានចំកំកលើធំ លាយអុជៗសខ្មៅ ផ្នែកពោះពណ៌ត្នោតខ្ចី ពេលហើរបង្ហាញនូវកន្ទុយតំរៀបជាកាំ និងចុងកន្ទុយជ្រលក់ស។ ទីជំរក: តាមតំបន់កសិកម្ម ព្រៃគុម្ពោត វាលលំហ។ សភាព: វត្តមានពេញមួយឆ្នាំ មានគ្រប់ទីកន្លែង។ រដូវបន្តពូជ: ពេញមួយឆ្នាំ។

**6 -ព្រាបស្រុក:** Rock Pigeon *Columba livia* ៣៣ ស.ម
ជាទូទៅសត្វស្លាបមានពណ៌ប្រផេះស្រាលតែស្លាបមានឆ្នូតខ្មៅពីរ។ កពណ៌បៃតងរលោង ចុងកន្ទុយពណ៌ខ្មៅ ប្រភេទខ្លះពណ៌សសុទ្ធតែម្តង។ ទីជំរក: ទីក្រុង ទីប្រជុំជន តាមភូមិច្រាំងថ្ម និងតាមបណ្តាតំបន់កសិកម្ម។ ជីវភាពត្រូវ: រកចំណីនៅតាម ជើងភូមិ ឬទីប្រជុំជន។ សភាព: វត្តមានពេញមួយឆ្នាំ មានគ្រប់ទីកន្លែង។ រដូវបន្តពូជ: ពេញមួយឆ្នាំ ។





1 ក្រួចអ៊ិត



2 ក្រួចតូច



3 ក្រួចទ្រូងខៀវ



4 លលកទ្រាំង



5 លលកបាយ



6 ព្រាបស្រុក

**7 -ស្ទាំងស្លាបឆែត:** Shikra *Accipiter badius* ៣០-៣៦ ស.ម

ឈ្មោល: ផ្នែកខ្នងពណ៌ប្រផេះព្រលែត ចុងស្លាបហើរទី១ពណ៌ខ្មៅ បំពង់កសដោយមានដៅឆ្នូតពណ៌ប្រផេះ។ មានឆ្នូតៗអង្កន់ញីកពណ៌លឿងនៅផ្នែកពោះ។ ចំកណ្តាលបណ្តោយកន្ទុយខាងក្រោមមានឆ្នូតទទឹងពណ៌ប្រផេះ៤កង់ និង ភ្នែកក្រហម។ ញី: មាឌធំជាងឈ្មោល ភ្នែកលឿង ផ្នែកខ្នងពណ៌លឿងខ្ចី ឆ្នូតកន្ទុយច្បាស់ជាងឈ្មោល។ ទីជំរក: តាមព្រៃល្បោះ ព្រៃពាក់កណ្តាលស្រោង ចំការធំៗ និងតំបន់វាល។ ស្ថានភាព: វត្តមានពេញមួយឆ្នាំ និងមានគ្រប់ទីកន្លែង។ រដូវបន្តពូជ: ចាប់ពីខែ មិនា ដល់មេសា។

**8 -ស្ទាំងលលក:** Black-shouldered Kite *Elanus coeruleus* ៣១-៣៥ ស.ម

ពេញវ័យ: កន្ទុយខ្ចី គែមលើនៃស្លាបពណ៌ខ្មៅ ស្លាបទី១ផ្នែកក្រោមពណ៌ខ្មៅ ផ្ចត់ស្លាបរាងជាអក្សរ V នៅ ពេលសំកាំង។ មិនទាន់ពេញវ័យ: ដើមទ្រូង និងផ្នែកខ្នងពណ៌លឿងខ្ចី សំលេងឮពីយូ ពីយូ នៅពេលដែលវាបង្ហួតរាង។ ទីជំរក: តំបន់វាលលំហរួមទាំងតំបន់កសិកម្ម រយៈកំពស់មិនលើសពី ១៥០០ម។ ជីវសាស្ត្រ: ហើរសំកាំងដើម្បីរកចំណី។ ស្ថានភាព: វត្តមានគ្រប់រដូវ និងមានគ្រប់ទីកន្លែង ពិសេសតំបន់វាលទំនាប។ រដូវបន្តពូជ: ពេញមួយឆ្នាំ។

**9 -ខ្លែងស្រាក:** Barn Owl *Tyto alba* ៣៤-៣៦ ស.ម

ផ្នែកពោះពណ៌ប្រផេះ និងផ្នែកខ្នងពណ៌មាស ព្រមទាំងមានអុជជាជួរៗ ចាប់ពីបន្ទួលក្បាលរហូតដល់ដើមផ្ទាំងស្លាប និងផ្នែកពោះទាំងមូល។ ភ្នែកពណ៌ត្នោចាស់។ ទីជំរក: តាមតំបន់វាលលំហវាលស្រែ ដំណាំកសិកម្ម វាលភក់ ទីប្រជុំជន និងទីក្រុង។ ស្ថានភាព: វត្តមានពេញមួយឆ្នាំ មានគ្រប់ទីកន្លែង។ រដូវបន្តពូជ: ពេញមួយឆ្នាំ។

**10 -ក្អែក:** Large-billed Crow *Corvus macrorhynchos* ៤៨-៥៩ ស.ម

មានបណ្តោយខ្លួនធំពណ៌ខ្មៅលាត មានចំពុះធំ ក្បាលមានកំប៉ោយបន្តិច គន្លងហើរត្រង់។ សំលេងខ្លាកៗ ដូចជាស្អក។ ទីជំរក: តំបន់វាលលំហ តំបន់ព្រៃ ព្រៃកោងកាង ទីប្រជុំជន និងទីក្រុង។ ជីវសាស្ត្រ: ចូលចិត្តរកស៊ីក្បែរភូមិ និងទីប្រជុំជន។ ក្អែកចូលចិត្តស៊ីពងសត្វស្លាបទឹកដទៃនៅតាមជំរុំពងកូននានា។ ស្ថានភាព: វត្តមានពេញមួយឆ្នាំ និងមានគ្រប់ទីកន្លែងហើយច្រើនបំផុតតំបន់បឹងទន្លេសាប។ រដូវបន្តពូជ: ចាប់ពីខែមករា ដល់ មិថុនា។





7 ស្ទាំងស្លាបផែក



8 ស្ទាំងលលក



9 ខ្លែងស្រាក



10 ក្អែក

**11 -អន្ទេបខ្មៅ:** Black Drongo *Dicrurus macrocercus* ២៧-២៨,៥ ស.ម

ជាទូទៅសត្វស្លាបមានសំបុរខ្មៅ ដងខ្លួនទ្រវែង និងកន្ទុយឆែកជ្រៅ។ មិនទាន់ពេញវ័យមានសំបុររោមសរាងជាស្រកានៅផ្នែកពោះ និងចុងខ្នង។ **ទីជំរក:** ព្រៃគុម្ពោតស្រឡះវាលស្រែ វាលភក់ ទីប្រជុំជន តាមមាត់ផ្លូវ។ **ចរាចរ:** វត្តមាននៅរដូវប្រាំង តែមួយចំនួនវត្តមាន ពេញមួយឆ្នាំ សំបូរគ្រប់ទីកន្លែង ពិសេសតំបន់មាត់សមុទ្រ។ **រដូវបន្តពូជ:** ចាប់ពីខែ មិនា ដល់ សីហា។

**12 -ត្រចាក់ខ្លា:** Racket-tailed Treepie *Crypsirina temia* ៣០,៥-៣២,៥ ស.ម

មាឌតូចជាងប្រភេទទ្រមាក់ខ្លាផ្សេងៗទៀត។ ខ្លួនមានពណ៌ខ្មៅទង់ដែងភ្លឺ ភ្នែកពណ៌ខៀវ។ កន្ទុយស្រឡូនរីកចុងរាងដូចជាវែក។ **ទីជំរក:** ព្រៃកោងកាង ព្រៃគុម្ពោត ដុំឈុះព្រៃក្មេង ព្រៃឫស្សី ព្រៃល្បោះ។ **ចរាចរ:** វត្តមានពេញមួយឆ្នាំ និងមានគ្រប់ទីកន្លែង។ **រដូវបន្តពូជ:** ចាប់ពី ខែ មេសា ដល់ សីហា។

**13 -តាវ៉ៅស្រុក:** Plaintive Cuckoo *Cacomantis merulinus* ២១,៥-២៣,៥ ស.ម

**ឈ្មោល:** ក្បាល បំពងក និងទ្រូងមានពណ៌ប្រផេះ ស្លាបពណ៌ខ្មៅព្រលែត និងពោះពណ៌ត្នោត។ **ញី:** ផ្នែកខ្នងមានពណ៌ក្រហមព្រឿងៗជាមួយ និងអង្កន់ឆ្នូតៗពណ៌ខ្មៅ ពោះពណ៌សព្រលែត អង្កន់ពណ៌ខ្មៅស្រាល។ **សំលេង:** ឈ្មោលយំទៅតាមដែនដីរបស់វា សំលេងរបៀបជាហួចជាប់គ្នារ ដឹក ពីរ...ពីរ...ពីរ...។ **ទីជំរក:** ព្រៃគុម្ពោត តំបន់វាល សួនច្បារ និងទីប្រជុំជន។ **ចរាចរ:** វត្តមានពេញមួយឆ្នាំ រដូវបន្តពូជជាទូទៅប្រភេទនេះពងដោយផ្ញើជាមួយប្រភេទដទៃទៀតដោយវាមិនក្រាបពងខ្លួនវាឡើយ។

**14 -ល្អុតធំ:** Greater Coucal *Centropus sinensis* ៤៨-៥២ ស.ម

មានបណ្តោយខ្លួនធំ ក្បាល ក កន្ទុយ និងផ្នែកខាងក្រោមមានពណ៌ខ្មៅរលោងធំជាងល្អុតស្បូវ ស្លាបមានពណ៌ក្រហមជាំ ភ្នែកក្រហម ចំពុះ និងជើងខ្មៅ។ **សំលេង:** យំជាប់ៗ គ្នា អ៊ូតៗៗៗ ចុងបញ្ចប់ញាប់កាន់តែខ្លាំង។ **ទីជំរក:** តំបន់វាលជាយព្រៃ គុម្ពោតព្រៃ តំបន់វាលស្មៅ តាមស្ទឹងអូរ ព្រៃកោងកាង។ **រដូវបន្តពូជ:** ចាប់ពីខែ មករា ដល់ សីហា។

**15 -តាវ៉ៅ:** Asian Koel *Eudynamys scolopacea* ៤០-៤៤ ស.ម

**ឈ្មោល:** ដងខ្លួនទាំងមូលពណ៌ខៀវជាំ បណ្តោយខ្លួនធំ កន្ទុយវែង ភ្នែកពណ៌ក្រហម ចំពុះបៃតង។ **ញី:** ពណ៌ត្នោតចាស់ និងមានឆ្នូតៗ អុជៗសពាសពេញដងខ្លួន។ **សំលេង:** តាវ៉ៅ-តាវ៉ៅ-តាវ៉ៅ រួចរំលឹកឡើងវិញ២-៣នាទីក្រោយមក។ **ទីជំរក:** តំបន់វាលព្រៃគុម្ពោត ព្រៃរបោះ និងតាមសួនច្បារ។ **ចរាចរ:** វត្តមាននៅរដូវប្រាំង មានគ្រប់ទីកន្លែង។ **រដូវបន្តពូជ:** ពងផ្ញើជាមួយសំបុកសត្វស្លាបដទៃ ជាពិសេសសំបុកសត្វក្អែក ។





11 អន្ទេបខ្មៅ



12 ទ្រមាក់ខ្លា



13 តាវ៉ៅស្រុក



14 លួតធំ



15 តាវ៉ៅ





**16 -ត្រសេវក្បាលបៃតង:** Blue-tailed Bee-eater *Merops philippinus* ២៣-២៤ ស.ម
បន្ទូលក្បាល និងដើមខ្នងពណ៌បៃតង បំពង់កផ្នែកលើពណ៌លឿង និងបំពង់កផ្នែកក្រោមពណ៌ត្នោត ចុងខ្នង និងកន្ទុយផ្នែកលើ ពណ៌ខៀវ ។ ទីជំរក: វាលលំហ ជាទូទៅតាមទន្លេ វាលភក់ ព្រៃកោងកាង ។ ជីវសាស្ត្រ: ហើរឆាបចាប់សត្វល្អិតជាចំណី និងទំលើមែកឈើស្រឡះ ។ ឋានៈ: វត្តមានពេញមួយឆ្នាំ មានគ្រប់ទីកន្លែង ។ រដូវបន្តពូជ: ចាប់ ពីខែ កុម្ភៈ ដល់ ឧសភា ។

**17 -ត្រសេវតូច:** Green Bee-eater *Merops orientalis* ១៩-២០ស.ម
ដងខ្លួនទាំងមូលស្ទើរតែពណ៌បៃតង បន្ទូលក្បាល និងកញ្ចឹងកពណ៌ត្នោត មានស្រង់កខ្មៅ កន្ទុយលយវែងផ្នែកកណ្តាល (កន្ទុយម្ជុល) ។ សំលេង: តែមួយបែបជាប់ៗគ្នាទ្រី-ទ្រី-ទ្រី-ទ្រី..... នៅពេលមានអាសន្ន វាបន្លឺសំឡេងផ្សេង ធី.ធី.ធី ។ ទីជំរក: តំបន់វាលលំហស្ងួតដំណាំកសិកម្ម ។ ជីវសាស្ត្រ: ធ្វើសំបុកនៅក្នុងរន្ធដី ។ ឋានៈ: វត្តមានពេញមួយឆ្នាំ មានគ្រប់ទីកន្លែង ។ រដូវបន្តពូជ: ចាប់ពីខែ កុម្ភៈ ដល់ ឧសភា ។

**18 -ខាវខៀវ:** Indian Roller *Coracias benghalensis* ៣១,៥-៣៤,៥ ស.ម
ចំពុះពណ៌ខ្មៅ បំពង់ក ពោះ និងត្រចៀកពណ៌ត្នោត ស្លាបពណ៌ខៀវភ្លឺ ។ សំលេង: របៀបស្រែកគហក គៀក..គៀក.. ។ ទីជំរក: តំបន់វាលលំហ ជាពិសេសបណ្តាតំបន់ស្ងួតៗ ព្រៃរបោះ តំបន់មាត់សមុទ្រ និងទីក្រុង ។ ជីវសាស្ត្រ: ចូលចិត្តទំនៅលើចុងឈើ ហើរឆាបចំណីជាអាហារ ។ ឋានៈ: វត្តមានពេញមួយឆ្នាំ មានគ្រប់ទីកន្លែង ។ រដូវបន្តពូជ: ចាប់ពីខែ មិនា ដល់ឧសភា ។

**19 -ប៉ោលតោកអំបុក:** Coppersmith Barbet *Megalaima haemacephala* ១៦ ស.ម
មាឌតូច ថ្ងាសក្រហម ដៅលឿងធំជុំវិញភ្នែក និងនៅបំពង់ក ។ មានឆ្នូតខ្មៅកាត់ភ្នែក និងពុកមាត់ខ្មៅ ។ ដងខ្លួនទាំងមូលពណ៌បៃតង មានដៅក្រហមនៅបំពង់ក ។ ទីជំរក: ព្រៃរបោះជាយព្រៃ តំបន់វាលលំហមានដើមឈើដុះរាយប៉ាយ ព្រៃកោងកាង និងសួនច្បារ រួមទាំងនៅតាមទីប្រជុំជន និងទីក្រុង រយៈកំពស់មិនលើសពី ៩១៥ម ។ ជីវសាស្ត្រ: ធ្វើសំបុកនៅក្នុងរន្ធឈើ ។ ឋានៈ: វត្តមានពេញមួយឆ្នាំ មានគ្រប់ទីកន្លែង ។ រដូវបន្តពូជ: ចាប់ពីខែ កុម្ភៈ ដល់ កក្កដា ។





16 ត្រដេវក្បាលបៃតង



17 ត្រដេវតូច





18 ទាវខៀវ



19 ប៉ោលគោកអំបុក





**20 -ត្រចៀកកាំ:** Barn Swallow *Hirundo rustica* ១៥ ស.ម
ពេញវ័យ: ផ្នែកខាងលើពណ៌ខ្មៅលាយខៀវរលោង ទ្រូងមានវ័ណ្ឌពណ៌ខ្មៅ ថ្ងាស និងបំពង់កពណ៌ឈាមជ្រូក កន្ទុយឆែកជ្រៅ។ (ពេញវ័យនៅរដូវជ្រុះរោម)។ មិនទាន់ពេញវ័យ: ផ្នែកខាង ពណ៌ត្នោតចាស់ ទ្រូងមានវ័ណ្ឌពណ៌ត្នោត និងផ្នែកពោះពណ៌ទឹកក្រូច។ ទីជម្រក: វាលលំហ មានច្រើននៅតំបន់ទំនាបទឹកច្រើន។ ជីវសាស្ត្រ: ជាទូទៅប្រភេទនេះចូលចិត្តរស់នៅជាហ្វូងធំៗ ស៊ីសត្វល្អិតជាអាហារ ទំលើកក់ ត្រែង និងលើខ្សែភ្លើង។ ឋានៈ: វត្តមាននៅរដូវប្រាំង មានគ្រប់ទីកន្លែង។ រដូវបន្តពូជ: ចាប់ពីខែ ឧសភា ដល់ មិថុនា។

**21 -ត្រចៀកកាំចុងខ្នងក្រហម:** Red-rumped Swallow *Hirundo daurica* ១៧ ស.ម
ផ្នែកពោះពណ៌ស និងមានឆ្នូតៗខ្មៅ។ កញ្ចឹងក និងចុងខ្នងពណ៌ត្នោត និងគូថពណ៌ខ្មៅ ។ សំលេង: ដំបូង ឆ្វិក ឆ្វិក បន្ទាប់មក គៀវ គៀវ...។ ទីជម្រក: នៅតាម វាលលំហ និងព្រៃតាមវាលថ្ម។ ជីវសាស្ត្រ: ផ្លាស់ប្តូរទីមិនឆ្ងាយ។ ឋានៈ: វត្តមាននៅរដូវប្រាំង និងសំបូរគ្រប់ទីកន្លែង។

**22 -ត្រចៀកកាំដើមត្នោត:** Asian Palm Swift *Cypsiurus balasiensis* ១១-១២ ស.ម
ផ្ទាំងស្លាបពណ៌ត្នោតក្រម៉ៅ បណ្តោយខ្លួនតូច ចុងស្លាបស្រួច និងកន្ទុយតូចវែងព្រែកពីរ។ ទីជម្រក: តំបន់វាលលំហ ជារឿយៗ នៅជិតទីក្រុង ភូមិ និងជិតដើមត្នោត។ ជីវសាស្ត្រ: ធ្វើសំបុក និងទំលើដើមត្នោត រកស៊ីតាមតំបន់ភ្នំ។ ឋានៈ: វត្តមានពេញមួយឆ្នាំ មានគ្រប់ទីកន្លែង។ រដូវបន្តពូជ: ចាប់ពីខែ ធ្នូ ដល់ សីហា។

**23 -ត្រចៀកកាំកន្ទុយឆែក:** Fork-tailed Swift *Apus pacificus* ១៨-១៩,៥ ស.ម
មានមាឌធំ សំបុរខ្មៅសុទ្ធ ចុងខ្នងស បំពង់កសព្រាលៗ ផ្នែកពោះអង្កន់សព្រាលៗ។ ទីជម្រក: ក្នុងព្រៃ និងទីវាលលំហ។ ឋានៈ: វត្តមាននៅរដូវប្រាំង ជាប្រភេទកម្រ។ សំលេង: ស្រួយ ស្រ៊ី ស្រ៊ី...។ រដូវបន្តពូជ: ចាប់ពីខែ មេសា ដល់ មិថុនា។

**24 -ត្រចៀកកាំចុងខ្នងស:** House Swift *Apus affinis* ១៤-១៥ ស.ម
ខ្លួនមូលធំ ផ្ទាំងស្លាបធំ កន្ទុយរាងការេ ចុងខ្នងពណ៌ស បំពង់កស។ សំឡេង: បន្តូយ៉ាងស្រួយ ស៊ីក ស៊ីក ស៊ីក...។ ទីជម្រក: តំបន់វាលលំហ និងនៅទីប្រជុំជន។ ឋានៈ: វត្តមានពេញមួយឆ្នាំ និងសំបូរគ្រប់ទីកន្លែង។ រដូវបន្តពូជ: ពេញមួយឆ្នាំ។





20 ត្រចៀកកាំ



21 ត្រចៀកកាំចុងខ្នងក្រហម



22 ត្រចៀកកាំដើមត្នោត



23 ត្រចៀកកាំកន្ទុយឆែក



24 ត្រចៀកកាំចុងខ្នងស

**25 -ល្វាចេក:** Oriental Magpie Robin *Copsychus saularis* ១៩-២១ ស.ម
ឈ្មោល: ខ្នង ក្បាល និងទ្រូង ពណ៌ខ្មៅរលោង ពោះស ឆ្នូតទទឹងស្លាប និងកន្ទុយឆ្លាស់ក្រៅ មានពណ៌ស។ ញី: ក្បាល ខ្នង ទ្រូងពណ៌ប្រផេះចាស់ ។ ទីជំរក: សួនច្បារ ដើមឈើក្នុងទីក្រុង ដំណាំកសិកម្ម ព្រៃកោងកាង។ ជីវសាស្ត្រ: មានសំឡេងពិរោះរណ្តំដូចភ្លេង។ ចរាចរ: វត្តមានពេញមួយឆ្នាំ មានគ្រប់ទីកន្លែង។ រដូវបន្តពូជ: ចាប់ ពីខែ មករា ដល់ កញ្ញា។

**26 -កញ្ជាក់ស្នាវ៍ណ្ឌកខ្មៅ:** Pied Fantail *Rhipidura javanica* ១៧,៥-១៩,៥ ស.ម
សត្វស្លាបមានវ៉ណ្ឌទ្រូងពណ៌ខ្មៅ បំពង់កស និងពោះពណ៌ស មានចិញ្ចើមសកន្ទុយរីកដូចផ្លិត។ ទីជំរក: ព្រៃរបោះ ព្រៃកោងកាង តំបន់ទឹកសាប និងព្រៃលិចទឹក សួនច្បារ។ រដូវបន្តពូជ: ចាប់ពីខែ មករា ដល់ សី ហា។

**27 -ចចិចផ្ទុខ្មៅចុងខ្នងស:** Pied Bushchat *Saxicola caprata* ១៤ ស.ម
ឈ្មោលរដូវបន្តពូជ: ពណ៌ខ្មៅទាំងអស់ ដោយមានឆ្នូតសនៅលើផ្ទាំងស្លាប និងចុងខ្នងពណ៌ស តែបើនៅរដូវមិនបន្តពូជ ខ្លួនមានពណ៌ត្នោតចាស់ ឆ្នូតស្លាប ចុងខ្នង និងក្រោមកន្ទុយពណ៌ស។ ញី: ពណ៌ត្នោតក្រម៉ៅដោយចុងខ្នងពណ៌ច្រេះ និងមានដៅឆ្នូត១លើផ្ទៃកពោះ។ ទីជំរក: នៅតំបន់វាលស្មៅ ព្រៃគុម្ពោត និងតំបន់កសិកម្ម។ ចរាចរ: វត្តមានពេញមួយឆ្នាំ មានគ្រប់ទីកន្លែង។ រដូវបន្តពូជ: ចាប់ពីខែ មិនា ដល់ មិថុនា ពងចំនួនពី៣ ទៅ ៥។

**28 -ចចិចផ្ទុទ្រូងត្នោត:** Common Stonechat *Saxicola torquata* ១៤ ស.ម
ឈ្មោលនៅរដូវមិនបន្តពូជ:ស្រដៀងញីដែរតែម្តុំត្រចៀក និងកអុជៗខ្មៅ។ ឈ្មោលនៅរដូវបន្តពូជ: ក្បាល ផ្នែកខ្នង និងស្លាបពណ៌ខ្មៅ។ ចំហៀងកអុជលើស្លាប និងចុងខ្នងពណ៌ស ទ្រូងពណ៌ក្រហម។ ញី: ពណ៌ត្រសក់ កពណ៌ស និងអុជស្លាបស។ ទីជំរក: វាលស្មៅ និងគុម្ពោតព្រៃតាមដំណាំកសិកម្ម។ ចរាចរ: វត្តមានពេញមួយឆ្នាំ មានគ្រប់ទីកន្លែង។ រដូវបន្តពូជ: ចាប់ពីខែ មិនា ដល់ កក្កដា ។

**29 -ចចិចផ្ទុ:** Blue Rock Thrush *Monticola solitarius* ២១-២៣ ស.ម
ឈ្មោលនៅរដូវបន្តពូជ: ដងខ្លួនទាំងមូលស្ទើតែពណ៌ខៀវ លើកលែងតែស្លាប និងកន្ទុយពណ៌ខ្មៅ។ ឈ្មោលនៅរដូវមិនបន្តពូជ: ខ្លួនទាំងមូលមានពណ៌ផ្ទៃមេឃ វ៉ណ្ឌដោយរោមសខ្មៅរាងជាស្រកាត្រីពេញខ្លួន។ ឈ្មោលពូជ Philippen ពោះពណ៌ត្នោតទុំ ផ្នែកខ្នង ក្បាល និងទ្រូងពណ៌ខៀវខ្ចី។ ញី: ពណ៌ត្នោតលាយប្រផេះស្រអាប់ពេញខ្លួន។ ទីជំរក: តំបន់ថ្មច្រើន តាមចិញ្ចើមផ្លូវតាមផ្ទះនៃទីប្រជុំជន។ ចរាចរ: វត្តមានពេញមួយឆ្នាំ មានគ្រប់ទីកន្លែង។ រដូវបន្តពូជ: ចាប់ពីខែ មករា ដល់ មិថុនា។





26 កញ្ជាក់ស្វារីណ្ឌកខ្មៅ

25 ល្វាចេក



27 ពពិចថ្មខ្មៅចុងខ្នងស



28 ពពិចថ្មទ្រូងត្នោត



29 ពពិចថ្ម

**30 -ខ្ទប់ថីខ្មៅ ស:** White Wagtail *Motacilla alba* ១៩ ស.ម
ផ្នែកខ្នងពណ៌ខ្មៅ និងប្រផេះ ដោយផ្ទាំងស្លាបមានស្នាមឆ្នូតពណ៌ស។ ថ្ងាស និងចំហៀងសងខាងក្បាលពណ៌ស ទ្រូងពណ៌ខ្មៅ និងជើងពណ៌ខ្មៅ ពោះពណ៌ស។ ទីជម្រក: តំបន់វាលលំហ វាលស្មៅ និងវាលខ្សាច់ជាប់ទន្លេ។ ជីវសាស្ត្រ: ពេលដើររកចំណីបក់កន្ទុយឡើងចុះ។ ស្ថានភាព: វត្តមាននៅរដូវប្រាំង ជាប្រភេទកំរ។ រដូវបន្តពូជ: ចាប់ពីខែ មិនា ដល់ មិថុនា ពងចំនួនពី ៤ ទៅ ៥ ពណ៌ស។

**31 -ខ្ទប់ថីពោះលឿង:** Yellow Wagtail *Motacilla flava* ១៨ ស.ម
ឈ្មោល: ផ្នែកពោះពណ៌លឿង ផ្ទាំងស្លាបលឿងលាយខ្មៅ ចិញ្ចើមសវែង។ ញី: ផ្នែកពោះពណ៌លឿងខ្ចី ផ្នែកខ្នងពណ៌ប្រផេះលាយត្នោត មានចិញ្ចើមលឿង ផ្ទាំងស្លាបពណ៌ ខ្មៅឆ្នូតស។ ទីជម្រក: នៅតាមតំបន់ទីវាលគ្រប់ប្រភេទដូចជា តំបន់វាលស្មៅ វាលស្រែ...ជា ពិសេសក្បែរមាត់ទឹក។ ស្ថានភាព: វត្តមាននៅរដូវប្រាំង សំបូរគ្រប់ទីកន្លែង។

**32 -ក្រួចអិនជើងវែង:** Richard's Pipit *Anthus novaeseelandiae* ១៨-២០,៥ ស.ម
នៅពេលដែលមានការប្រុងប្រយ័ត្នសត្វនេះឈរត្រង់ ជើងវែងជាងក្រួចអិនដទៃទៀតហើយក្រញ៉ាំម្រាមក្រោយវែង កន្ទុយវែង ចំពុះវែង មានកន្ទុយសឆ្នាស់ក្រៅ។ ផ្នែកខ្នងពណ៌ត្នោតលាយលឿង និងពោះពណ៌សប្រផេះ។ ទីជម្រក: វាលស្មៅ វាលស្រែ។ ស្ថានភាព: វត្តមាននៅរដូវប្រាំង មានគ្រប់ទីកន្លែង។

**33 -ក្រួចអិន:** Indochinese Bushlark *Mirafra marionae* ១៤-១៥ ស.ម
ស្រដៀងក្រួចអិនជើងវែងដែរ មានដៅអុជពាសពេញនៅលើខ្នង និងទ្រូងគ្មានកន្ទុយសឆ្នាស់ក្រៅទេ។ ស្លាបហើរទីមួយពណ៌ឈាមជ្រូក។ ទីជម្រក: តំបន់វាលស្ងួតជាមួយគុម្ពោតព្រៃ។ ស្ថានភាព: វត្តមានគ្រប់រដូវ និងគ្រប់ទីកន្លែងភាគច្រើននៅតំបន់ទំនាបជុំវិញបឹងទន្លេសាប។

**34 -ពន្លាក់ចូវិច:** Savanna Nightjar *Caprimulgus affinis* ២៥ ស.ម
ឈ្មោល: ខុសប្លែកពីពញ្លាក់ដទៃទៀតដោយមានកន្ទុយសឆ្នាស់ក្រៅនៅពេលហើរ។ ញី: មាឌតូចជាងឈ្មោលបន្តិច កន្ទុយគ្មានសឆ្នាស់ក្រៅទេ។ ទីជម្រក: តំបន់ព្រៃល្បោះ ព្រៃស្រល់ និងព្រៃស្រោង រយៈកំពស់មិនលើសពី ៩១៥ម។ ស្ថានភាព: វត្តមានពេញមួយឆ្នាំមានគ្រប់ទីកន្លែង។ រដូវបន្តពូជ: ចាប់ពីខែ មិនា ដល់ សីហា ពងចំនួន ២។





30 ខ្ទប់ដីខ្មៅ ស



31 ខ្ទប់ដីពោះលឿង



33 ក្រួចអិន

32 ក្រួចអិនជើងវែង



34 ពន្លាក់ជូរិច





**35 –ចចិចត្រចៀកក្រហមស:** Red-whiskered Bulbul *Pycnonotus jocosus* ១៨-២០,៥ ស.ម

មានកំប៉ោយខ្មៅឈរត្រង់ខ្ពស់ មានដៅក្រហមនៅខាងក្រោយភ្នែក និងគូថក្រហម។ ផ្នែកខ្នងពណ៌ត្នោត ផ្នែកពោះ និងគុម្ពត្រចៀកពណ៌ស។ សំលេង: របៀបជាបទភ្លេងយ៉ាងពិរោះ វិតទីវ៉ាអែតឃីបឃីវយ៉ា ឃីកខៃ...។ ទីជំរក: ព្រៃគុម្ពោត ទីវាល និងតំបន់កសិកម្ម។ ឋានៈ: វត្តមានពេញមួយឆ្នាំ យើងសង្កេតឃើញមានច្រើននៅតំបន់ព្រៃរបោះខេត្តមណ្ឌលគិរី។ រដូវបន្តពូជ: ចាប់ពីខែ មករា ដល់ សីហា ពងចំនួនពី ២ ទៅ ៤ ពណ៌ស។

**36 –ចាបក្រុច:** Yellow-vented Bulbul *Pycnonotus goiavier* ២០-២០,៥ ស.ម។

មានបំពង់ក និងចិញ្ចើមធំពណ៌ស បន្ទូលក្បាលពណ៌ក្រម៉ៅ ផ្នែកគូថពណ៌លឿង។ សំលេង: ដូចពពុះទឹក ជិក-ជិក-ជិក រួចបន្តរទៅដោយ ចាវិច-ចាវិច-ចាវិច។ ទីជំរក: គុម្ពោតព្រៃ តំបន់កោះ ព្រៃកោងកាង ចំការ តំបន់កសិកម្ម តាមភូមិ និងទីក្រុង។ ឋានៈ: វត្តមានពេញមួយឆ្នាំ សំបូរគ្រប់ទីកន្លែង។ រដូវបន្តពូជ: ចាប់ពីខែ ធ្នូ ដល់ តុលា ពងចំនួន ២ ពណ៌ស។

**37 –ចចិចត្រចៀកឆ្នូត:** Streak-eared Bulbul *Pycnonotus blanfordi* ១៧-១៩ ស.ម

ផ្នែកពោះពណ៌ត្នោតខ្ចី គូថពណ៌លឿង ឆ្នូតសៗនៅគុម្ពត្រចៀក ភ្នែកសស្រអាប់។ សំលេង: វិច-វិច-វិច របៀបគំហក ហើយស្អក។ ទីជំរក: គុម្ពោតព្រៃ សួនច្បារ ដំណាំកសិកម្ម តំបន់ទីប្រជុំជនរយៈកំពស់មិនលើសពី ៩១៥ម។ ឋានៈ: វត្តមានពេញមួយឆ្នាំ មានគ្រប់ទីកន្លែង។ រដូវបន្តពូជ: ចាប់ពីខែ មករា ដល់ កញ្ញា ពងចំនួនពី ២ ទៅ ៣ ។

**38 –ចាបថ្ងូនតាខ្នងត្នោត:** Brown Shrike *Lanius cristatus* ១៩-២០ ស.ម

ផ្នែកខ្នងពណ៌ត្នោតខ្ចី បំពង់ក និងពោះស ឆ្នូតខ្មៅធំកាត់ភ្នែក អាស្រ័យតាមពូជ។ ទីជំរក: តំបន់វាលលំហរួមបញ្ចូលទាំងទីស្ងួត និងវាលស្រែ វាលភក់ ព្រៃគុម្ពោត និងតាមសួនច្បារ។
ជីវសាស្ត្រ: ចាប់សត្វល្អិត កង្កែបទុកលើដើមឈើ ដើម្បីស៊ីពេលក្រោយទៀត។ ឋានៈ: ជាប្រភេទហើរឆ្លងកាត់ និងមានគ្រប់ទីកន្លែង។





35 ពពិចត្រចៀកក្រហមស



36 ចាបក្រច



37 ពពិចត្រចៀកឆ្នូត



38 ចាបដូនតាខ្នងត្នោត

**39 -សារិកាកែវគោឬរីក:** Common Myna *Acridotheres tristis* ២៤,៥-២៧ ស.ម
ផ្ទាំងស្លាប និងដងខ្លួនពណ៌ត្នោតក្រម៉ៅ ក្បាល បំពង់ក និងផ្នែកលើទ្រូងពណ៌ប្រផេះក្រម៉ៅ ស្បែកមុខនៅជាប់ភ្នែកពណ៌លឿងភ្លឺ។ សំលេង: បី-បី ជៀកកា១១។ ទីជំរក: តំបន់វាល តំបន់កសិកម្ម ក្បែរលំនៅដ្ឋានមនុស្ស។ ជីវសាស្ត្រ: ជារឿយៗរកស៊ីតាមហ្វូងគោ ពិសេសនៅតាមវាលស្រែ។ ឋានៈ: វត្តមានពេញមួយឆ្នាំ មានសំបូរគ្រប់ទីកន្លែង។ រដូវបន្តពូជ: ពេញមួយឆ្នាំ។

**40 -សារិកាកែវក្របី ឬ រីកក្របី:** White-vented Myna *Acridotheres javanicus* ២៤,៥-២៧,៥ ស.ម
មានចំពុះលឿង មានកំប៉ោយមួយកញ្ចុំ ភ្នែកក្រហម ខ្លួនមានពណ៌ខ្មៅស្រអាប់ និងគូថពណ៌ស។ មានដៅសមួយកញ្ចុំលើស្លាប និងចុងកន្ទុយជ្រលក់ស។ សំលេង: ស្រដៀងសារិកាកែវគោ រួចបន្តរដោយ ឈូរ-ឈូរ បន្ទាប់មកស្រែក កា-កា។ ទីជំរក: តំបន់វាល ដំណាំកសិកម្ម វាលស្រែ ទីប្រជុំជន។ ឋានៈ: វត្តមានពេញមួយឆ្នាំ មានសំបូរគ្រប់ទីកន្លែង។ រដូវបន្តពូជ: ចាប់ពីខែ មេសា ដល់ សីហា។

**41 -ត្រឡឹងត្រឡោង:** Black-collared Starling *Sturnus nigricollis* ៣០,៥ ស.ម
ពេលពេញវ័យ: មាឌមធ្យម ក្បាលពណ៌សព្រាលែត មានចំកំក និងចំពុះពណ៌ខ្មៅ ពោះស។ មិនទាន់ពេញវ័យ: គ្មានចំកំកខ្មៅទេ ក្បាល និងទ្រូងពណ៌ស្រគាំ។ សំលេង: ឮខ្លាំង ហើយស្រួយ ជីវ-ជីវ-ជីវ ឬ ជីវកាល្បេង។ ទីជំរក: តំបន់វាលលំហ និងព្រៃរបោះ ព្រៃគុម្ពោត ទីប្រជុំជន ទីក្រុង។ ឋានៈ: វត្តមានពេញមួយឆ្នាំ សំបូរគ្រប់ទីកន្លែង។ រដូវបន្តពូជ: ចាប់ពីខែ កុម្ភៈ ដល់ សីហា។

**42 -ត្រឡឹងត្រឡោងត្រចៀកស:** Asian Pied Starling *Sturnus contra* ២៥ ស.ម
ជាទូទៅបក្សីមានពណ៌សខ្មៅ ត្រចៀកស គល់ចំពុះក្រហម។ ទីជំរក: តំបន់វាលលំហ ជាទូទៅក្បែរមាត់ទឹក ទីប្រជុំជន និងតំបន់ទំនាប។ ឋានៈ: វត្តមានពេញមួយឆ្នាំ សំបូរគ្រប់ទីកន្លែង។ រដូវបន្តពូជ: ចាប់ ពីខែ ឧសភា ដល់ សីហា ពងនៅក្នុងរន្ធឈើ ។

**43 -កព្រៀច:** Vinous-breasted Starling *Sturnus burmannicus* ២២-២៥,៥ ស.ម
ជាទូទៅសត្វស្លាបមានក្បាលស ឆ្នូតកាត់ភ្នែកខ្មៅ ចំពុះពណ៌លឿងលើប្រភេទ leucocephalus និងចំពុះពណ៌ក្រហមគល់ចំពុះខ្មៅ លើប្រភេទ burmannicus។ ទីជំរក: តំបន់វាលស្ងួត គុម្ពោតព្រៃ តំបន់ដំណាំកសិកម្ម។ ឋានៈ: វត្តមានពេញមួយឆ្នាំ មានសំបូរគ្រប់ទីកន្លែង។ រដូវបន្តពូជ: ចាប់ពី ខែ តុលា ដល់ វិច្ឆិកា។





39 សារិកាកែវគោ ឬ រីក

40 សារិកាកែវក្របី ឬ រីកក្របី



41 គ្រលីងត្រលោង



42 គ្រលីងគ្រលោងត្រចៀកស

43 កញ្ច្រៀច

**44 -ចាបកន្លង់**: Olive-backed Sunbird *Nectarinia jugularis* ១១,៥ ស.ម

ឈ្មោល: ខ្នងមានពណ៌បៃតងខ្ចីរលោង ថ្ងាស បំពង់ក និងដើមទ្រូងមានពណ៌ខៀវចាស់ ពោះ និងគូថពណ៌លឿង ក្រោមកន្ទុយពណ៌ស។ ឈ្មោលក្រៅរដូវបន្តពូជ: មានបំពង់កពណ៌ខៀវចាស់។ ញី: ផ្នែកពោះពណ៌លឿង ខាងក្រោមកន្ទុយពណ៌ស។ ទីជំរក: ព្រៃល្បោះ តំបន់វាលសួនច្បារ និងតំបន់កសិកម្ម ព្រៃកោងកាង និងតាមព្រៃគុម្ពោត ឆ្នេរសមុទ្រ។ ជីវសាស្ត្រ: ស៊ីលំអងផ្កា។ ស្ថានភាព: វត្តមានពេញមួយឆ្នាំ មានគ្រប់ទីកន្លែង។ រដូវបន្តពូជ: ចាប់ពីខែ ធ្នូ ដល់ កញ្ញា

**45 -ចាបកន្លង់បំពង់កត្នោតចាស់**: Brown-throated Sunbird *Anthreptes malacensis* ១៤ ស.ម

ឈ្មោល: ផ្នែកខ្នងពណ៌បៃតងភ្លឺ ផ្នែកពោះពណ៌ប្រផេះស្រាល តែបំពង់ក និងទ្រូងពណ៌ប្រផេះក្រម៉ៅជាង កន្ទុយពណ៌ត្នោតខ្ចី ថ្ងាសពណ៌បៃតងចាស់។ ញី: ថ្ងាសគ្មានពណ៌បៃតងចាស់ទេ។ ទីជំរក: ជាយព្រៃ ព្រៃកោងកាង ព្រៃជាំ ដំណុះព្រៃក្មេង គុម្ពោតព្រៃតំបន់កោះ ព្រៃចំការ និងវាលទំនាប។ស្ថានភាព: វត្តមានពេញមួយឆ្នាំមានគ្រប់ទីកន្លែង។ រដូវបន្តពូជ: ចាប់ពីខែធ្នូដល់សីហា។

**46 -ចាបកន្លង់ខ្នងក្រហម**: Scarlet-backed Flowerpecker *Dicaeum cruentatum* ៨,៥-៩ ស.ម

ឈ្មោល: ខ្នងមានពណ៌ក្រហមចាប់ពីគល់ចំពុះរហូតដល់គល់កន្ទុយ ចំហៀងក្បាល និងចំហៀងទ្រូងពណ៌ខ្មៅ ស្លាបមានពណ៌ខៀវចាស់។ ញី: ផ្នែកខ្នងពណ៌ត្នោតខ្ចីដោយចុងខ្នង និងលើគល់កន្ទុយពណ៌ក្រហម។ មិនទាន់ពេញវ័យ: គល់ចំពុះពណ៌ក្រហម ចុងខ្នង និងលើគល់កន្ទុយពណ៌លឿង។ ទីជំរក: ព្រៃល្បោះ ជាយព្រៃស្រោង តំបន់កសិកម្ម និងវាលលំហ ថែមទាំងតាមសួនច្បា កណ្ដាលទីប្រជុំជន និងទីក្រុង។ ស្ថានភាព: វត្តមានពេញមួយឆ្នាំ មានគ្រប់ទីកន្លែង។ រដូវបន្តពូជ: ចាប់ពីខែ មករា ដល់ សីហា ពងចំនួនពី ២-៣។

**47 -ចាបថ្គូនតាចិញ្ចើមលឿង**: Yellow-browed Warbler *Phylloscopus inornatus* ១១-១១,៥ ស.ម

ផ្នែកខ្នងពណ៌បៃតងភ្លឺ ដោយមានឆ្នូតសពីរធំៗកាត់ទទឹងស្លាប។ ផ្នែកពោះពណ៌សព្រឿងៗ និងមានចិញ្ចើមធំវែងពណ៌លឿង។សំឡេង: ធីស្វីអីប ធីស្វីត។ទីជំរក: ក្នុងព្រៃ ដំណុះព្រៃក្មេង ព្រៃគុម្ពោត និងគ្រប់ស្ថានភាពទាំងអស់នៃតំបន់ព្រៃឈើ។ ជីវសាស្ត្រ: រស់នៅ និងរកចំណីនៅលើចុងឈើពិបាករកមើល។ ស្ថានភាព: ជាប្រភេទហើរឆ្លងកាត់មានគ្រប់ទីកន្លែង។





44 ចាបកន្លង់



45 ចាបកន្លង់បំពង់កត្នោតចាស់



46 ចាបកន្លង់ខ្នងក្រហម



47 ចាបដូនតាចិញ្ចើមលឿង



48 ចាបស៊ីរុយកក្រហម



49 ចាបស៊ីរុយខ្នងត្នោត



50 ចាបតេត



51 ចាបដង្កូវទ្រូងប្រផេះ



52 ចាបដង្កូវលឿង





**53 -ចាបចង្រ្កង់ចុងខ្នងស:** White-rumped Munia *Lonchura striata* ១១ ស.ម
ពេញវ័យ: ផ្នែកខ្នងពណ៌ត្នោតក្រម៉ៅ ចុងខ្នង និងពោះពណ៌ស។ មិនទាន់ពេញវ័យ: ផ្នែកខ្នងពណ៌ត្នោតខ្ចី ចុង ខ្នង និងពោះពណ៌ប្រផេះស្រាល។ ទីជំរក: ដំណុះព្រៃក្មេង ព្រៃគុម្ពោត វាលស្មៅ តំបន់កសិកម្ម។ សំលេង: បន្លឺតិចៗ ដូចសំលេងសើច ពីត ពីត ពីត រួចបន្តដោយ ស្ពី.បោយី...។ ចរៈ: វត្តមានពេញមួយឆ្នាំ មានគ្រប់ទីកន្លែង។ រដូវបន្តពូជ: ពេញមួយឆ្នាំ ច្រើនធ្វើសំបុកនៅ តាមគុម្ពោតព្រៃទាបៗ។

**54 -ចាបចង្រ្កង់:** Scaly-breasted Munia *Lonchura punctulata* ១២-១២,៥ ស.ម
ផ្នែកខ្នងពណ៌ត្នោតទុំ ចុងខ្នង និងកន្ទុយពណ៌លឿង ពោះស។ ពេញវ័យទ្រូង និងចំហៀងពោះ មានរាងដូចស្រកាត្រី។ សំឡេង: សំឡេងស្ងាត់ស្រទន់រណ្តំ គីឌី គីឌី ឬ ឃីទ្ធី ឃីទ្ធី ជាពិសេស ពេលហើរ។ ទីជំរក: វាលស្រែតំបន់កសិកម្ម ព្រៃគុម្ពោត ដំណុះព្រៃក្មេង។ ចរៈ: វត្តមានពេញ មួយឆ្នាំ មានគ្រប់ទីកន្លែង។ រដូវបន្តពូជ: ពេញមួយឆ្នាំ ពងចំនួន៤-១០ ពណ៌ស។

**55 -ចាបចង្រ្កង់ក្បាលខ្មៅ:** Black-headed Munia *Lonchura malacca* បណ្តោយខ្លួន ១១-១១,៥ ស.ម
ពេញវ័យ: ខ្លួនពណ៌ត្នោតទុំ លើកលែងតែក្បាល បំពង់ក ពោះ និងគូថពណ៌ខ្មៅ ចំពុះពណ៌ ខៀវខ្ចី។ មិនទាន់ពេញវ័យ: ផ្នែកខ្នងពណ៌ត្នោតខ្ចី និងផ្នែកពោះពណ៌លឿងខ្ចី។ ចំណែកប្រភេទ ferruginosa មានក្បាលពណ៌ស បំពង់កខ្មៅ និងពោះទាំងមូលពណ៌ខ្មៅ។ ទីជំរក: វាលស្មៅ ព្រៃ គុម្ពោត វាលស្រែ។ ចរៈ: វត្តមានពេញមួយឆ្នាំ មានគ្រប់ទីកន្លែង។
រដូវបន្តពូជ: ចាប់ពីខែ ធ្នូ ដល់ តុលា។





53 ចាបចង្រង់ចុងខ្នងស



54 ចាបចង្រង់



55 ចាបចង្រង់ក្បាលខ្មៅ

**56 -ចាបស្រុក:** Plain-backed Sparrow *Passer flaveolus* ១៣,៣-១៥ ស.ម
ឈ្មោល: បន្ទលក្បាល កញ្ចឹងក និងត្រចៀកពណ៌ត្នោតខ្ចី ដើមផ្ចាំងស្លាប និងក្រោយភ្នែកពណ៌ត្នោតទុំ។ ញី: ខ្នងពណ៌ត្នោតខ្ចី និងផ្នែកពោះពណ៌លឿងខ្ចី។ ទីជំរក: តំបន់ព្រៃលំហ គុម្ពោតព្រៃ តំបន់សមុទ្រ តំបន់កសិកម្មស្ងួត ក្បែរទីប្រជុំជន និងក្បែរភូមិ។ ជីវសាស្ត្រ: រកចំណីតាមជើងភូមិ។ ចរាចរ: វត្តមានពេញមួយឆ្នាំ មានគ្រប់ទីកន្លែង។ រដូវបន្តពូជ: ពេញមួយឆ្នាំ ពងចំនួនពី ២-៤។

**57 -ចាបផ្ទះ:** Eurasian Tree Sparrow *Passer montanus* ១៤-១៤,៥ ស.ម
ឈ្មោល និងញីស្រដៀងគ្នា ថ្ពាល់ពណ៌ស ត្រចៀកមានដៅខ្មៅមួយដុំ។ បន្ទលក្បាលពណ៌ត្នោតទុំ ពោះពណ៌ត្នោតចាស់។ ទីជំរក: តាមតំបន់ទីក្រុង ទីប្រជុំជន តំបន់ដំណាំកសិកម្ម។ ជីវសាស្ត្រ: រកចំណីតាមជើងភូមិ និងទីប្រជុំជន។ ចរាចរ: វត្តមានពេញមួយឆ្នាំ មានគ្រប់ទីកន្លែង។ រដូវបន្តពូជ: ពេញមួយឆ្នាំ ពងចំនួនពី ៣-៦។

**58 -ចាបអឺរ៉ុប:** House Sparrow *Passer domesticus* ១៥ ស.ម
ឈ្មោលរដូវបន្តពូជ: បន្ទលក្បាល និងចុងខ្នងពណ៌ប្រផេះ បំពង់កខ្មៅ ចំពុះខ្មៅ។ និងរដូវមិនបន្តពូជ: ចំពុះលឿងខ្ចី បន្ទលក្បាលពណ៌ត្នោតខ្ចី។ ញី: ជាទូទៅខ្លួនមានពណ៌ត្នោតខ្ចី ចិញ្ចើម និងផ្នែក ពោះពណ៌សព្រលែត។ ទីជំរក: រស់នៅតាមទីក្រុង តាមភូមិ ដំណាំកសិកម្ម និងតំបន់វាលស្ងួត។ ចរាចរ: មិនពិតប្រាកដ។ រដូវបន្តពូជ: ពេញមួយឆ្នាំ ពងចំនួនពី ៣ ទៅ៦។

**59 -ចាបព្រៃវែង:** Yellow-breasted Bunting *Emberiza aureola* ១៥ ស.ម
ឈ្មោលរដូវបន្តពូជ: មុខ និងបំពង់កពណ៌ខ្មៅ ផ្នែកពោះពណ៌លឿង វ័ណ្ឌទ្រូងត្នោត និងមានឆ្នូតសនៅដើមស្លាប។ ឈ្មោលរដូវមិនបន្តពូជ: មានបំពង់ក និងផ្នែកពោះពណ៌លឿងទុំ និង-មានវ័ណ្ឌទ្រូងពណ៌ត្នោត មានឆ្នូតស្លាបស។ ញី: ស្រដៀងឈ្មោលនៅរដូវមិនបន្តពូជ ប៉ុន្តែគ្មានវ័ណ្ឌទ្រូងត្នោតទេ ផ្នែកពោះពណ៌លឿងខ្ចី និងផ្នែកខ្នងពណ៌ត្នោតខ្ចី។ ទីជំរក: វាលស្មៅ គុម្ពោតព្រៃ តំបន់វាលលំហ តំបន់កសិកម្ម ជាទូទៅក្បែរមាត់ទឹក។ ចរាចរ: ជាប្រភេទហើរឆ្លងកាត់ មានគ្រប់ទីកន្លែង។





56 ចាបស្រុក



57 ចាបផ្ទះ





58 ចាបអឺរ៉ុប



59 ចាបព្រៃវែង

# ប្រភេទសត្វស្លាបរស់នៅ
# តំបន់ដីសើម



Wetland Birds

**60 - ក្អែកទឹកតូច:** Little Cormorant *Phalacrocorax niger* ៥១-៥៥ ស.ម

រដូវមិនបន្តពូជ: ខ្លួនពណ៌ខ្មៅទង់ដែង មាឌតូចជាងក្អែកទឹកដទៃ កខ្លី និងចំពុះខ្លីពណ៌លឿង។ ពេលបន្តពូជ: ក្បាលមានអុជៗសពាសពេញ ចំពុះខ្មៅ។ ទីជំរក: តំបន់ដីសើមផ្សេងៗ ជាពិសេសតំបន់ទឹកសាប តែក៏មាននៅតាមមាត់សមុទ្រផងដែរ។ ជីវសាស្ត្រ: ហែលទឹកដើម្បីជ្រមុជចាប់ត្រី។ ចរាចរ: វត្តមានពេញមួយឆ្នាំ មានគ្រប់ទីកន្លែងពិសេសបឹងទន្លេសាបដែលជាបន្ទាយពងកូនយ៉ាងធំសំរាប់ប្រទេសយើង។ រដូវបន្តពូជ: ចាប់ពីខែ តុលា ដល់ មិថុនា ពងចំនួនពី ៣ ទៅ ៥។

**61 - ក្អែកទឹកមធ្យម:** Indian Cormorant *Phalacrocorax fuscicollis* ៦៤ ស.ម

ពេលមិនបន្តពូជ: ដូចក្អែកទឹកតូច ប៉ុន្តែមាឌធំជាងបន្តិច ចំពុះវែងជាង កន្ទុយវែង បំពង់កសចំពុះលឿង។ ពេលបន្តពូជ: នៅពីលើ ក្បាលមានរោមពណ៌សមួយដុំ ចំពុះខ្មៅ។ ទីជំរក: តំបន់ដីសើមផ្សេងៗ មានទឹកសាប និងទឹកប្រៃ។ ចរាចរ: វត្តមានពេញមួយឆ្នាំ បន្ទាយពងកូនធំជាងគេនៅតំបន់ព្រែកទាល់បឹងទន្លេសាប។ រដូវបន្តពូជ: ចាប់ពីខែ មករា ដល់ សីហា ពងចំនួនពី ៣ ទៅ ៦។

**62 - ក្អែកទឹកធំ:** Great Cormorant *Phalacrocorax carbo* ៨0-១00 ស.ម

ពេញវ័យរដូវមិនបន្តពូជ: មានមាឌធំជាងក្អែកទឹកដទៃ ចំពុះធំ បំពង់កលើ និងមុខពណ៌ស។ រដូវបន្តពូជ: មានរោមឆ្នូតសយ៉ាងច្រើននៅក្បាល និងគល់ចំពុះពណ៌លឿង ដៅសនៅដើមកកាន់តែធំ។ ទីជំរក: មិនទាន់ពេញវ័យ: ក្បាល ក និងពោះស្ទើរតែពណ៌ស ខ្នងប្រផេះក្រម៉ៅ។ វាលភក់រុក្ខ ជាតិ និងច្រាំងសមុទ្រ។ ចរាចរ: វត្តមានពេញមួយឆ្នាំ ភាគច្រើននៅបឹងទន្លេសាប។ រដូវបន្តពូជ: ខែតុលា ដល់ កុម្ភៈ។

**63 - ស្មោញ:** Darter *Anhinga melanogaster* ៨៥-៩៧ ស.ម។

កវែងដូចពស់ ចំពុះស្រួចដូចដាវ សំបុរពណ៌ខ្មៅ កន្ទុយវែង ឆ្នូតសវែងៗនៅផ្នែកខ្នង។ ទីជំរក: បឹង វាលភក់ ទន្លេធំៗ។ ចរាចរ: វត្តមានពេញមួយឆ្នាំ បន្ទាយពងកូនដ៏ធំនៅតំបន់ព្រែកទាល់ បឹងទន្លេសាប និងតំបន់តូចមួយចំនួននៅភាគខាងជើងនៃប្រទេស។ ជីវសាស្ត្រ: មុជទឹកចាប់ត្រីជាអាហារ។ រដូវបន្តពូជ: ចាប់ ពីខែ មិថុនា ដល់ មិនាចំនួនពងពី៤-៦។



60 ក្អែកទឹកតូច

61 ក្អែកទឹកមធ្យម

63 ស្មោញ

62 ក្អែកទឹកធំ

**64 -ក្រសាប្រផេះ:** Grey Heron *Ardea cinerea* ៩០-៩៨ ស.ម
នៅរដូវមិនបន្តពូជ: ផ្នែកខ្នងពណ៌ប្រផេះក្រម៉ៅ ក្បាល និងកពណ៌សព្រលែត បន្ទូលក្បាលមានរោមកំប៉ោយវែងពណ៌ខ្មៅ ចំពុះលឿង ផ្នែកក្រោមស្លាបមានពណ៌ខ្មៅឆ្នូតកណ្តាលប្រផេះ។ ពេលបន្តពូជ: ចំពុះពណ៌លឿងទុំ។ ទីជំរក: តំបន់ដីសើមផ្សេងៗ និងតំបន់ឆ្នេរ វាលស្រែ ព្រៃកោងកាង។ ចរាចរ: វត្តមានពេញមួយឆ្នាំមានគ្រប់ទីកន្លែង។ រដូវបន្តពូជ: ពេញមួយឆ្នាំ ពងចំនួនពី៣ទៅ៥។

**65 -ក្រសាឆ្នង់:** Purple Heron *Ardea purpurea* ៧៨-៩០ ស.ម
ពេលពេញវ័យ: បន្ទូលក្បាលខ្មៅ និងបន្តដោយកំប៉ោយវែង កវែងមានពណ៌ទឹកក្រូច និងមាន-ឆ្នូតខ្មៅចាប់ពីគល់ចំពុះតាមបណ្តោយករហូតដល់ទ្រូង ពោះ និងគែមលើផ្នែកក្រោមនៃស្លាបពណ៌ឈាមជ្រូក។ ទីជំរក: វាលភក់ រុក្ខជាតិបឹង និងទន្លេ។ ចរាចរ: វត្តមានពេញមួយឆ្នាំ ប្រភេទមិនសូវសំបូរ។ រដូវបន្តពូជ: ពេញមួយឆ្នាំ ពងចំនួនពី ៣ ទៅ ៦។

**66 -ក្រសាចំពុះធំ:** Great-billed Heron *Ardea sumatrana* ១១៤-១១៥ ស.ម
បណ្តោយខ្លួនធំ សំបុរប្រផេះក្រម៉ៅ ចំពុះធំជាងក្រសាដទៃ។ ទីជំរក: កោះនៅសមុទ្រ និងព្រៃកោងកាង ឆ្នេរដែលគ្មានការរំខាន។ ចរាចរ: វត្តមានពេញមួយឆ្នាំ ភាគច្រើនរស់នៅតំបន់ឆ្នេរ។ រដូវបន្តពូជ: ចាប់ខែ មិនា ដល់ កញ្ញា ពងចំនួន ២ ។

**67 -កុកសមុទ្រ:** Pacific Reef Egret *Egretta sacra* ៥៨ ស.ម
មាឌធំ ចំពុះ និងជើងពណ៌លឿង ខ្លួនពណ៌ស។ មួយប្រភេទទៀតខ្លួនពណ៌ខ្មៅ ចំពុះ និងជើងពណ៌លឿង។ ខុសពីកុកដទៃដោយពេលហើរលយជើងមកក្រោយខ្លីជាងកុកដទៃ។ ទីជំរក: ច្រាំងសមុទ្រដែលមានថ្ម និងកោះតូចៗ ឆ្នេរខ្សាច់។ ជីវភាពគ្រួ: ជាទូទៅវាហើរតែមួយ ឬ មួយគូរប៉ុណ្ណោះ។ ចរាចរ: វត្តមានពេញមួយឆ្នាំ ជាប្រភេទមានដោយកំរ។ រដូវបន្តពូជ: ចាប់ពីខែឧសភា ដល់ ធ្នូ ពងចំនួនពី ៣ ទៅ ៥។

# ប្រភេទសត្វស្លាបរស់នៅតំបន់ដីសើម



**68 -កុកគ្រោងធំ:** Great Egret *Egretta alba* ៨៥-១០២ ស.ម

រដូវមិនបន្តពូជ: ជាកុកធំជាងគេ កវែងដូចពស់ហើយកួក់ ចំពុះលឿងវែងស្រួច ជើងខ្មៅ។ រដូវបន្តពូជ: ជង្គង់ពណ៌ផ្កាឈូក ស្មងជើង និងម្រាមខ្មៅ ចំពុះខ្មៅ។ ទីជំរក: វាលភក់រុក្ខជាតិ បឹង វាលស្រែ ព្រមទាំងព្រៃកោងកាង និងតំបន់ឆ្នេរ។ ឋានៈ: វត្តមានពេញមួយឆ្នាំ មិនសូវសំបូរ។ រដូវបន្តពូជ: ចាប់ពី ខែ មិថុនា ដល់ តុលា ពងចំនួនពី ៣ ទៅ ៤។

**69 -កុកគ្រោងមធ្យម:** Intermediate Egret *Egretta intermedia* ៦៥-៧២ ស.ម

រដូវមិនបន្តពូជ: ខុសប្លែកពីកុកគ្រោងធំដោយចំពុះខ្លីហើយទាល កខ្លីជាង ជើងខ្មៅ ចំពុះលឿង និងមានអុជខ្មៅនៅចុងចំពុះ។ ពេលបន្តពូជ: ចំពុះលើរាងក្រម៉ៅ រោមបះៗនៅដើមទ្រូង និងកន្ទុយ។ ទីជំរក: តំបន់ដីសើមផ្សេងៗ មានវាលភក់រុក្ខជាតិ និងវាលស្រែ។ ឋានៈ: វត្តមានពេញមួយឆ្នាំ មិនសូវសំបូរ។ រដូវបន្តពូជ: ចាប់ពីខែ មិថុនា ដល់ កញ្ញា ពងចំនួនពី ៣ ទៅ ៥។

**70 -កុកគ្រោងតូច:** Little Egret *Egretta garzetta* ៥៥-៦៥ ស.ម

រដូវមិនបន្តពូជ: ដងខ្លួនទាំងមូលពណ៌ស ចំពុះខ្មៅ ជើងខ្មៅ ប្រអប់ជើង និងម្រាមពណ៌លឿង។ ពេលបន្តពូជ: ក្បាលមានកំប៉ោយរោមវែងពីរសរសៃ រោមទ្រូង និងកន្ទុយបះជ្រោង មានដៅក្រហមនៅដើមភ្នែកតល់ចំពុះ ប្រអប់ជើង និងម្រាមពណ៌ក្រហម។ ទីជំរក: វាលភក់រុក្ខជាតិ វាលស្រែ តាមដំណាំកសិកម្ម និងតំបន់ឆ្នេរ។ ឋានៈ: វត្តមានពេញមួយឆ្នាំ មានគ្រប់ទីកន្លែង និងសំបូរបំផុត។ រដូវបន្តពូជ: ចាប់ពីខែ មិថុនា ដល់ សីហា ពងចំនួនពី ៣ ទៅ ៥។

**71 -កុកគោ:** Cattle Egret *Bubulcus ibis* ៤៨-៥៣ ស.ម

នៅរដូវមិនបន្តពូជ: ដងខ្លួនទាំងមូលពណ៌ស មានកខ្លីធំត្រង់គល់ក និងចំពុះខ្លីជាងកុកផ្សេងៗទៀត និងជើងខ្លី។ រដូវបន្តពូជ: ក្បាល ក ទ្រូង និងចុងខ្នងមានពណ៌ត្នោតទុំ។ ទីជំរក: តំបន់ដីសើមផ្សេងៗ ដំណាំកសិកម្ម។ ឋានៈ: វត្តមានពេញមួយឆ្នាំ មានសំបូរគ្រប់ទីកន្លែង។ រដូវបន្តពូជ: ចាប់ពីខែ មេសា ដល់មិថុនា ពងចំនួនពី ៣ ទៅ ៥។

**72 -កុកក្រកក្បាលត្នោតខ្ចី:** Javan Pond-Heron *Ardeola speciosa* ៤៥ ស.ម

នៅរដូវមិនបន្តពូជ: មានលក្ខណៈដូចគ្នានឹងកុកក្រកចិនដែរ (Chinese Pond-Heron) ប៉ុន្តែចុងស្លាបទី១មិនមានពណ៌ខ្មៅដូច កុកក្រកចិនទេ។ នៅរដូវបន្តពូជ: ក្បាល ក និងទ្រូងពណ៌ទឹកក្រូចចាស់ ខ្នងខ្មៅ ពោះស។ ទីជំរក: តំបន់ដីសើមផ្សេងៗ ជាពិសេសតាមតំបន់ឆ្នេរ និងតំបន់វាលទំនាប។ ឋានៈ: វត្តមានពេញមួយឆ្នាំ មានគ្រប់ទីកន្លែង។ រដូវបន្តពូជ: ចាប់ពីខែ មិថុនា ដល់ កញ្ញា ពង ចំនួនពី ៣ ទៅ ៥។



68 កុកគ្រាងធំ



69 កុកគ្រាងមធ្យម



70 កុកគ្រាងតូច



71 កុកគោ



72 កុកក្រកក្បាលត្នោតខ្ចី

**73-កុកខ្មៅ ឬ ថ្លើមអណ្តើក**: Black Bittern *Bupetor flavicollis* ៥៤-៦១ ស.ម
ឈ្មោល: ខ្លួនមានពណ៌ខ្មៅ មានឆ្នូត១សជាជួរនៅដើមទ្រូង មានដៅពណ៌លឿងនៅគុម្ពត្រចៀក។ ញី: ខ្លួនមានពណ៌ត្នោតទុំ គុម្ពត្រចៀកលឿងដូចឈ្មោលដែរ។ ទីជម្រក: វាលភក់រុក្ខជាតិ វាលស្រែ និងព្រៃកោងកាង ព្រៃជាំ។ ចរាចរ: វត្តមានពេញមួយឆ្នាំ ជាប្រភេទកំរ។ រដូវបន្តពូជ: ចាប់ពីខែ មិថុនា ដល់ កញ្ញា ពងចំនួនពី ៣ ទៅ ៥។

**74-ខ្វែក**: Black-crowned Night Heron *Nycticorax nycticorax* ៥៨-៦៥ ស.ម
ពេញវ័យ: ចំពុះ ក្បាល និងខ្នងពណ៌ខ្មៅ ភ្នែកក្រហម ក និងទ្រូងពណ៌ស ស្លាបប្រផេះចាស់។ ពេលមិនទាន់ពេញវ័យ: ខ្លួនទាំងមូលពណ៌ត្នោតលាយអុជ១ស។ ទីជម្រក: វាលភក់រុក្ខជាតិវាលស្រែព្រៃកោងកាង។ ជីវសាស្ត្រ: រកស៊ីពេលយប់ និងរស់នៅកន្លែងគុម្ពោតស្ងាត់ពេលថ្ងៃ។ ចរាចរ: វត្តមានពេញមួយឆ្នាំ មានគ្រប់ទីកន្លែង។ រដូវបន្តពូជ: ចាប់ពីខែ មិនា ដល់ មករា ពងចំនួនពី ៣ ទៅ ៥។

**75-ក្រអាច់ ឬ ក្រសាស្វាយ**: Little Heron *Butorides striatus* ៤៦ ស.ម
ពេញវ័យ: រាងដូចខ្វែកប៉ុន្តែមាឌតូចជាង ស្លាបពណ៌ប្រផេះក្រម៉ៅ បន្ទួលក្បាលខ្មៅ ជើងពណ៌ទឹកក្រូច។ មិនទាន់ពេញវ័យ: សំបុរពណ៌ត្នោតចាស់ អុជ១សផ្នែកពោះ។ ទីជម្រក: វាលភក់ និងព្រៃកោងកាង តំបន់កោះ ស្ទឹង បឹង។ ចរាចរ: វត្តមានពេញមួយឆ្នាំ មានគ្រប់ទីកន្លែង។ រដូវបន្តពូជ: ពេញមួយឆ្នាំ ពងចំនួន ពី ៣ ទៅ ៥។

**76-កុកសំបកត្រពាំង**: Yellow Bittern *Ixobrychus sinensis* ៣៦-៣៨ស.ម
ខ្លួនពណ៌សំបកត្រពាំង រាងដូចកុកម្ទេសទុំ បន្ទួលក្បាលខ្មៅ ពេលហើរស្លាបទី១ ស្លាបទី២ និងកន្ទុយពណ៌ខ្មៅ។ ទីជម្រក: វាលស្មៅ ត្រែងខ្ពស់ៗ តំបន់វាលភក់រុក្ខជាតិ ជួនកាលមាននៅតាមវាលស្រែផងដែរ។ ចរាចរ: វត្តមានពេញមួយឆ្នាំ សំបូរភាគច្រើននៅតំបន់បឹងទន្លេសាប។ រដូវបន្តពូជ: ចាប់ពីខែ មិនា ដល់ វិច្ឆិកា ។

**77-កុកម្ទេសទុំ**: Cinnamon Bittern *Ixobrychus cinnamomeus* ៣៨-៤១ ស.ម
ឈ្មោល: ខ្លួនទាំងមូលពណ៌ច្រែះ មានរោមទ្រូងក្រាស់។ ញី: មានពណ៌ស្រអាប់ មានឆ្នូតសជាជួរនៅផ្នែកពោះ និងឆ្នូតពណ៌ច្រែះនៅផ្នែកខ្នង។ ទីជម្រក: ស្មៅខ្ពស់ៗនៃតំបន់វាលភក់រុក្ខជាតិ វាលស្រែស្រះ។ ចរាចរ: វត្តមានពេញមួយឆ្នាំ មានគ្រប់ទីកន្លែង។ រដូវបន្តពូជ: ពេញមួយឆ្នាំ ពងចំនួនពី ៣ ទៅ ៥។





73 កុកខ្មៅ ឬ ថ្មើមអណ្តើក

74 ខ្វែក

75 ក្រអាច់ ឬ ក្រសាស្វាយ

76 កុកសំបកត្រពាំង

77 កុកម្ទេសទុំ

**78 -ត្រដក់ធំ:** Greater Adjutant *Leptoptilos dubius* ១៤៥-១៥០ ស.ម

បណ្តោយខ្លួនធំ ឆ្នូតបណ្តោយកណ្តាលផ្ទាំងស្លាបលើពណ៌សប្រផេះ ស្មាមានរោមស និងមានថង់យាមមួយនៅក។ ពេលបន្តពូជ: មានដៅខ្មៅនៅគល់ចំពុះត្រង់ថ្ងាស។ ទីជំរក: ព្រៃរនាម (ព្រៃលិចទឹកតាមរដូវ) តំបន់ដីសើម និងព្រៃល្បោះស្ងួត។ ឋានៈ: វត្តមានពេញមួយឆ្នាំ មានបន្ទាយពងកូនយ៉ាងធំនៅតំបន់ព្រែកទាល់បឹងទន្លេសាប របាយបង្គួរហើយកំពុងរងការគំរាមកំហែងដោយការទាក់ចាប់យ៉ាងខ្លាំងនៅទូទាំងប្រទេស។ រដូវបន្តពូជ: ចាប់ពីខែ តុលា ដល់ មិនា។

**79 -ត្រដក់តូច:** Lesser Adjutant *Leptoptilos javanicus* ១២២-១២៩ ស.ម

មាឌតូចជាងត្រដក់ធំ ស្លាបខ្មៅទាំងលើទាំងក្រោម និងគ្មានថង់យាម។ ពេលបន្តពូជ: ស្បែកក្បាលឡើងក្រហម។ ទីជំរក: ព្រៃរនាម (ព្រៃ លិចទឹកតាមរដូវ) ព្រៃកោងកាង និងវាលភក់។ ឋានៈ: វត្តមានពេញមួយឆ្នាំ មានគ្រប់ទីកន្លែង ជាពិសេសបឹងទន្លេសាបដែលជាសំបុកពងកូនយ៉ាងធំរបស់វា និងមានបន្ទាយពងកូនមួយចំនួននៅខេត្តព្រះវិហារផងដែល។ រដូវបន្តពូជ: ចាប់ពីខែ តុលា ដល់ មិថុនា ពងចំនួនពី ២ ទៅ ៤ ។

**80 -អង្កត់ខ្មៅ ឬ ចំបង់ក្រញ្ចង់:** Black-necked Stork *Ephippiorhychus asiaticus* ១២១-១៣៥ ស.ម

ពេញវ័យ: មាឌធំ ចំពុះធំវែងខ្មៅ និងជើងវែងក្រហម ដងខ្លួនស តែចុងខ្នងដល់កន្ទុយខ្មៅ ឆ្នូតកណ្តាលស្លាបពណ៌ខ្មៅ ក្បាល និងកខ្មៅ ភ្នែកលឿងចាំង។ ញី: រូបរាងដូចឈ្មោលដែរ តែភ្នែកពណ៌ត្នោត។ ទីជំរក: ព្រៃលិចទឹក ព្រៃតាមទន្លេ និងតំបន់ដីសើមក្នុងព្រៃល្បោះ។ ជីវសាស្ត្រ: ច្រើនរកស៊ីនៅតែឯកឯង។ ឋានៈ: វត្តមានពេញមួយឆ្នាំ មានគ្រប់ទីកន្លែង ជាប្រភេទកំរ។ រដូវបន្តពូជ: ចាប់ពីខែ តុលា ដល់ មិនា ពងចំនួនពី ៣ ទៅ ៥។

**81 -ក្រៀល:** Sarus Crane *Grus antigone* ១៥២-១៥៦ ស.ម

ខ្លួនធំហើយខ្ពស់ សំបុរសប្រផេះ ក្បាលត្រងោលក្រហមដោយមានបន្ទួលក្បាលប្រផេះ និងជើងក្រហមវែង ចំពុះវែងត្រង់ ស្លាបទី១ពណ៌ខ្មៅ។ ទីជំរក: ទំនាបលិចទឹក វាលស្រែ តាមតំបន់វាលស្មៅក្នុងព្រៃរបោះ។ ជីវសាស្ត្រ: រដូវប្រាំងរក ស៊ីជាហ្វូង រដូវវស្សាបន្តពូជតែឯកឯង។
ឋានៈ: វត្តមានពេញមួយឆ្នាំ មាននៅភាគខាងជើងបឹងទន្លេសាបជាពិសេសខេត្តបន្ទាយមានជ័យ និងតាកែវ រដូវវស្សាបន្តពូជចាប់ពីខេត្តបាត់ដំបង ព្រះវិហារ ដល់ខេត្តមណ្ឌលគិរី។ រដូវបន្តពូជ: ចាប់ពី ខែ មិនា ដល់ តុលា ពងចំនួនពី ១ ទៅ ៣។



78 ត្រដក់ធំ



79 ត្រដក់តូច



80 អង្កត់ខ្មៅ ឬ ដិបងក្រញូង

81 ក្រៀល

**82 –រនាលពណ៌:** Painted Stork *Mycteria leucocephala* ៩៣-១០២ ស.ម

ខ្លួនពណ៌ស ស្លាបទី១ និងទី២ពណ៌ខ្មៅ ចុងខ្នងពណ៌ផ្កាឈូក វ៉ែណ្ឌខ្មៅលើដើមទ្រូង ចំពុះធំវែងលឿងកោងខុបចុះបន្តិច។ ពេលបន្តពូជ: ស្បែកក្បាលឡើងក្រហម ចំពុះពណ៌ផ្កាឈូក។ ទីជំរក: ទំបន់ដីសើមផ្សេងៗ ព្រៃលិចទឹក និងទំនាបលិចទឹក។ ជីវសាស្ត្រ: ចូលចិត្តរស់នៅ និងរកចំណីទាំងហ្វូងៗ។ ចរាចរ: វត្តមានពេញមួយឆ្នាំមានបន្ទាយពងកូនដ៏ធំនៅបឹងទន្លេសាបនៅរដូវប្រាំង រដូវវស្សានៅតាមតំបន់ទំនាប។ រដូវបន្តពូជ: ចាប់ពីខែ វិច្ឆិកា ដល់ ឧសភា ពងចំនួនពី ២ ទៅ ៥។

**83 –រនាលស:** Milky Stork *Mycteria cinerea* ៩២-៩៧ ស.ម

ដងខ្លួនពណ៌ស ស្លាបហើរទី១ និងទី២ពណ៌ខ្មៅ មុខពណ៌ក្រហម ចំពុះលឿងខ្ចីវែងខុបបន្តិច ជើងពណ៌ផ្កាឈូក ស្បែកមុខពណ៌ក្រហមចាស់។ ពេលបន្តពូជ: ចំពុះពណ៌លឿងចាំង ស្បែកមុខក្រហមចាំង ដងខ្លួនពណ៌ទឹកដោះគោ។ ទីជំរក: វាលភក់នៃតំបន់ទឹកជោនាច ព្រៃលិចទឹក និងព្រៃកោងកាង ។ ចរាចរ: វត្តមានពេញមួយឆ្នាំ មានដោយកន្លែង ពិសេសតាមតំបន់ឆ្នេរ។ រដូវពងកូន: ចាប់ពីខែ សីហា ដល់ ធ្នូ ចំនួនពងពី ៣ ទៅ ៤។

**84 –ចង្កៀលខ្យង:** Asian Openbill *Anastomus oscitans* ៦៨-៨១ ស.ម

មាឌធំ ចំពុះមានប្រហោង ខ្លួនពណ៌ស ស្លាបហើរទី១ ទី២ និងកន្ទុយពណ៌ខ្មៅ។ ទីជំរក: ព្រៃលិចទឹក វាលលិចទឹក វាលស្រែលិចទឹក។ ជីវសាស្ត្រ: ជាទូទៅស៊ីខ្យងជាអាហារ និងរកស៊ីជាហ្វូង។ ចរាចរ: វត្តមានពេញមួយឆ្នាំ សំបូរភាគច្រើននៅតំបន់ជុំវិញបឹងទន្លេសាប ពងកូននៅតំបន់ព្រៃកទាល់។ រដូវបន្តពូជ: ចាប់ពីខែ តុលា ដល់ មេសា ពងចំនួនពី ២ ទៅ ៥។

**85 –សត្វកស ឬ ត្រុំ ឬកុកចាក់អំបោះ:** Woolly-necked Stork *Ciconia episcopus* ៧៥-៩១ ស.ម

ខ្លួនទាំងមូលខ្មៅរលោង លើកលែងតែ ក ក្រោមពោះ និងក្រោមកន្ទុយពណ៌ស។ ទីជំរក: ទំនាបលិចទឹក និងតំបន់ដីសើមក្នុងព្រៃល្បោះ។ ចរាចរ: វត្តមានពេញមួយឆ្នាំ មានគ្រប់ទីកន្លែង។ កន្លែងពងកូនធំជាងគេនៅព្រែកទាល់បឹងទន្លេសាប។ រដូវបន្តពូជ: អាចចាប់ពី ខែ កុម្ភៈ ដល់ ឧសភា និងចាប់ពីខែ សីហា ដល់ វិច្ឆិកា អាស្រ័យទៅលើរីយរបស់វា។

# ប្រភេទសត្វស្លាបរស់នៅតំបន់ដីសើម



82 រនាលពណ៌

83 រនាលស

84 ចង្កៀលខ្យង

85 សត្វកស ឬ ត្រុំ ឬ កុកពាក់អំបោះ

**86 -ត្រយ៉ងខ្លួនស:** Black-headed Ibis *Threskiornis melanocephalus* ៧៥-៧៦ ស.ម
មាឌធំ ខ្លួនពណ៌ស ក ក្បាល និងជើងពណ៌ខ្មៅ ចំពុះកោងវែងពណ៌ខ្មៅ។ ទីជំរក: ព្រៃលិចទឹក ព្រៃកោងកាង។ ស្ថានភាព: វត្តមានពេញមួយឆ្នាំ សំបូរនៅបឹងទន្លេសាប និងតំបន់ជុំវិញបឹង។ រដូវបន្តពូជ: ចាប់ពីខែ តុលា ដល់ មេសា ពងចំនួនពី ២ ទៅ ៤។

**87 -ត្រយ៉ងចំកំកស:** White-shouldered Ibis *Pseudibis davisoni* ៧៥-៨៥ ស.ម
ខ្លួនពណ៌ខ្មៅរលោង ចំកំកស ជើងវែងក្រហមមានដៅសមួយដុំនៅលើស្មា (ពេលហើរទើបឃើញច្បាស់)។ ទីជំរក: ព្រៃ តាមទន្លេ តំបន់ដីសើមក្នុងព្រៃល្បោះ និងតំបន់ដីសើមតាមវាលទំនាប។ ស្ថានភាព: វត្តមានពេញមួយឆ្នាំ ស្ថានភាព: ខេត្តព្រះវិហារ ស្ទឹងត្រែង ភាគច្រើននៅភាគខាងជើងនៃប្រទេស។ រដូវបន្តពូជ: ចាប់ពីខែ កុម្ភៈ ដល់ ឧសភា ពងចំនួនពី ៣ ទៅ ៤។

**88 -ត្រយ៉ងយក្ស ឬ ឌំលើក:** Giant Ibis *Pseudibis gigantea* ១០២-១០៦,៥ស.ម
មាឌធំ សំបុរក្រម៉ៅប្រផេះ ជើងវែងក្រហម ក្បាល និងកមួយផ្នែកត្រងោលពណ៌ប្រផេះ និងមានឆ្នូតអង្កន់ៗខ្មៅ ចំពុះវែងកោងខុប។ ទីជំរក: ព្រៃរបោះ ព្រៃលិចទឹក និងតំបន់ដីសើម។ ជីវសាស្ត្រ: ជាសត្វជិតផុតពូជ រស់នៅក្នុងទីស្ងាត់កំបាំង ចូលចិត្តយំពេលព្រឹកព្រលឹម និងពេលល្ងាចព្រលប់។ ស្ថានភាព: វត្តមានពេញមួយឆ្នាំ របាយភាគច្រើននៅភាគខាងជើងនៃប្រទេសខេត្តព្រះវិហារ មណ្ឌលគីរី និងជាពិសេសខេត្តស្ទឹងត្រែង។ល។ រដូវបន្តពូជ: តាមការអង្កេតស្តែង ចាប់ពីខែមិថុនា ដល់ កញ្ញា ពងភាគច្រើនពី១-២។

**89 -ត្រយ៉ងខ្លួនរលោង:** Glossy Ibis *Plegadis falcinellus* ៥៥-៦៥ ស.ម
នៅរដូវមិនបន្តពូជ: មាឌតូចជាងត្រយ៉ងដទៃ ខ្លួនមានពណ៌ប្រផេះក្រម៉ៅ ស្លាបពណ៌ស្លាបកំភែន ជើងពណ៌ដី ក្បាល និងកមានអុជៗ ស។ ពេលបន្តពូជ: ក្បាល ក និងដងខ្លួនពណ៌កាហ្វេ បន្ទូលក្បាលពណ៌បៃតង។ ទីជំរក: តំបន់វាលភក់ រុក្ខជាតិ។ ស្ថានភាព: វត្តមានពេញមួយឆ្នាំ កំណត់ត្រាកន្លងមកតាមដងស្ទឹងសេសានខេត្តស្ទឹងត្រែង។ រដូវបន្តពូជ: ចាប់ពីខែ តុលា ដល់ កុម្ភៈ ពងចំនួនពី ២ ទៅ ៣។



86 ត្រយ៉ងខ្លួនស



87 ត្រយ៉ងចំកំកស



88 ត្រយ៉ងយក្ស ឬ ឱលើក



89 ត្រយ៉ងខ្លួនរលោង

**90 -ប្រវិក**: Lesser Whistling Duck *Dendrocygna javanica* ៣៨-៤១ ស.ម

ញី និងឈ្មោលមានរូបរាងដូចគ្នា ជាពួកទាដែលមានមាឌមធ្យម បន្ទូលក្បាលពណ៌ត្នោតចាស់ ផ្នែកខ្នងមានពណ៌ក្រម៉ៅចំរុះលឿង និងត្នោត ផ្នែកទ្រូងមានពណ៌ត្នោតទុំ។ ទីជំរក: វាលលិចទឹក តំបន់វាលភក់ និងបឹង។ ជីវសាស្ត្រ: រកស៊ីពេលយប់ជាហ្វូងៗ ពិសេសស៊ីស្រូវ រកស៊ីពេលថ្ងៃនៅតាមបឹងបួរធំៗ។ ចរាចរ: វត្តមានគ្រប់រដូវ នៅមានសំបូរ។ រដូវបន្តពូជ: ពេញមួយឆ្នាំ។

**91 -ទាព្រៃក្បាលឆ្នូតស**: Garganey *Anas querquedula* ៣៦-៤១ ស.ម

ពពួកទាដែលមានមាឌតូចមាំ ចំពុះប្រផេះជាំ។ ឈ្មោល: ក្បាលពណ៌ត្នោតចាស់ មានចិញ្ចើមសធំ ស្លាបមានពណ៌ប្រផេះស្រាល និងមានស្លាបឆ្នុះពណ៌ខៀវចាំង។ ញី: គ្មានចិញ្ចើមសទេ និង-មានឆ្នូតខ្មៅកាត់តាមភ្នែក និងក្រោមភ្នែកស្របគ្នា ផ្នែកខ្នងមានពណ៌ប្រផេះ និងមានពណ៌សនៅខាង ចុងរោម។ ទីជំរក: វាលភក់ រុក្ខជាតិ បឹង ស្រះ និងតំបន់ដីសើមផ្សេងៗ ទៀត។ ចរាចរ: មិនសូវសំបូរ វត្តមាននៅរដូវប្រាំង។

**92 -ទាកាបព្រៃ**: Spot-billed Duck *Anas poecilorhyncha* ៥៥-៦៣ស.ម

ដូចទាស្រុក ឈ្មោល: ចំពុះខ្មៅ និងចុងចំពុះលឿង មានអុជក្រហមនៅគល់ចំពុះផ្នែកក្រោមថ្ងាស ក្បាលពណ៌សព្រលែត ដែលមានបន្ទូលក្បាលខ្មៅ និងមានឆ្នូតខ្មៅកាត់តាមភ្នែក ទ្រូង និងចំហៀងទ្រូងមានអុជៗខ្មៅ មានស្លាបឆ្នុះពណ៌បៃតង ដែលព័ទ្ធជុំវិញដោយតែមពណ៌ស ហើយបន្តទៅស្លាបទីបី ផ្នែកក្រោមស្លាបមានពណ៌ស និងឆ្នូតពណ៌ខ្មៅ។ ញី: មានមាឌតូចជាងឈ្មោល គ្មានអុជក្រហមនៅគល់ចំពុះ នៅទ្រូង និងចំហៀងទ្រូងមានអុជៗ ខ្មៅតិចជាងឈ្មោល។ ទីជំរក: តំបន់ដីសើម បឹង និងទន្លេធំៗ ជាទូទៅច្រើនហើរជាគូរ ឬ ជាហ្វូងតូចៗ។ ចរាចរ: មានគ្រប់ទីកន្លែង ពិសេសនៅតំបន់ជាប់បឹងទន្លេសាប។ រដូវបន្តពូជ: ពេញមួយឆ្នាំ រយ:កំពស់៨00មចុះ។

**93 -ទាកាច់ព្រៃ**: Comb Duck *Sarkidiornis melanotos* ៥៦-៧៦ ស.ម។

ឈ្មោល: ក្បាល និងកពណ៌សដែលមានអុជៗ ខ្មៅពាសពេញ ផ្នែកពោះពណ៌ស និងចំហៀងខ្លួនពណ៌ប្រផេះ ចំពុះខ្មៅដែលមានសិរមួយកញ្ចុំពីលើ ស្លាបក្រោមខ្មៅទាំងអស់ ស្លាបលើពណ៌ខៀវចាស់។ ពេលបន្តពូជ: ក្បាលគ្មានសិរពីលើទេ។ ទីជំរក: ព្រៃលិចទឹក និងតំបន់ដីសើមវាលទំនាប។ ជីវសាស្ត្រ: ជាទូទៅច្រើនហើរមួយគូរ ឬ ហ្វូងតូចៗ។ ចរាចរ: វត្តមានពេញមួយឆ្នាំភាគច្រើនតំបន់ជុំវិញបឹងទន្លេសាប។ រដូវបន្តពូជ: ចាប់ពីខែ មិថុនា ដល់ កញ្ញា។

**94 -ទាព្រៃស្លាបស**: White-winged Duck *Cairina scutulata* ៦៦-៨១ ស.ម

ឈ្មោល: មាឌធំ ដងខ្លួនជាទូទៅពណ៌ត្នោតចាស់ ក្បាល និងកពណ៌សលាយខ្មៅពព្លាក់ ចំពុះលឿងជាំ។ ក្នុងសភាពហើរតែមស្លាបលើពណ៌សឆ្នុះ។ ញី: មានមាឌតូចជាងឈ្មោល និងមានពណ៌ស្រដៀងឈ្មោលដែរ។ ទីជំរក: តាមបឹង អូរ ក្នុងព្រៃស្រោង ព្រៃជាំ។ ចរាចរ: វត្តមានពេញមួយឆ្នាំ វត្តមានភាគច្រើននៅភាគខាងជើងប្រទេស។

រដូវបន្តពូជ: ចាប់ពីខែ មីនា ដល់ កញ្ញា ។



90 ប្រវឹក



91 ទាព្រៃក្បាលឆ្នូតស



92 ទាកាបព្រៃ



93 ទាកាប៉ាព្រៃ



94 ទាព្រៃស្លាបស

**95 -ប្រវែក**: Cotton Pygmy-goose *Nettapus coromandelianus* ៣៣-៣៨ ស.ម
ឈ្មោល: មានក្បាល និងកពណ៌ស បន្ទួលក្បាលខ្មៅ ផ្នែកខ្នង និងចំកំកមានពណ៌បៃតងជាំ ឆ្នូតសពែមក្រោមនៃស្លាប ។ ញី: ក្បាល និងកពណ៌សព្រលែត បន្ទួលក្បាល និងឆ្នូតកាត់តាមភ្នែកពណ៌ខ្មៅ ស្លាបបៃតង ។ ទីជំរក: ស្រះ បឹង វាលភក់ទឹកសាប ។ របាយ: វត្តមានពេញមួយឆ្នាំ មានគ្រប់ទឹកន្លែង ។ រដូវបន្តពូជ: ចាប់ពីខែ មិថុនា ដល់ សីហា ។

**96 -ពពុះទឹក**: Little Grebe *Tachybaptus ruficollis* ២៥-២៩ ស.ម
រាងដូចសត្វទាប៉ុន្តែតូចល្អិត ផ្នែកខ្នងពណ៌ប្រផេះត្នោត ចំពុះស្រួចស្តើងមើលទៅហាក់ដូចជាគ្មានកន្ទុយ ។ រដូវមិនបន្តពូជ: ឈ្មោល និងញីមានថ្ពាល់ ក និងផ្នែកពោះមានពណ៌ត្នោតខ្ចី ចំពុះលឿងខ្ចី ផ្នែកខ្នងមានពណ៌ក្រម៉ៅជាំ ។ នៅរដូវបន្តពូជ: ឈ្មោល និងញី បន្ទួលក្បាល កញ្ចឹងក និងផ្នែកខ្នងមានពណ៌ខ្មៅ ភ្នែកលឿង ។ ទីជំរក: ត្រពាំង បឹង តំបន់វាលភក់ ។ របាយ: វត្តមានពេញមួយឆ្នាំ មានគ្រប់ទឹកន្លែង ។ ជីវសាស្ត្រ: មុន និងហើរទទះស្លាប ខ្លាំង១រួចហើរពីលើផ្ទៃទឹកជាមុនសិន ។ រដូវបន្តពូជ: ចាប់ពីខែ មេសា ដល់ កុម្ភៈ សំបុកអណ្តែតលើទឹកពងចំនួនពី ៣-៧ ។

**97 -មាន់ទឹកខ្មៅ**: Common Moorhen *Gallinula chloropus* ៣០-៣៥ ស.ម
ពេលពេញវ័យ: បណ្តោយខ្លួនប៉ុនមាន់ទឹក សម្បុរខ្មៅស្រអាប់ ក្រោមកន្ទុយ និងផ្នែកចំហៀងពោះពណ៌ស ចំពុះក្រហម ចុងចំពុះលឿង និងមានសិរក្រហមនៅថ្ងាស ។ ចំណែកសត្វមិនទាន់ពេញវ័យ : ខ្លួនពណ៌ប្រផេះលាយលឿងព្រឿង១ ចំពុះលឿង ។ ទីជំរក: រស់នៅតាមត្រពាំង បឹង តំបន់ដីសើម វាលស្រែលិច ទឹក ។ របាយ: វត្តមានគ្រប់រដូវ និងមានគ្រប់ទឹកន្លែង ។ រដូវបន្តពូជ: ពេញមួយឆ្នាំ ពងចំនួនពី៤-១៤ ។

**98 -មាន់ទឹក**: White-breasted Waterhen *Amaurormis phoenicurus* ២៨,៥-៣៦ ស.ម
ចាប់ពីបន្ទួលក្បាល និងផ្នែកខ្នងមានពណ៌ខ្មៅស្រអាប់ ផ្នែកមុខ ទ្រូង និងពោះមានពណ៌សផ្នែកគូថមានពណ៌ត្នោតទុំ ចំពុះ និងជើងពណ៌លឿង ។ ទីជំរក: រស់តាមតំបន់ដីសើមគ្រប់ប្រភេទ និងក្បែរព្រៃកោងកាង ។ របាយ: វត្តមានពេញមួយឆ្នាំ មានគ្រប់ទឹកន្លែង ។ រដូវបន្តពូជ: ពេញមួយឆ្នាំ ពងចំនួនពី ៣-៨ ។

**99 -កាត្រែត**: Ruddy-breasted Crake *Porzana fusca* ២១-២៦,៥ស.ម
ពេញវ័យ: ខ្នងពណ៌ត្នោតចាស់ ក្បាល ក ទ្រូង និងពោះពណ៌ត្នោតទុំ ផ្នែកគូថអង្កន់ឆ្នូតស ជើងក្រហម ចំពុះខ្មៅ គល់ចំពុះបៃតង ។ មិនទាន់ពេញវ័យ: ពណ៌ស្រអាប់ ផ្នែកពោះខ្មៅអង្កន់ឆ្នូតស ស្លាបខ្មៅ ។ ទីជំរក: តាមទឹកតំបន់វាលទំនាប គុម្ពព្រែងលិចទឹក ។ របាយ: វត្តមានពេញមួយឆ្នាំ មានគ្រប់ទឹកន្លែង ។ រដូវបន្តពូជ: ចាប់ពីខែ កុម្ភៈ ដល់ មិថុនា ។

# ប្រភេទសត្វស្លាបរស់នៅតំបន់ដីសើម



95 ប្រវើក



96 ពពុះទឹក



97 មាន់ទឹកខ្មៅ



98 មាន់ទឹក



99 កាត្រែត

**100 -ខ្វូលទឹក**: Masked Finfoot *Heliopais personata* ៥២-៥៤,៥ ស.ម
មាឌធំរាងដូចក្ងាន សំបុរត្នោត ចំពុះធំលឿងស្រួច ផ្នែកខ្នងពណ៌ប្រផេះជាំ។ ឈ្មោល: កខ្មៅឆ្នូតស។ ញី: កសឆ្នូតខ្មៅ។ ទីជំរក: ព្រៃតាមទន្លេ ព្រៃលិចទឹក និងព្រៃកោងកាង។ ជីវសាស្ត្រ: រស់នៅ ក្នុងសភាពសាត់ជ្រង។ ចរាចរ: វត្តមានពេញមួយឆ្នាំ ភាគច្រើននៅបឹងទន្លេសាប និងតំបន់ជុំវិញ បឹង។ រដូវបន្តពូជ: ចាប់ពីខែ កុម្ភៈ ដល់ មិថុនា ពងចំនួនពី ៥ ទៅ ៧ ។

**101 -ត្លុំ**: Watercock *Gallicrex cinerea* ៤១-៤៣ ស.ម ញីពី ៣១-៣៦ ស.ម
ឈ្មោលនៅរដូវបន្តពូជ:មានមាឌមធ្យម ខ្លួនមានពណ៌ខ្មៅប្រផេះ ស្លាបទី១រំលិចតែមពណ៌លឿង មានចំពុះលឿង មានសិរក្រហមដុះទៅលើ និងជើងពណ៌ក្រហម។ ឈ្មោលរដូវមិនបន្តពូជ: មានរូបរាងដូចញីដែរនៅរដូវមិនបន្តពូជ តែមានមាឌធំជាង ខ្សែអង្កត់ផ្នែកពោះច្បាស់ជាង។ ញីនៅរដូវបន្តពូជ: មាឌតូចជាងឈ្មោល ផ្នែកខ្នងមានពណ៌ក្រម៉ៅ ផ្នែកទ្រូង និងចំហៀងទ្រូង មានពណ៌លឿងទុំ និងតាមចង្កូរពោះពណ៌ស។ ទីជំរក: វាលភក់មានរុក្ខជាតិក្រាស់ និងវាលស្រែ តំបន់វាលស្មៅលិចទឹក។ ចរាចរ: វត្តមានពេញមួយឆ្នាំ និងមានគ្រប់ទីកន្លែង។ រដូវបន្តពូជ: ចាប់ពី ខែ ឧសភា ដល់ កញ្ញា។

**102 -ទោច**: Purple Swamphen *Porphyrio porphyrio* ២៨,៥-៤២ ស.ម
ខ្លួនពណ៌ស្វាយលាយខៀវខ្ចី និងក្រម៉ៅ ចំពុះធំ និងជើងពណ៌ក្រហម បំពង់កពណ៌ខៀវខ្ចី។ ទោចមានពីរប្រភេទគឺ *poliocephalus* ដែលមានទំហំធំជាងប្រភេទ *viridis*។ ទីជំរក: តំបន់វាលភក់រុក្ខជាតិ ពិសេសនៅតាមរុក្ខជាតិអណ្តែតទឹក ស្រូវឡើងទឹក។ ចរាចរ: វត្តមានពេញមួយឆ្នាំ និងមានគ្រប់ទីកន្លែង។ រដូវបន្តពូជ: ចាប់ពីខែ កុម្ភៈ ដល់ មិថុនា ពងចំ នួនពី ៣-៧។

**103 -ព្រហិតខ្មៅ**: Bronze-winged Jacana *Metopidius indicus* ២៦,៥-៣០,៥ ស.ម
ខ្លួនពណ៌ខ្មៅ ចំពុះលឿង ស្លាប និងខ្នងពណ៌ទង់ដែង ជើងពណ៌បៃតង។ ទីជំរក: វាលភក់រុក្ខជាតិ តែងឃើញនៅតាមបឹងមានរុក្ខជាតិអណ្តែតទឹកក្រាស់ៗ។ ចរាចរ: វត្តមានពេញមួយឆ្នាំ មានគ្រប់ទីកន្លែង។ រដូវបន្តពូជ: ពេញមួយឆ្នាំ។

**104 -ព្រហិតស**: Pheasant-tailed Jacana *Hydrophasianus chirurgus* ៣០ ស.ម
ពេលបន្តពូជ: មានម្រាមជើងវែងៗ កញ្ចឹងកលឿង ក្បាល និងបំពង់កស ស្លាបពណ៌សចុងស្លាបពណ៌ខ្មៅ កន្ទុយវែងដូចក្អែកខ្លួនពណ៌ត្នោតក្រម៉ៅ ជើងពណ៌ត្រាវ។ រដូវមិនបន្តពូជ: ខ្លួនពណ៌ស្រអាប់ ក បំពង់ក និងផ្នែកពោះពណ៌ស មានឆ្នូតខ្មៅធំកាត់តាមភ្នែកបន្តមកដើមទ្រូង ខ្នងពណ៌ប្រផេះ កន្ទុយខ្លី។ ទីជំរក: វាលភក់រុក្ខជាតិ និងវាលបឹងលិចទឹក។ ចរាចរ: វត្តមានពេញមួយឆ្នាំ មានគ្រប់ទីកន្លែង។ រដូវបន្តពូជ: ចាប់ពីខែ ឧសភា ដល់ មិថុនា ។



100 ពពូលទឹក



101 ក្ងុំ



102 ទោម



103 ព្រហិតខ្មៅ



104 ព្រហិតស

**105 -ខ្សឹប ឬ ទ្រមាក់អណ្តើក**: Bengal Florican *Eupodotis bengalensis* ៦៦-៦៨,៥ ស.ម

ឈ្មោល: ក្បាល និងផ្នែកពោះពណ៌ខ្មៅ ស្លាបស ខ្នងលឿងត្រសក់។ ញី: សំបុរលឿងត្រសក់ ក្បាលឆ្នូតខ្មៅ ពោះស ពេលហើរផ្នែកក្រោមស្លាបពណ៌សប្រផេះ។ ទីជំរក: វាលស្មៅ វាលស្រែ នៃស្រូវឡើងទឹក។ ជីវសាស្ត្រ: មុនហើររត់យ៉ាងលឿន ចូលចិត្តហើរបោះពួយទៅលើបង្ហាញខ្លួន។ ចរាចរ: វត្តមានពេញមួយឆ្នាំ ភាគច្រើនតំបន់ជុំវិញបឹងទន្លេសាប ខេត្តកំពង់ធំ បន្ទាយមានជ័យ និងខេត្តតាកែវជាដើម។ រដូវបន្តពូជ: ចាប់ពីខែ មិនា ដល់ សីហា ពងចំនួន ២ ។

**106 -ទុងប្រផេះ**: Spot-billed Pelican *Pelecanus philippensis* ១២៧-១៤០ ស.ម

ពេលបន្តពូជ: មាឌធំ ខ្លួនសប្រផេះ ចំពុះធំវែង ដែលចំពុះក្រោមរាងជាថង់ នៅលើចំពុះ និងថង់មានអុជៗខ្មៅពាសពេញ។ រដូវមិនបន្តពូជ: នៅលើចំពុះ និងថង់គ្មានអុជៗខ្មៅទេ។ ទីជំរក: បឹង ត្រពាំង ទឹកប្រៃមាត់សមុទ្រ ស្ទឹងធំៗ វាលភក់ តំបន់វាលទំនាប។ ចរាចរ: វត្តមានពេញមួយឆ្នាំ មានច្រើននៅបឹងទន្លេសាប។ រដូវបន្តពូជ: ចាប់ពីខែ សីហា ដល់ ឧសភា ។

**107 -ព្រាបស ខ្មៅ**: Pied Imperial Pigeon *Ducula bicolor* ៣៨-៤១ ស.ម

មាឌមធ្យម ដងខ្លួនពណ៌ស តែស្លាបហើរទី១ និងទី២ពណ៌ខ្មៅ កន្ទុយពណ៌ខ្មៅឆ្លាស់ក្រៅពណ៌ស។ ទីជំរក: រស់នៅតាមព្រៃតំបន់កោះ ព្រៃកោងកាង ព្រៃតំបន់ឆ្នេរសមុទ្រ។ ចរាចរ: វត្តមានពេញមួយឆ្នាំ។ រដូវបន្តពូជ: កុម្ភៈ ដល់ សីហា ពងចំ នួន១ពណ៌ស។

**108 -ព្រាបកោះ**: Nicobar Pigeon *Caloenas nicobarica* ៤០,៥-៤១ ស.ម

បណ្តោយខ្លួនធំមូល សំបុរបៃតងចាស់ ក្បាលខ្មៅ កន្ទុយខ្លីពណ៌ស ជើងក្រហម ចំពុះខ្មៅមានថៃដុះពីលើ។ មិនទាន់ពេញវ័យ: ពណ៌ស្រអាប់ គ្មានរោមករវែងៗ កន្ទុយពណ៌បៃតង។ ទីជំរក: តាមកោះដែលមានព្រៃឈើ។ ជីវសាស្ត្រ: រកចំណីនៅលើដី។ ចរាចរ: វត្តមានពេញមួយឆ្នាំ វត្តមានតែនៅតំបន់កោះ។ រដូវបន្តពូជ: ចាប់ពីខែមេសា ដល់ ឧសភា ពងចំនួនតែ១គត់ពណ៌ស។

**109 -ស្ទាំងធំស្លាបស្រួច**: Peregrine Falcon *Falco peregrinus* ៣៨-៤៨ ស.ម

មាឌធំ ខ្នងពណ៌ប្រផេះស្រអាប់ ពុកមាត់ខ្មៅ និងត្រចៀកស ឆ្នូតអង្កន់ខ្មៅៗជាច្រើននៅចំហៀងដងខ្លួន នៅពីក្រោមស្លាបហើរមាន ឆ្នូតអង្កន់ៗញឹក។ ទីជំរក: ទីជំរកផ្សេងៗគ្នាជាច្រើន រួមទាំងតំបន់ដីសើមផង។ ចរាចរ: វត្តមានពេញមួយឆ្នាំ មានដោយកម្រ។ រដូវបន្តពូជ: ចាប់ពីខែ មករា ដល់ មេសា ពងចំនួនពី ៣ ទៅ ៤។



105 ខ្សឹប ឬ ទ្រមាក់អណ្តើក



106 ទុងប្រផេះ



107 ព្រាបស ខ្មៅ



108 ព្រាបកោះ



109 ស្ទាំងធំស្លាបស្រួច

**110 -អកសមុទ្រ**: White-bellied Sea Eagle *Haliaeetus leucogaster* ៧០-៨៥ ស.ម
ពេលទំមែកឈើខ្លួនឈរត្រង់ ក្បាល ទ្រូង និងពោះពណ៌សព្រលែត ស្លាបពណ៌សព្រលែត តែស្លាប ទី១ និង ទី២ពណ៌ខ្មៅ ចំពុះធំខុប ផ្នែកលើគល់កន្ទុយពណ៌ខ្មៅ។ ទីជំរក: ឆ្នេរសមុទ្រ កោះ និងនៅទឹកសាបមានម្តងម្កាល។ ចរាចរ: វត្តមានពេញមួយឆ្នាំ ជាប្រភេទកំរ។ រដូវបន្តពូជ: ចាប់ពីខែ កញ្ញា ដល់ មិថុនា ពងចំនួន២។

**111 -អកត្រីក្បាលប្រផេះ**: Grey-headed Fish Eagle *Ichthyophaga icthyaetus* ៦៩-៧៤ ស.ម
មានឧធំ កវែងជាងអកដទៃ ក្បាលប្រផេះ សំបុរត្នោតចាស់ ចុងកន្ទុយខ្មៅ ពោះ និងកន្ទុយស ដើមទ្រូងពណ៌ឈាមជ្រូក ស្លាបផ្នែកក្រោមពណ៌ខ្មៅ។ ទីជំរក: ត្រពាំង ព្រៃលិចទឹក ទន្លេធំៗ។ ចរាចរ: វត្តមានពេញមួយឆ្នាំ មានគ្រប់ទីកន្លែង ជាប្រភេទកំរ។ រដូវបន្តពូជ: ចាប់ពី ខែ វិច្ឆិកា ដល់ មិនា។

**112 -អកត្រីតូច**: Lesser Fish Eagle *Ichthyophaga humilis* ៥១-៦៨ ស.ម
ពេញវ័យ: ស្រដៀងអកត្រីក្បាលប្រផេះដែរ តែមាឌតូចជាង ដែលមានពណ៌ប្រផេះស្រាលផ្នែកខ្នង និងកន្ទុយប្រផេះជាំ ក្រោមស្លាបពណ៌ខ្មៅអាចបង្ហាញនូវដៅសមួយដុំចុងស្លាបសងខាង កន្ទុយអង្កន់ខ្មៅខាងចុង។ មិនទាន់ពេញវ័យ: ដងខ្លួនពណ៌ពព្លាក់ ក្រោមស្លាបពណ៌ស។ ទីជំរក: តាមស្ទឹង អូរធំៗក្នុងព្រៃ។ ចរាចរ: វត្តមានពេញមួយឆ្នាំ កំណត់ត្រាចុងក្រោយនៅភាគនិរតី និង ភាគឦសាននៃប្រទេស។ រដូវបន្តពូជ: ចាប់ពីខែ មករា ដល់ មេសា។

**113 -អកត្រីធំ**: Pallas's Fish Eagle *Haliaeetus leucoryphus* ៧៦-៨៤ ស.ម
ពេញវ័យ: មានរូបរាងស្រដៀងអកត្រីក្បាលប្រផេះដែរតែមាឌធំជាង សំបុរត្នោតចាស់ ក្បាលប្រផេះ គល់កន្ទុយអង្កន់សធំ និងចុងកន្ទុយពណ៌ខ្មៅ។ មិនទាន់ពេញវ័យ: ក្បាល ដើមទ្រូងពណ៌ប្រផេះក្រម៉ៅ កន្ទុយខ្មៅ ក្រោមស្លាបមានឆ្នូតសកណ្តាលស្លាប និងដៅសមួយដុំនៅស្លាបទី១។ តែមស្លាបផ្នែកក្រោមពណ៌ត្នោត។ ទីជំរក: ទំនាបលិចទឹក បឹងធំៗ និងទន្លេ។ ចរាចរ: ជាប្រភេទខ្វាត់ព្រាត់ ជួបប្រទះតែម្តងគត់ និងជាសត្វកម្រ។ រដូវបន្តពូជ: ចាប់ពីខែតុលាដល់កុម្ភៈ។

**114 -ប្រម៉ង់**: Osprey *Pandion haliaetus* ៥៥-៦៣ ស.ម
ឈ្មោល: ផ្នែកខ្នងពណ៌ត្នោតចាស់ ផ្នែកពោះ និងក្បាលពណ៌ស មានឆ្នូតក្រម៉ៅកាត់តាមភ្នែក។ ញី: មានប្រឡៅដើមទ្រូងពណ៌ប្រផេះ។ ទីជំរក: មាត់សមុទ្រ បឹង ទន្លេ និងវាលភក់ រុក្ខជាតិ។ ចរាចរ: ជាប្រភេទឆ្លងកាត់ មានគ្រប់ទីកន្លែង។



110 អកសមុទ្រ



111 អកត្រីក្បាលប្រផេះ



112 អកត្រីតូច



113 អកត្រីធំ



114 ប្រម៉ង់

**115 -ខ្លែងឆាបលឿងក្រម៉ៅ**: Brahminy Kite *Haliastur indus* ៤៤-៥២ ស.ម
ស្លាបលើ និងពោះពណ៌ត្នោតទុំ ក្បាល ក និងទ្រូងពណ៌សពពាល ចុងស្លាបទី១ខ្មៅរាងដូចម្រាមៗ។ ទីជំរក: តំបន់ឆ្នេរ ព្រៃកោងកាង ទន្លេធំៗ បឹង និងនៅក្បែរក្រុង។ ជីវសាស្ត្រ: ចូលចិត្តសំកាំងស្លាប និងឆាបចាប់ត្រី។ ចរាចរ: វត្តមានពេញមួយឆ្នាំ មានគ្រប់ទីកន្លែង។ រដូវបន្តពូជ: ចាប់ពីខែ តុលា ដល់ សីហា ពងចំនួនពី ២ ទៅ ៤។

**116 -ខ្លែងខ្មៅ**: Black Kite *Milvus migrans* ៥៥-៦០ ស.ម
ពេញវ័យ: ជាទូទៅដងខ្លួនពណ៌ត្នោតទុំ កន្ទុយវែង និងឆែកបន្តិច ចុងស្លាបទី១ពេលហើរឃ្លាតពីគ្នារាងដូចម្រាមដៃ មានដៅឆ្នូតសក្រោមស្លាបត្រង់គល់ស្លាបទី១។ ពេលមិនទាន់ពេញវ័យ: ដងខ្លួនមានដៅឆ្នូត និងអង្កន់សពាសពេញខ្លួន។ ទីជំរក: តំបន់វាល តំបន់ឆ្នេរ ទន្លេធំៗ និងតាមទីក្រុង។ ចរាចរ: វត្តមានពេញមួយឆ្នាំ តែមួយចំនួនវត្តមាននៅរដូវប្រាំង មានគ្រប់ទីកន្លែង។ រដូវបន្តពូជ: ចាប់ពីខែ តុលា ដល់ កុម្ភៈ។

**117 -រអាតទន្សាយ**: Eastern Marsh Harrier *Circus spilonotus* ៤៨-៥៦ ស.ម
ឈ្មោល: ស្រដៀងរអាតក្បាលខ្មៅដែរតែមានឆ្នូតៗខ្មៅសនៅក និងទ្រូង គ្មានដៅសនៅផ្នែកស្លាបស្មាឡើយ។ ញី: ស្រដៀងញីរអាតខ្មៅដែរ តែដងខ្លួនពណ៌ត្នោតទុំជាង ជាយស្លាបរាងក្រម៉ៅអង្កន់ខ្មៅ។ ញីមិនទាន់ពេញវ័យក្បាលរាងស។ ទីជំរក: តំបន់ដីសើម វាលស្រែ វាលលំហ យើងអាចឃើញចំនួនច្រើននៅតាមទ្រនំរបស់វា។ ចរាចរ: ជាប្រភេទឆ្លងកាត់ ភាគច្រើននៅវាលទំនាបជុំវិញតំបន់បឹងទន្លេសាប។

**118 -អកខ្មៅធំសើម**: Greater Spotted Eagle *Aquila clanga* ៦៥-៧២ ស.ម
បណ្តោយខ្លួនធំ សំបុរត្នោតចាស់ បណ្តោយស្លាបខ្លី ចំពុះតូច កន្ទុយមូលរាងជាអក្សរ U មានដៅសនៅគល់ស្លាបទី១សងខាង។ មិនទាន់ពេញវ័យ: ផ្នែកខ្នងមានពណ៌សពពាល។ ទីជំរក: ទំនាបលិចទឹក បឹង ទន្លេ តំបន់វាលលំហ។ ចរាចរ: ជាប្រភេទឆ្លងកាត់ មានដោយកំរ។

**119 -ឥន្ទ្រីយ៍**: Imperial Eagle *Aquila heliaca* ៧២-៨៣ ស.ម
ជាទូទៅដងខ្លួនមានពណ៌ឈាមជ្រូកក្រម៉ៅ ក្បាល និងកញ្ចឹងកមានពណ៌លឿងមាស មានដៅពណ៌សអុជៗនៅផ្នែកស្មា កន្ទុយពណ៌ប្រផេះ និងឆ្នូតទទឹងខ្មៅធំចុងកន្ទុយ ផ្ទាំងស្លាប ក្រោមពណ៌ប្រផេះជាំ។ ពេលមិនទាន់ពេញវ័យដងខ្លួនមានពណ៌សព្រាលែត។ ទីជំរក: តំបន់វាល តំបន់កសិកម្ម រយៈកំពស់មិនលើសពី ៤០០ម។ ចរាចរ: វត្តមាននៅរដូវប្រាំង ជាប្រភេទកំរ។



115 ខ្លែងឆាបលឿងក្រម៉ៅ



116 ខ្លែងខ្មៅ



117 រអាតទន្សាយ



118 អកខ្មៅដីសើម



119 ឥន្ទ្រីយ៍

**120 -ជើងវែង**: Black-winged Stilt *Himantopus himantopus* ៣៥-៤០ ស.ម
នៅរដូវមិនបន្តពូជ: ចំពុះខ្មៅតូចត្រង់វែងស្រួច មានជើងវែងពណ៌ក្រហម ស្លាបខ្មៅ បន្ទុលក្បាលពណ៌ប្រផេះក្រម៉ៅ។ ឈ្មោលរដូវបន្តពូជ: ដងខ្លួនទាំងមូលលើកលែងស្លាបមានពណ៌សសុទ្ធ និងស្លាបពណ៌ខ្មៅ។ ញីរដូវបន្តពូជ: បន្ទុលក្បាលរាងប្រផេះស្រាល ខ្លួនធាត់មូល។ ទីជំរក: នៅតាមជាយនៃតំបន់ដីសើមវាលស្រែអំបិល តំបន់ឆ្នេរសមុទ្រ ទន្លេធំៗ។ ចរាចរ: វត្តមានពេញ មួយឆ្នាំ មាននៅគ្រប់ទីកន្លែង។

**121 -ផង្កង់ក្រាស់ចំពុះខ្មៅ**: Great Thick-knee *Esacus recurvirostris* ៤៩-៥៤ ស.ម
មាឌធំ ជើងធំហើយវែង ចុងចំពុះខ្មៅ គល់ចំពុះលឿង ពេលហើរស្លាបទី១ខ្មៅលាយស។ ទីជំរក: តាមមាត់ទន្លេធំៗ វាលភក់ វាលខ្សាច់ តំបន់ឆ្នេរ។ ជីវសាស្ត្រ: ច្រើនរកចំណីតែឯកឯង។ ចរាចរ: វត្តមានពេញមួយឆ្នាំ មានគ្រប់ទីកន្លែង ជាប្រភេទកំរ។ រដូវបន្តពូជ: នៅប្រទេសឥណ្ឌាចាប់ពីខែ កុម្ភ: ដល់ សីហា ពងចំនួន២។

**122 -ត្រដេវរិចទួល**: Red-wattled Lapwing *Vanellus indicus* ៣១,៥-៣៥ ស.ម
ក្បាល ក បំពង់ក និងទ្រូងពណ៌ខ្មៅ ត្រចៀកស ជើងលឿង ស្លាបពណ៌ត្នោតខ្ចី និងពោះពណ៌ស។ ចំពុះក្រហមដៅចុងខ្មៅ ជើងលឿង ថ្ងាសក្រហម។ នៅពេលហើរឆ្នូតពណ៌សកាត់ទទឹងលើស្លាបទី១ និងស្លាបទី២។ ទីជំរក: នៅតាមមាត់បឹង ត្រពាំង មាត់ស្ទឹង តំបន់ដីសើម និងដំណាំកសិកម្ម។ ចរាចរ: វត្តមានពេញមួយឆ្នាំ និងមានគ្រប់ទីកន្លែង។ រដូវបន្តពូជ: ចាប់ពីខែ កុម្ភ: ដល់ មិថុនា។

**123 -ត្រដេវរិចក្បាលប្រផេះ**: Grey-headed Lapwing *Vanellus cinereus* ៣៤-៣៧ ស.ម។
មាឌធំជាងត្រដេវរិចដទៃ ក្បាល ក និងទ្រូងពណ៌ប្រផេះ វ័ណ្ឌទ្រូងខ្មៅ ចំពុះលឿងចុងខ្មៅ ជើវែងលឿង ពោះស ។ ទីជំរក: ទំនាបលិចទឹក វាលស្រែ ។ ជីវសាស្ត្រ: រកចំណីលើដី និងពងលើដី។ ចរាចរ: ជាប្រភេទឆ្លងកាត់ មានគ្រប់ទីកន្លែង។

**124 -ត្រដេវរិចទន្លេ**: River Lapwing *Vanellus duvaucelii* ២៩-៣២ ស.ម។
ក្បាល កញ្ចឹងក ដើមទ្រូង ចំពុះ និងជើងមានពណ៌ខ្មៅ ត្រចៀកពណ៌ស ស្លាបហើរទី១-ទី២ពណ៌ខ្មៅ។ ទីជំរក: វាលខ្សាច់តាមមាត់ទន្លេធំៗ។ ចរាចរ: វត្តមានពេញមួយឆ្នាំ មានគ្រប់ទីកន្លែង។ រដូវបន្តពូជ: នៅប្រទេសឥណ្ឌាចាប់ពីខែ មិនា ដល់ មិថុនា ពងចំនួនពី ៣ ទៅ ៤ ។

# ប្រភេទសត្វស្លាបរស់នៅតំបន់ដីសើម



120 ជើងទៀន



121 ជង្គង់ក្រាស់ចំពុះខ្មៅ



122 ត្រដេវវិចទូល



123 ត្រដាវវិចក្បាលប្រផេះ



124 ត្រដេវវិចទន្លេ

**125 -សត្វក្បាលធំវីណ្ណទ្រូងភ្លើងចំពុះវែង**: Greater Sand Plover *Charadrius leschenaultii* ២២-២៥ ស.ម

រដូវមិនបន្តពូជ: ប្រហាក់ប្រហែលនឹងសត្វក្បាលធំវីណ្ណទ្រូងភ្លើងចំពុះខ្លីដែរ ប៉ុន្តែចំពុះ និងមាឌធំជាង ពេលហើរម្រាមជើងសណ្ដកហួសកន្ទុយ។ ឈ្មោលពេលបន្តពូជ: រូបរាងស្រដៀងនឹងសត្វក្បាលធំវីណ្ណទ្រូងភ្លើងចំពុះខ្លីដែរ តែវីណ្ណទ្រូងពណ៌ទឹកក្រូចតូចជាង។ ញីរដូវបន្តពូជ: ស្រដៀងនឹងរដូវមិនបន្តពូជដែរ តែវីណ្ណទ្រូងពណ៌ទឹកក្រូចស្រាលជាង។ ទីជំរក: វាលភក់ តាមឆ្នេរខ្សាច់ តំបន់ឆ្នេរ វាលស្រែអំបិល។ ឋានៈ: វត្តមាននៅរដូវប្រាំង មានគ្រប់ទីកន្លែង និងមួយចំនួនជាប្រភេទឆ្លងកាត់។

**126 -សត្វក្បាលធំវីណ្ណទ្រូងខ្មៅ**: Little Ringed Plover *Charadrius dubius* ១៤-១៧ ស.ម

នៅរដូវមិនបន្តពូជ: ផ្នែកខ្នងពណ៌ត្នោតចាស់ កញ្ចឹងក និងបំពង់កពណ៌ស ជើងលឿង។ ពេលបន្តពូជ: ចំកំកសខ្មៅ ឆ្នូតខ្មៅ កាត់តាមភ្នែក ថ្ងាសស និងខ្មៅ។ ទីជំរក: តាមទន្លេធំៗ បឹងតំបន់ដីសើមទឹកសាប វាលភក់តំបន់ឆ្នេរ វាលភក់រុក្ខជាតិ និងវាលស្រែ។ ជីវសាស្ត្រ: ដើរ ឬរត់២-៣ ជំហានហើយឈប់ដើម្បីរកចំណី។ ឋានៈ: វត្តមានពេញមួយឆ្នាំ មានគ្រប់ទីកន្លែង។ រដូវបន្តពូជ: ចាប់ពីខែ មិនា ដល់ មេសា។

**127 -សត្វក្បាលធំជើងខ្មៅ**: Kentish Plover *Charadrius alexandrinus*១៥-១៧,៥ ស.ម

នៅរដូវមិនបន្តពូជ: ចំកំក ក និងផ្នែកពោះពណ៌ស ចំពុះ និងជើងពណ៌ខ្មៅ ផ្នែកខ្នងពណ៌ត្នោតខ្ចី។ ឈ្មោលពេលបន្តពូជ: បន្ទូលក្បាលពណ៌ទឹកក្រូច ថ្ងាសពណ៌សភ្ជាប់ជាមួយចិញ្ចើមស មានឆ្នូតខ្មៅកាត់តាមភ្នែក និងចំពុះខ្មៅ មានឆ្នូតខ្មៅមួយឆ្នូតនៅដើមទ្រូង។ ទីជំរក: នៅតែតំបន់ឆ្នេរ វាលភក់ ឆ្នេរខ្សាច់ ប៉ុន្តែក៏មានតាមវាលស្រែ ឬ វាលភក់រុក្ខជាតិទឹកសាបដែរ រយៈកំពស់មិនលើសពី ៤៥០ម។ ឋានៈ: ជាប្រភេទឆ្លងកាត់។ រដូវបន្តពូជ: ចាប់ពីខែ កុម្ភៈ ដល់ មិថុនា ។

**128 -សត្វក្បាលធំខ្សាច់**: Malaysian Plover *Charadrius peronii* ១៤-១៦ ស.ម

ឈ្មោល: ខ្នងពណ៌ចំរុះ ក្បាលលឿង ចំកំកខ្មៅស ថ្ងាសខ្មៅស ចំពុះខ្មៅ។ ញី: ស្រដៀងឈ្មោលដែរ ចំកំកស ថ្ងាសស។ ទីជំរក: តំបន់វាលខ្សាច់ដែលគ្មានការរំខាន តំបន់ឆ្នេរសមុទ្រ។ ឋានៈ: វត្តមានពេញមួយឆ្នាំ មានដោយកំរ។ រដូវបន្តពូជ: ចាប់ពីខែ កុម្ភៈ ដល់ សីហា។

# ប្រភេទសត្វស្លាបរស់នៅតំបន់ដីសើម



125សត្វក្បាលធំរីណ្ណទ្រូងភ្លើងចំពុះវែង



126 សត្វក្បាលធំរីណ្ណទ្រូងខ្មៅ



127 សត្វក្បាលធំជើងខ្មៅ



128 សត្វក្បាលធំខ្សាច់

**129 -សត្វក្បាលធំប្រផេះ**: Grey Plover *Pluvialis squatarola* ២៧-៣០ ស.ម
នៅរដូវមិនបន្តពូជ: មានក្បាលធំជាងសត្វក្បាលធំប្រផេះ ចំពុះធំជាងពពួកសត្វក្បាលធំដទៃ ផ្នែកខ្នងមានពណ៌ប្រផេះលាយដោយអុជៗពណ៌សរាងជាស្រកា មានពណ៌ខ្មៅមួយដុំក្រោមស្លាបត្រង់ក្លៀក។ ពេលអាពាហ៍ពិពាហ៍នៅរដូវបន្តពូជ: ជាទូទៅស្រដៀង នឹងឈ្មោលនៅរដូវបន្តពូជនៃសត្វក្បាលធំពណ៌មាសដែរ ប៉ុន្តែឆ្នូតសធំជាងកាត់តាមចិញ្ចើមមកចំហៀងខ្លួន ផ្នែកខ្នងមានពណ៌ខ្មៅអុជៗលាយទៅដោយពណ៌សពាសពេញ។ ទីជំរក: វាលភក់ ឆ្នេរខ្សាច់តំបន់សមុទ្រ កម្រមាន នៅទឹកសាប។ ចរាចរ: មានគ្រប់ទីកន្លែងនៅរដូវប្រាំង និងមួយចំនួនគ្រាន់តែឆ្លងកាត់។

**130 -សត្វក្បាលធំពណ៌មាស**: Pacific Golden Plover *Pluvialis fulva* ២៣-២៦ ស.ម
នៅរដូវមិនបន្តពូជ: ក្បាល ទ្រូង និងផ្នែកខ្នងសម្បុរលឿងក្រម៉ៅ ចំពុះខ្លីស្តើង ផ្នែកពោះពណ៌ស ឈ្មោលរដូវបន្តពូជ: មុខ និងផ្នែកពោះពណ៌ខ្មៅក្រឹប ឆ្នូតសចាប់ពីចិញ្ចើមដល់ចំហៀងខ្លួន។ ទីជំរក: ដំណាំកសិកម្មតំបន់ទំនាប ទីជំរកតាមតំបន់ឆ្នេរ។ ចរាចរ: វត្តមាននៅរដូវប្រាំង មានគ្រប់ ទីកន្លែង និងមួយចំនួនគ្រាន់តែឆ្លងកាត់។

**131 -ទន្រ្ទីតធំ**: Oriental Pratincole *Glareola maldivarum* ២៣-២៤ ស.ម
នៅរដូវមិនបន្តពូជ: ជើង និងចំពុះខ្មៅខ្លី កន្ទុយឆែកល្មម សំបុរដងខ្លួនពណ៌ត្នោតខ្ចី ខ្លួនមូល។ ពេលបន្តពូជ: ខ្លួនរាងទ្រវែង បំពង់កសពុកមាត់ និងជើងខ្មៅក្រឹប គល់ចំពុះក្រហម ចុងខ្នងស។ ទីជំរក: ជនបទ វាលស្រែ វាលភក់ និងតំបន់ឆ្នេរ។ សំលេង: អំបូរនេះមានសំលេងតែមួយឈៀ....បន្ទាប់មកបន្តដោយ ទ្រីត ទ្រីត ទ្រីត ស្រដៀងឈ្មោះរបស់វាដែរ។ ពីសោត្រ្ត: ពងតាមវាលស្រែស្ងួតមានដីរីង និងស៊ីសត្វល្អិត។ ចរាចរ: វត្តមាននៅរដូវពងកូន។ រដូវបន្តពូជ: ចាប់ពីខែ មិនា ដល់ ឧសភា។

**132 -ទន្រ្ទីតទន្លេ**: Small Pratincole *Glareola lactea* ១៦-១៩ ស.ម
នៅរដូវបន្តពូជ: មាឌតូច និងពណ៌ប្រផេះស្រាលជាងទន្រ្ទីតធំ គ្មានពុកមាត់ខ្មៅ ផ្នែកខាងក្រោមស្លាបមានពណ៌សតាមបណ្តោយស្លាបទី១ និង ទី២ និងពណ៌ខ្មៅតាមបណ្តោយគែមលើនៃស្លាប។ នៅរដូវមិនបន្តពូជ: ដើមទ្រូងមានឆ្នូតៗ និងបំពង់កពណ៌ស។ ទីជំរក: ទន្លេធំៗ តាមមាត់បឹងឬតំបន់ដីសើម តាមឆ្នេរសមុទ្រ។ ចរាចរ: វត្តមានពេញមួយឆ្នាំ មិនសូវសំបូរ។ រដូវបន្តពូជ: ចាប់ពីខែ កុម្ភៈ ដល់ មិថុនា ពងចំនួនពី ២ ទៅ ៤។ ជីវសាស្ត្រ: ស៊ីសត្វល្អិត ជាអាហារ។



129 សត្វក្បាលធំប្រផេះ



130 សត្វក្បាលធំពណ៌មាស



131 ទន្ទ្រីតធំ



132 ទន្ទ្រីតទន្លេ

**133 -ថ្ពាំងតូច**: Whimbrel *Numenius phaeopus* ៤០-៤៦ ស.ម
សម្បុរក្រម៉ៅលាយសអុជៗលើខ្លួនចំពុះវែងរាងខុបបន្តិច ចុងខ្នងពណ៌ស ឆ្នូតក្បាលចំហៀងក្រាស់ខ្មៅ ឆ្នូតកណ្តាលក្បាលពណ៌ត្នោតពពាល ។ ទីជំរក: វាលភក់តាមឆ្នេរសមុទ្រ និងឆ្នេរខ្សាច់ព្រៃកោងកាង តំបន់ទំនាបដីសើម ។ ជីវសាស្ត្រ: ពេលទឹកជោរវាទំនៅលើដើមកោងកាង ។ ស្ថានភាព: វត្តមាននៅរដូវប្រាំង ភាគច្រើនតាមតំបន់ឆ្នេរ ។

**134 -ថ្ពាំងធំ**: Eurasian Curlew *Numenius arquata* ៥០-៦០ ស.ម
ខ្លួនធំជាងថ្ពាំងតូច និងចំពុះវែងហើយកោងចុះក្រោមជាង ពេលហើរឃើញចុងខ្នងពណ៌ស ផ្នែកខាងលើស្លាបមានពណ៌អុជចំរុះជាច្រើន (លឿង ស ក្រម៉ៅ ប្រផេះ ត្នោត ពិសេសសំគាល់ដោយមានអុជៗ ស) ផ្នែកពោះពណ៌ផ្កាឈូក ។ ទីជំរក: វាលភក់ តំបន់ឆ្នេរ ឆ្នេរខ្សាច់ ទន្លេ ។ ស្ថានភាព: វត្តមាននៅរដូវប្រាំង ភាគច្រើននៅតំបន់ឆ្នេរ ។

**135 -ខ្វែកសមុទ្រធំពោះត្នោត**: Bar-tailed Godwit *Limosa lapponica* ៣៧-៤១ ស.ម
នៅរដូវមិនបន្តពូជសម្បុរពណ៌ប្រាក់ ស្លាប និងខ្នងពណ៌សលាយប្រផេះដូចស្រកាត្រី ចំពុះវែងហើយស្រួច មានពណ៌លឿងខ្ចីនៅគល់ និងក្រម៉ៅនៅចុង ។ នៅពេលបន្តពូជសម្បុរខ្លួនឡើងពណ៌ត្នោត ។ ទីជំរក: ឆ្នេរខ្សាច់ វាលភក់តាមតំបន់ឆ្នេរ ។ ស្ថានភាព: វត្តមាននៅរដូវប្រាំង ជាពិសេសមាននៅតាមតំបន់ឆ្នេរ ។

**136 -ខ្វែកសមុទ្រតូចពណ៌ត្នោត**: Asian Dowicher *Limnodromus semipalmatus* ៣៤-៣៦ ស.ម
រដូវមិនបន្តពូជ: ខ្នងពណ៌ប្រផេះត្រសក់ ចំពុះខ្មៅត្រង់វែង ចិញ្ចើមស ។ពេញវ័យពេលបន្តពូជ: ខ្លួនឡើងពណ៌ក្រហម ចំណែកញីរាងធាត់ជាង ស្លាប និងទ្រូងពណ៌លឿង ។ ទីជំរក: វាលភក់ឆ្នេរសមុទ្រ ។ ស្ថានភាព: ជាប្រភេទឆ្លងកាត់ មានដោយកំរ ។





133 ថ្ងាងតូច



134 ថ្ងាងធំ



135 ខ្វែកសមុទ្រធំពោះត្នោត



136 ខ្វែកសមុទ្រតូចពណ៌ត្នោត

**137 -ចង្រ្យជើងក្រហមស្លាបឆ្នូតស**: Common Redshank *Tringa totanus* ២៧-២៩ ស.ម
នៅរដូវមិនបន្តពូជ: ទាំងញី និងឈ្មោល ផ្នែកខ្នងសម្បុរលឿងប្រផេះ ផ្នែកពោះពណ៌ស ចំពុះក្រហមត្រង់ ជើងក្រហមព្រលែត នៅពេលហើរបង្ហាញស្លាបឆ្នូតពណ៌ស ។ នៅរដូវបន្តពូជ: ផ្នែកខ្នងមានពណ៌ក្រម៉ៅ និងមានឆ្នូតៗខ្មៅពីក្រោមពោះ ។ ទីជំរក: វាលភក់ឆ្នេរសមុទ្រ វាលភក់រុក្ខជាតិទឹកសាប វាលស្រែ និងទន្លេធំៗ ។ ឋានៈ: វត្តមាននៅរដូវប្រាំង មានគ្រប់ទីកន្លែង ។

**138 -ចង្រ្យជើងពហូត**: Nordmann's Greenshank *Tringer guttifer* ២៩-៣២ ស.ម
រដូវមិនបន្តពូជ: ផ្នែកខ្នងពណ៌ប្រផេះស្រាល ពោះស ជើងលឿង ចំពុះវែងក្រាស់ ចុងខ្នងស ។ ពេលបន្តពូជ: ខ្លួនអុជៗខ្មៅពាសពេញ ខ្នង ទ្រូង និងពោះស ។ ទីជំរក: វាលភក់ វាលខ្សាច់តាមឆ្នេរសមុទ្រ ។ ឋានៈ: ជាប្រភេទឆ្លងកាត់ មានដោយកំរ ភាគច្រើននៅតំបន់ឆ្នេរ ។

**139 -ចង្រ្យជើងល្មៀត**: Common Greenshank *Tringa nebularia* ៣០-៣៤ ស.ម
នៅរដូវមិនបន្តពូជ: មាឌមធ្យម ក្រអាញ ពណ៌ប្រផេះ ចំពុះប្រផេះវែងកោងឡើងលើបន្តិច ជើងវែងពណ៌លឿងបៃតង ។ នៅរដូវបន្តពូជ: ផ្នែកខ្នងមានដៅដុំៗពណ៌ខ្មៅ អង្កន់ឆ្នូតៗចាប់ពីបន្ទូលក្បាលដល់ក ។ ទីជំរក: វាលភក់ វាលភក់រុក្ខជាតិទឹកសាប វាលស្រែ និងទន្លេ ។
ឋានៈ: វត្តមាននៅ រដូវប្រាំង និងមាននៅគ្រប់ទីកន្លែង ។

**140 -ទីតលីតជើងវែង**: Marsh Sandpiper *Tringa stagnatillis* ២២-២៥ ស.ម
ផ្នែកខ្នងពណ៌ត្នោតចាស់ ផ្នែកពោះពណ៌ស ជើងវែងពណ៌លឿង ចំពុះត្រង់ពណ៌ក្រម៉ៅ ។ ពេលបន្តពូជផ្នែក ខ្នងមានអុជៗខ្មៅលាយត្នោត ។ ទីជំរក: វាលភក់តាមឆ្នេរ វាលភក់រុក្ខជាតិទឹកសាប វាលស្រែ ។ ឋានៈ: វត្តមាននៅរដូវប្រាំង និងមួយចំនួនគ្រាន់តែឆ្លងកាត់ ។

**141 -ទីតលីតចំពុះកោង**: Terek Sandpiper *Xenus cinereus* ២២-២៥ ស.ម
ងាយសំគាល់ដោយ បណ្តោយខ្លួនតូច ចំពុះលឿងក្រម៉ៅវែងកោងឡើងលើ សម្បុរប្រផេះលាយពណ៌ផ្កាឈូកខ្ចី និងជើងពណ៌លឿងភ្លឺ កន្ទុយផ្នែកលើពណ៌ខ្មៅ ។ ទីជំរក: វាលភក់ ឆ្នេរខ្សាច់ ។
ឋានៈ: វត្តមាននៅរដូវប្រាំង និងមួយចំនួនគ្រាន់តែឆ្លងកាត់ ។

**142 -ទីតលីតស្លាបក្រោមត្នោតព្រលែត**: Wood Sandpiper *Tringa glareola* ១៨-២១ ស.ម
មិនទាន់ពេញវ័យ: ផ្នែកខ្នងពណ៌ក្រម៉ៅមានអុជៗស ចិញ្ចើមសធំហើយវែង ឆ្នូតៗដើមទ្រូង ពោះពណ៌ស និងជើងពណ៌ទឹកក្រូច ។ រដូវបន្តពូជ: ផ្នែកខ្នងមានអុជខ្មៅៗ លាយស និងក្រម៉ៅក្បាល ក និងទ្រូងមានឆ្នូតៗយ៉ាងច្បាស់ ។ ទីជំរក: វាលភក់រុក្ខជាតិ វាលស្រែ ស្រះចិញ្ចឹមត្រីតាមឆ្នេរ និងទន្លេធំៗ ។ ឋានៈ: វត្តមាននៅរដូវប្រាំង និងមួយចំនួនគ្រាន់តែឆ្លងកាត់ ។

## ប្រភេទសត្វស្លាបរស់នៅតំបន់ដីសើម



**143 -ទីតលីត**: Common Sandpiper *Actitis hypoleucos* ១៩-២១ ស.ម

មិនទាន់ពេញវ័យ: សត្វស្លាបមានមាឌតូចល្អិត ផ្នែកខ្នងមានពណ៌ត្នោតខ្ចី ចំពុះខ្មៅ ជើងលឿង មានចិញ្ចើមពណ៌ស និងឆ្នូតខ្មៅកាត់តាមភ្នែក ពេលហើរមានឆ្នូតសតាមបណ្ដោយលើស្លាប រដូវបន្តពូជ: នៅផ្នែកខ្នងមានឆ្នូតៗខ្មៅច្បាស់ និងខ្នងមាន ពណ៌ត្នោតទុំ។ ទីជំរក: តំបន់ដីសើម ផ្សេងៗ វាលភក់រុក្ខជាតិ ទឹកជោរ ទឹកនាជនៅតាមព្រែកតូចៗតាមថ្មតំបន់ឆ្នេរ បឹង ស្ទឹងជាដើម។ ចរាចរ: ឃើញមានគ្រប់ទីកន្លែង វត្តមាននៅរដូវប្រាំង និងមួយចំនួនគ្រាន់តែឆ្លងកាត់ ។

**144 -ទីតលីតចំពុះឡាំង**: Curlew Sandpiper *Calidris ferruginea* ១៩-២១,៥ ស.ម

រដូវមិនបន្តពូជ: មានចំពុះវែងកោងចុះក្រោមបន្តិច ជើងវែងខ្មៅ ផ្នែកខ្នងពណ៌ប្រផេះស្រាល មានចិញ្ចើម និងពោះពណ៌ស មានឆ្នូតសកណ្ដាលស្លាប ចុងខ្នង និងលើគល់កន្ទុយពណ៌ស។ នៅរដូវបន្តពូជ: ខ្លួនឡើងពណ៌ក្រហម ហើយផ្នែកខ្នងមានអុជចំរុះពណ៌ខ្មៅ ស និងក្រហម។ ទីជំរក: តំបន់វាលភក់ និងវាលខ្សាច់ តំបន់ឆ្នេរ ស្ទឹងធំៗ និងតំបន់ទំនាប។ ចរាចរ: វត្តមាន នៅរដូវប្រាំង ពិសេសតំបន់ឆ្នេរ និងមួយចំនួនជាប្រភេទឆ្លងកាត់។

**145 -ទីតលីតកក្រហម**: Red-necked Stint *Calidris ruficollis* ១៤-១៦ ស.ម

រដូវមិនបន្តពូជ: សម្បុរខ្លួនពណ៌ប្រាក់ ចិញ្ចើមស ឆ្នូតសកណ្ដាលស្លាបលើ ចំពុះខ្លី និងជើងពណ៌ ខ្មៅ ម្រាមវែងៗ។ រដូវបន្តពូជ: សំបុរប្រែប្រួល ក្បាល ក និងខ្នងឡើងពណ៌ក្រហមដូចដុំឥដ្ឋ។ ទីជំរក: តាមវាលស្រែអំបិលនៃតំបន់ឆ្នេរ វាលភក់ឆ្នេរខ្សាច់។ ចរាចរ: វត្តមាននៅរដូវប្រាំង មានគ្រប់ទីកន្លែង និងមួយចំនួនគ្រាន់តែឆ្លងកាត់។

**146 -ខ្វែកត្រោក**: Common Snipe *Gallinago gallinago* ២៥-២៧ ស.ម

ពេញវ័យ: មានចំពុះវែងត្រង់ មានឆ្នូតខ្មៅកាត់តាមភ្នែក ចិញ្ចើមសធំវែង ដងខ្លួនមានពណ៌ចំរុះ ត្នោតចាស់ លឿង និងស។ ពោះ និងគំរបក្រោមកន្ទុយពណ៌ស ឆ្នូតគែមក្រោមនៃស្លាបពណ៌ស កន្ទុយឆ្នាស់ក្រៅពណ៌ស និងលើកន្ទុយពណ៌ត្នោត។ ទីជំរក: តំបន់វាលភក់រុក្ខជាតិ វាលស្រែ។ លក្ខណៈជីវសាស្ត្រ: ហើរលឿនខុសពីធម្មតា។ ចរាចរ: ជាប្រភេទឆ្លងកាត់ មានគ្រប់ទីកន្លែង។





143 ទីតលីត



144 ទីតលីតចំពុះថ្ពាង



145 ទីតលីតកក្រហម



146 ខ្វែកត្រោក

**147 –រំពេតូច**: Little Tern *Sterna albifrons* ២២-២៥ ស.ម

រដូវមិនបន្តពូជ: មាឌតូច ចំពុះខ្មៅស្រួច ជើងខ្លីខ្មៅ បន្ទូលក្បាលខ្មៅ ថ្ងាសស ដងខ្លួនសប្រផេះ តែមស្លាបក្រៅទី១ខ្មៅ។ ពេលបន្តពូជ: ចំពុះលឿង ចុងចំពុះខ្មៅ ជើងពណ៌ទឹកក្រូច ថ្ងាសស បន្ទូលក្បាលខ្មៅក្រិប។ មិនទាន់ពេញវ័យ: ផ្នែកលើស្លាបរាងក្រម៉ៅ។ ទីជំរក: តំបន់កោះ តំបន់ឆ្នេរ ទន្លេធំៗ តំបន់ទំនាប។ ចរាចរ: វត្តមានពេញមួយឆ្នាំ មានសំបូរនៅតាមតំបន់ឆ្នេរនៃប្រទេស។ រដូវបន្តពូជ: ចាប់ពីខែ មេសា ដល់ កញ្ញា។

**148 –រំពេពោះប្រផេះ**: Whiskered Tern *Chlidonias hybridus* ២៤-២៨ ស.ម

សំបុរប្រផេះស្រាល ក្បាលក្រោយខ្មៅ ចំពុះខ្មៅ។ រដូវបន្តពូជ: ក្បាលពណ៌ខ្មៅ ពោះពណ៌ប្រផេះ ជើង និងចំពុះពណ៌ក្រហម។ ទីជំរក: វាលភក់តំបន់ឆ្នេរ ស្រះបង្គា ទន្លេ ព្រៃលិចទឹក បឹង និង វាលលិចទឹក។ ចរាចរ: វត្តមាននៅរដូវប្រាំង ជាពិសេសបឹងទន្លេសាបនារដូវប្រាំង និងមួយចំនួនតូចអាចរស់នៅក្នុងស្រុក។

**149 –រំពេពោះខ្មៅ**: Black-bellied Tern *Sterna acuticauda* ៣០-៣៣ ស.ម

ច្រើនរស់នៅជាមួយរំពេរទន្លេ ចំពុះលឿង ជើងតូចក្រហម ផ្នែកតូចមានអុជៗខ្មៅ។ ពេលបន្តពូជ: បន្ទូលក្បាលខ្មៅ ចំពុះ និងជើងពណ៌ទឹកក្រូច ទ្រូងប្រផេះ និងពោះខ្មៅ កន្ទុយផែកល្មម។ ទីជំរក: វាលភក់ តាមទន្លេធំ និងបឹងធំៗ។ ចរាចរ: វត្តមានពេញមួយឆ្នាំ មានគ្រប់ទីកន្លែង។ រដូវបន្តពូជ: ចាប់ពីខែ កុម្ភៈ ដល់ មេសា ។

**150 –រំពេទន្លេ**: River Tern *Sterna aurantia* ៣៨-៤៦ ស.ម

ចំពុះលឿងចុងវាខ្មៅ ជើងក្រហម កន្ទុយផែកខ្លាំង បន្ទូលក្បាលឆ្នូតៗខ្មៅ ឆ្នូតខ្មៅកាត់តាមភ្នែក។ ពេលបន្តពូជ: ចំពុះលឿងសុទ្ធ បន្ទូលក្បាល និងភ្នែកខ្មៅ ស្លាបលើពណ៌ប្រផេះក្រម៉ៅ។ ទីជំរក: ទន្លេធំៗ ជួនកាលតាមបឹង។ ចរាចរ: វត្តមានពេញមួយឆ្នាំ មានគ្រប់ទីកន្លែង។ រដូវបន្តពូជ: ចាប់ពីខែ មេសា ដល់ ឧសភា។



147 រំពេតូច



148 រំពេពោះប្រផេះ



149 រំពេពោះខ្មៅ



150 រំពេទន្លេ

**151 –រំពេកំពោយធំ**: Great Crested Tern *Sterna bergii* ៤៦ ស.ម

រដូវមិនបន្តពូជ: ខ្លួនពណ៌ប្រផេះស្រាល បន្ទូលក្បាលពណ៌ប្រផេះឆ្នូតៗ ចំពុះ និងជើងពណ៌ខ្មៅ។ ពេលបន្តពូជ: ចំពុះ និងជើងពណ៌ក្រហម បន្ទូលក្បាល និងកញ្ចឹងកពណ៌ខ្មៅក្រិប បំពង់ក និងកពណ៌ស ពោះពណ៌ខ្មៅ កន្ទុយផ្នែកខ្លាំង។ ទីជំរក: តំបន់ឆ្នេរ តំបន់ដីសើម វាលស្រែលិចទឹក។ ជីវសាស្ត្រ: ធ្វើសំបុកនៅតាមកោះតូចៗក្បែរឆ្នេរ។ ស្ថានភាព: វត្តមានពេញមួយឆ្នាំ ជាពិសេសតំបន់ឆ្នេរ។ រដូវបន្តពូជ: ចាប់ពីខែ ឧសភា ដល់ មិថុនា ពងចំនួន ១-២ ។

**152 –រំពេចំពុះធំក្រហម**: Caspian Tern *Sterna caspia* ៤៨-៥៥ ស.ម

រដូវមិនបន្តពូជ: បណ្តោយខ្លួនធំ ចំពុះធំពណ៌ក្រហម បន្ទូលក្បាលប្រផេះឆ្នូតៗ។ ពេលបន្តពូជ: បន្ទូលក្បាលខ្មៅក្រិបតែម្តង។ ទីជំរក: តំបន់ឆ្នេរ វាលភក់ និងវាលខ្សាច់ជួនកាលមាននៅតំបន់ទឹកសាបតាមបឹង និងទន្លេជាដើម។ ស្ថានភាព: ជាប្រភេទឆ្លងកាត់ មានគ្រប់ទីកន្លែងជាពិសេសតំបន់ឆ្នេរ។

**153 –រំពេចំពុះវែងខ្ចី**: Indian Skimmer *Rhynchops albicollis* ៤០-៤៣ ស.ម

សំបុរខ្មៅ ផ្នែកខ្នង និងបន្ទូលក្បាលខ្មៅ ក និងពោះពណ៌ស ចំពុះលឿង ចំពុះលើខ្លីក្រោមវែង ជើងលឿង។ ទីជំរក: ទន្លេធំៗ បឹង និងតាមតំបន់ឆ្នេរ។ ស្ថានភាព: វត្តមានពេញមួយឆ្នាំ ប្រហែលផុតពូជនៅកម្ពុជា។ រដូវបន្តពូជ: នៅប្រទេសឥណ្ឌាចាប់ពីខែ កុម្ភៈ ដល់ មេសា ពងចំនួនពី ៣ ទៅ៤។

**154 –នាងនួនក្បាលត្នោត**: Brown-headed Gull *Larus brunnicephalus* ៤២-៤៦ ស.ម

ពេលបន្តពូជ: ក្បាលពណ៌ខ្មៅ ជើងពណ៌ក្រហម ចំពុះពណ៌ក្រហមជាំ។ ពេលមិនទាន់ពេញវ័យ: ពេលហើរឃើញស្លាបកែវ និងចុងកន្ទុយពណ៌ខ្មៅ។ ទីជំរក: តំបន់ឆ្នេរ ទន្លេធំៗ បឹង។ ស្ថានភាព: វត្តមាននៅរដូវប្រាំង មានគ្រប់ទីកន្លែង។

**155 –ត្រចៀកកាំកោះ**: Christmas Island Frigatebird *Fregata andrewsi* ៩២-១០២ ស.ម

ឈ្មោល: សំបុរខ្មៅសុទ្ធ តែផ្នែកពោះដៅសមួយដុំ បំពង់កក្រហម។ ញី: ផ្នែកពោះសទាំងអស់ កខ្មៅ គ្មានបំពង់កក្រហមទេ។ ទីជំរក: តំបន់សមុទ្រ និងកោះ។ ស្ថានភាព: វត្តមាននៅរដូវបន្តពូជ និងមានដោយកំរ កំណត់ត្រាចុងក្រោយនៅតំបន់សមុទ្រនៃប្រទេសកម្ពុជា។



151 រំពេកំប៉ោយធំ



152 រំពេចំពុះធំក្រហម



153 រំពេចំពុះវែងខ្ចី



154 នាងនួនក្បាលត្នោត



155 ត្រចៀកកាំកោះ





**156 -ចចាតក្រឹច**: Common Kingfisher *Alcedo atthis* ១៦-១៨ ស.ម
បណ្តោយខ្លួនតូចល្អិត ត្រចៀក ពោះពណ៌ត្នោត បំពង់កស ក្បាលពណ៌ខៀវជាមួយអុជៗស។ ទីជំរក: ស្ទឹងដែលមានព្រៃ ប្រឡាយ វាលភក់រុក្ខជាតិ ព្រៃកោងកាង និងតំបន់ឆ្នេរ។ ចរាចរ: វត្តមានពេញមួយឆ្នាំ មានគ្រប់ទីកន្លែង។ រដូវបន្តពូជ: ចាប់ពីខែ មករា ដល់ កក្កដា។

**157 -កងបខៀវស**: Collared Kingfisher *Todiramphus chloris* ២៤-២៦ ស.ម
ផ្នែកខ្នងពណ៌ខៀវ ផ្នែកពោះពណ៌ស ចំកំកស បន្ទូលក្បាលពណ៌បៃតង ចំពុះ និងជើងពណ៌ខ្មៅ និងចិញ្ចើមស។ ទីជំរក: ព្រៃកោងកាង សួនច្បារ និងតំបន់ដាំដុះដែលជិតឆ្នេរជួនកាលនៅតាមទន្លេធំៗ និងព្រៃលិចទឹក។ ចរាចរ: វត្តមានពេញមួយឆ្នាំ មានសំបូរនៅគ្រប់ទីកន្លែង។ រដូវបន្តពូជ: ចាប់ពីខែ ធ្នូ ដល់ សីហា ពងចំនួនពី ៣ ទៅ ៧។

**158 -កងបខ្មៅស**: Pied Kingfisher *Ceryle rudis* ២៧-៣០,៥ ស.ម
សំបុរខ្មៅស វិល្លទ្រូងខ្មៅពីរអង្កន់ ចិញ្ចើមស មានកំប៉ោយធំ។ ញី: វិល្លទ្រូងខ្មៅ តែមួយអង្កន់ទេ។ ទីជំរក: តាមដៃទន្លេ ប្រឡាយ បឹងជួនកាលវាលស្រែ។ ចរាចរ: វត្តមានពេញមួយឆ្នាំ សំបូរគ្រប់ទីកន្លែង។ រដូវបន្តពូជ: ចាប់ពីខែ តុលា ដល់ ឧសភា ពងចំនួនពី ៤ ទៅ ៦ ។

**159 -កងបក្បាលខ្មៅ**: Black-capped Kingfisher *Halcyon pileata* ២៩-៣១,៥ ស.ម
ផ្នែកខ្នងពណ៌ខៀវចាស់ បន្ទូលក្បាលខ្មៅ ចំពុះ និងជើងក្រហម ចំកំក បំពង់ក និងទ្រូងពណ៌ស ពោះពណ៌ត្នោតទុំ ពេលហើរមានដៅសនៅស្លាបទី១។ ទីជំរក: ព្រៃកោងកាង តំបន់ឆ្នេរ ទន្លេធំ ប្រឡាយ បឹង ជួនកាលវាលស្រែ។ ចរាចរ: វត្តមានពេញមួយឆ្នាំ សំបូរគ្រប់ទីកន្លែង។ រដូវបន្តពូជ: ចាប់ពីខែ មេសា ដល់ ឧសភា ពងចំនួនពី ៤ ទៅ ៥។

**160 -កងបទ្រូងស**: White-throated Kingfisher *Halcyon smyrnensis*២៧-២៩ ស.ម
ពោះ និងក្បាលពណ៌កាហ្វេ កន្ទុយ ស្លាប និងខ្នងពណ៌ខៀវ បំពង់ក និងទ្រូងពណ៌ស ចំពុះ និងជើងពណ៌ក្រហម។ ទីជំរក: ជនបទ តំបន់កសិកម្ម ដំណុះព្រៃក្មេង ។ ចរាចរ: វត្តមានពេញមួយឆ្នាំ សំបូរគ្រប់ទីកន្លែង។ រដូវបន្តពូជ: ចាប់ពីខែ តុលា ដល់ មិថុនា ពងចំនួនពី ៣ ទៅ ៧ ។

**161 -ងាវកក**: Stork-billed Kingfisher *Halcyon capensis* ៣៧,៥-៤១ ស.ម
មាឌធំជាងចចាតដទៃ ចំពុះធំក្រហម ចុងចំពុះរាងក្រម៉ៅ បន្ទូលក្បាលពណ៌ប្រផេះក្រម៉ៅ ស្លាបពណ៌ខៀវ ចុងខ្នងពណ៌ខៀវខ្ចី។ ទីជំរក: តាមបឹងដែលមានដើមឈើដុះរាយប៉ាយ ឬ តាមស្ទឹងដែលមានព្រៃស្រោង ឬ ព្រៃរបោះ។ ចរាចរ: វត្តមានពេញមួយឆ្នាំ មានគ្រប់ទីកន្លែង។ រដូវបន្តពូជ: ចាប់ពីខែ មិនា ដល់ ឧសភា ពងចំនួនពី ២ ទៅ ៥។




156 ចចាតក្រឹម


157 កងបខៀវ ស


158 កងបខ្មៅ ស


159 កងបក្បាលខ្មៅ


160 កងបទ្រូងស


161 ងាវកក

**162 –ចាបថ្កូនតាខ្នងត្នោត**: Dusky Warbler *Phylloscopus fuscatus* ១២-១២ ស.ម
ជាទូទៅផ្នែកខ្នងសត្វស្លាបមានពណ៌ត្នោតទុំ ឬពណ៌ប្រផេះត្នោត ផ្នែកពោះពណ៌សព្រលែត និងចិញ្ចើមសវែង។ ទីជំរកៈ តាមគុម្ពោតព្រៃតូចៗ និងតាមតំបន់វាល ជាទូទៅនៅក្បែរមាត់ទឹក។ ឋានៈ: ជាប្រភេទឆ្លងកាត់ មានគ្រប់ទីកន្លែង។

**163 –ចាបថ្កូនតាវាលស្រែ**: Manchurian Reed Warbler *Acrocephalus tangorum* ១៣-១៤.៥ ស.ម
មេបាត់: ផ្នែកខ្នងពណ៌ប្រផេះ ផ្នែកពោះពណ៌ស ចិញ្ចើមសវែង មានឆ្នូតខ្មៅមិនច្បាស់នៅចំហៀងបន្ទូលក្បាល។ មេញី: មានឆ្នូតខ្មៅច្បាស់នៅចំហៀងបន្ទូលក្បាល។ ទីជំរកៈ តាមគុម្ពត្រែង តាមវាលស្មៅនៃតំបន់លិចទឹក។ ឋានៈ: វត្តមាននៅរដូវប្រាំង ភាគច្រើននៅតំបន់ទំនាបជុំវិញបឹងទន្លេសាប។

**164 –ចាបថ្កូនតាចិញ្ចើមខ្មៅស**: Black-browed Reed Warbler *Acrocephalus bistrigiceps* ១៣,៥-១៤ស.ម
ឆ្នូតក្បាលចំហៀងខ្មៅ ចិញ្ចើមស ផ្នែកខ្នងបៃតងខ្ចី ផ្នែកពោះសពពាល។ ទីជំរកៈ ស្មៅត្រែងគុម្ពោតព្រៃតាមវាលភក់រុក្ខជាតិ បឹង និងជិតវាលស្រែ។ ឋានៈ: ជាប្រភេទឆ្លងកាត់ វត្តមានគ្រប់ទីកន្លែង។

**165 –ចាបថ្កូនតាឆ្នូតចុងខ្នង**: Lanceolated Warbler *Locustella lanceolta* ១២-១៣ ស.ម
មាឌតូចស្រដៀងចាបដូនតាដទៃទៀតដែរតែពណ៌ក្រម៉ៅជាង មានឆ្នូតៗខ្មៅពាសពេញដងខ្លួនលើកលែងពោះ។ ទីជំរកៈ វាលស្មៅ គុម្ពោតព្រៃ ជាទូទៅនៅតំបន់ដីសើម។ ឋានៈ: ជាប្រភេទឆ្លងកាត់ មានគ្រប់ទីកន្លែង។

**166 –ចាបថ្កូនតា**: Oriental Reed Warbler *Acrocephalus orientalis* ១៨-២០ ស.ម
ផ្នែកខ្នងពណ៌ត្នោតខ្ចី បំពង់កសពពាល ពោះស ចិញ្ចើមធំស។ ទីជំរកៈ វាលត្រែង ស្មៅ គុម្ពោតព្រៃដែលនៅក្បែរទឹក។ ជីវសាស្ត្រ: រកចំណីតាមដើមឈើទាបៗ។ ឋានៈ: វត្តមាននៅរដូវប្រាំង មួយចំនួនគ្រាន់តែឆ្លងកាត់ មានគ្រប់ទីកន្លែង។



162 ចាបដូនតាខ្នងត្នោត



163 ចាបដូនតាវាលស្រែ



164 ចាបដូនតាចិញ្ចើមខ្មៅ ស



165 ចាបដូនតាឆ្នូតចុងខ្នង



166 ចាបដូនតា

**167 -ចាបក្រុក**: Striated Grassbird *Megalurus palustris* ២៥-២៨ ស.ម ញី ២១,៥-២៤ ស.ម

មានបណ្តោយខ្លួនធំជាងចាបដទៃ កន្ទុយវែងបែកចុងវែងខ្លីតំរៀបជាកាំ ខ្លួនពណ៌ត្នោតចាស់ ចំពុះខ្មៅឆ្នូត១ស ។ មានឆ្នូតខ្មៅធំៗជាជួរនៅផ្នែកខ្នង និងឆ្នូតតូចៗនៅផ្នែកពោះ ។ ទីជំរក: វាលស្មៅ តំបន់ដីសើម និងវាលភក់រុក្ខជាតិនៅតំបន់ទំនាប និងគុម្ពត្រែង ។ ជីវសាស្ត្រ: ធ្វើសំបុកដូចពែង ឬកាបូបស្រី ។ ឋានៈ: វត្តមានពេញមួយឆ្នាំ មានគ្រប់ទីកន្លែង ។ រដូវបន្តពូជ: ចាប់ពីខែ មេសា ដល់ ឧសភា ពងចំនួនពី ៣ ទៅ ៤ ។

**168 -ចាបផង្គូវចិញ្ចើមស**: Plain Prinia *Prinia inornata* ១៣,៥-១៥ ស.ម

កន្ទុយវែងតំរៀបជាកាំៗ ផ្នែកខាងខ្នងពណ៌ត្នោតខ្ចី បំពង់កស ដើមទ្រូងលឿងខ្ចី ចិញ្ចើមសវែង ។ ទីជំរក: តំបន់ដីសើមផ្សេងៗ ត្រែង ស្មៅ និងគុម្ពោតព្រៃ ព្រៃល្បោះ ប្រឡាយ វាលស្រែ និងជិតព្រៃកោងកាង ។ ជីវសាស្ត្រ: ធ្វើសំបុកដូចពែងអាកោ ។ ឋានៈ: វត្តមានពេញមួយឆ្នាំ មានសំបូរគ្រប់ទីកន្លែង ។ រដូវបន្តពូជ: ចាប់ពីខែ មិនា ដល់ តុលា ពងចំនួនពី ៣ ទៅ ៦ ។

**169 -ចាបផង្គូវចុងកន្ទុយស**: Zitting Cisticola *Cisticola juncidis* ១០,៥-១២ ស.ម

មាឌតូចល្អិត បន្ទូលក្បាលពណ៌ត្នោតទុំ ឆ្នូតខ្មៅកណ្តាលក្បាល ចុងខ្នងក្រហមព្រឿងៗ បំពង់កពណ៌ស ចុងកន្ទុយឆ្នូតពិណស ។ ពេលបន្តពូជ: ឆ្នូតខ្មៅនៅខ្នងធំៗ ។ ទីជំរក: វាលស្រែដីភក់រុក្ខជាតិ ស្មៅ និងគុម្ពោតព្រៃទំនាប ។ ឋានៈ: វត្តមានពេញមួយឆ្នាំ មានគ្រប់ទីកន្លែង ។ រដូវបន្តពូជ: ចាប់ពីខែ កុម្ភៈ ដល់ តុលា ពងចំនួនពី ២ ទៅ ៦ ។

**170 -ក្រួចអិនវាលស្រែ**: Paddyfield Pipit *Anthus rufulus* ១៥-១៦ ស.ម

រូបរាងសំបុរដូចចាបពូក ប៉ុន្តែរាងខ្ពស់ស្រឡះក្រចកជើងក្រោយវែង ជំហររាងត្រង់ស្តម ។ ទីជំរក: វាលស្មៅ វាលស្រែ តំបន់ដាំដុះ ។ ឋានៈ: វត្តមានពេញមួយឆ្នាំ សំបូរគ្រប់ទីកន្លែង ។ រដូវបន្តពូជ: ចាប់ពីខែ មករា ដល់ សីហា ពងចំនួនពី ២ ទៅ ៤ ។

**171 -ចាបវាលស្រែកខៀវ**: Bluethroat *Luscinia svecica* ១៣,៥-១៥ ស.ម

ពេញវ័យនៅរដូវមិនបន្តពូជ: កមានពណ៌ខៀវខ្ចីរាងជាស្រកា ទ្រូងពណ៌ខ្មៅ និងពណ៌ទឹកក្រូចដែលតំរៀបជាស្រកាដែរ ចិញ្ចើមសធំ គល់កន្ទុយឆ្លាស់ក្រៅមានពណ៌ទឹកក្រូច ។ ពេញវ័យនៅរដូវបន្តពូជ: កមានពណ៌ខៀវចាស់ដោយមានដៅពណ៌ក្រហមនៅកណ្តាល រួចបន្តទៅទ្រូងដោយពណ៌ខ្មៅ និងពណ៌ក្រហម ។ ញី: ពុកចង្កា និងវីណ្ឌទ្រូងពណ៌ខ្មៅ ។ ទីជំរក: វាលស្មៅ និងគុម្ពោតព្រៃដែលជាទូទៅនៅក្បែរទឹក ។ ឋានៈ: វត្តមាននៅរដូវប្រាំង មានដោយកម្រ ។



167 ចាបក្រុក

168 ចាបដង្កូវចិញ្ចើមស



169 ចាបដង្កូវចុងកន្ទុយស



170 ក្រូចអិនវាលស្រែ



171 ចាបវាលស្រែ ក ខៀវ





**172 -ចាបស៊ីរុយសមុទ្រ**: Mangrove Whistler *Pachycephala grisola* ១៥,៥-១៧ ស.ម
ផ្នែកខ្នងពណ៌ដី ផ្នែកពោះពណ៌ស ចំពុះធំជាងចាបស៊ីរុយ និងពណ៌ខ្មៅសុទ្ធ។ ទីជំរក: ព្រៃកោងកាង ដីប្រៃស្ងួតនៅតំបន់ឆ្នេរ និងកោះ។ ឋានៈ: វត្តមានពេញមួយឆ្នាំ មានបង្គួរ។ រដូវបន្តពូជ: ចាប់ពីខែ មិនា ដល់ មិថុនា ពងចំនួន២។

**173 -ចាបកន្លង់កោងកាង**: Copper-throated Sunbird *Nectarinia calcostetha* ១៤ ស.ម
ឈ្មោល: ផ្នែកខ្នងមានពណ៌ស្លាបកំភែន បំពង់កពណ៌ក្រហម ទ្រូង និងពោះពណ៌ស្វាយ បន្ទួលក្បាល ស្មា និងចុងខ្នងពណ៌បៃតង ។ ញី: ក្បាល និងខ្នងពណ៌ប្រផេះ បំពង់កពណ៌ស ពោះពណ៌លឿងខ្ចី។ ទីជំរក: ព្រៃកោងកាង រុក្ខជាតិតំបន់ឆ្នេរ ជួនកាលនៅលើកោះ និងដំណាំកសិកម្ម។ ឋានៈ: វត្តមានពេញមួយឆ្នាំ ជាប្រភេទកំរ។ រដូវបន្តពូជ: ចាប់ពីខែ មករា ដល់ កញ្ញា។

**174 -ខ្ទប់ដីមេគង្គលើ**: Mekong Wagtail *Motacila samveasna* ១៩ ស.ម
ជាទូទៅសត្វស្លាបមានពណ៌សខ្មៅ ស្រដៀងទៅនឹង ខ្ទប់ដីខ្មៅស White Wagtailដែរ ប៉ុន្តែខុសត្រង់វាមានរោមឆ្នូតខ្មៅកាត់តាមភ្នែក មានចិញ្ចើមសក្រាស់ហើយវែង និងមានឆ្នូតសតាមបណ្តោយចំពុះផ្នែកខាងលើ។ ទីជំរក: រស់នៅតាមបណ្តោយទន្លេភាគច្រើន តាមទន្លេមេគង្គភាគខាងលើក្នុងភូមិភាគឦសាន ខេត្តស្ទឹងត្រែង។ ឋានៈ: ជាប្រភេទស្ថានិក កម្ពុជា ឡាវ ថៃ។ ពត៌មានផ្សេង ទៀតពុំទាន់មាន។

**175 -ត្រចៀកកាំទន្លេត្នោតលាត**: Plain Martin *Riparia paludicola* ១១-១២ ស.ម
ស្រដៀង និងត្រចៀកកាំទន្លេវ័ណ្ណក ប៉ុន្តែគ្មានវ័ណ្ណកទេ សំបុរត្នោតខ្ចី ពោះសព្រលែត។ ទីជំរក: ទន្លេធំៗ និង បឹង។ ឋានៈ: វត្តមានពេញមួយឆ្នាំ មានគ្រប់ទីកន្លែង។ រដូវបន្តពូជ: ចាប់ពីខែ តុលា ដល់ មេសា។

**176 -ត្រចៀកកាំទន្លេវ័ណ្ណក**: Sand Martin *Riparia riparia* ១២-១៣ ស.ម
ពេលពេញវ័យ: ផ្នែកខ្នង និងប្រឡៅកពណ៌ត្នោត ផ្នែកពោះ និងបំពង់កពណ៌ស កន្ទុយឆែកជ្រៅ។ មិនទាន់ពេញវ័យ: បំពង់ក និងពោះពណ៌សស្រអាប់។ ទីជំរក: បឹងទន្លេសាបតំបន់ដីសើម ជួនកាលតំបន់វាលដែលនៅឆ្ងាយពីទឹក។ ឋានៈ: វត្តមាននៅរដូវប្រាំង តែមិនសូវសំបូរ។

**177 -ត្រចៀកកាំកន្ទុយខ្សែលួស**: Wire-tailed Swallow *Hirundo smithii* ១៣-១៤ ស.ម
ស្រដៀងត្រចៀកកាំធម្មតាដែរ តែបន្ទួលក្បាលពណ៌ឈាមជ្រូក ផ្នែកពោះ និងក្រោមស្លាបពណ៌ស កន្ទុយទងកន្ទ្រៃ។ ទីជំរក: ទន្លេធំៗ បឹង។ ឋានៈ: វត្តមានពេញមួយឆ្នាំ មានគ្រប់ទីកន្លែង។ រដូវបន្តពូជ: ចាប់ពីខែ មករា ដល់ វិច្ឆិកា។





172 ចាបស៊ីរុយសមុទ្រ





173 ចាបកន្ទង់កោងកាង



174 ខ្ចប់ដីមេតង្គលើ





175 ត្រចៀកកាំទន្លេត្នោតលាត





176 ត្រចៀកកាំទន្លេវីណ្ឌក





177 ត្រចៀកកាំកន្ទុយខ្សែពីរ

**178 -ចាបមាសឬចាបចង្រ្កង់ក្រហម:** Red Avadavat *Amandava amandava* ១០ ស.ម
ឈ្មោល: នៅរដូវបន្តពូជ ខ្លួនមានពណ៌ក្រហមឆេះលាយអុជៗពណ៌សពាសពេញ។ ញី: ពោះពណ៌ខៀវខ្ចី និងខ្នងពណ៌ត្នោតខ្ចី ចុងខ្នង និងចំពុះពណ៌ក្រហម ឆ្នូតស្លាបសពីរខ្សែ។ ទីជំរក: តំបន់វាលស្មៅ តំបន់ដីសើម គុម្ពោតព្រៃ និងតំបន់វាលលំហ។ ឋានៈ: វត្តមានពេញមួយឆ្នាំ មានគ្រប់ទីកន្លែង ជាប្រភេទកំរ។ រដូវបន្តពូជ: ចាប់ពីខែ មករា ដល់ កញ្ញា ។

**179 -ចាបពូកទ្រូងត្នោតលាត:** Baya Weaver *Ploceus philippinus* ១៥ ស.ម
ឈ្មោលរដូវបន្តពូជ: បន្ទូលក្បាលពណ៌លឿង បំពង់កពណ៌ត្នោតចាស់ មុខប្រផេះជាំ និងទ្រូងគ្មានឆ្នូតទេ។ ញី: មានពណ៌ចំរុះ បន្ទូលក្បាល និងត្រចៀកគ្មានពណ៌ខ្មៅទេ។ រដូវមិនបន្តពូជ: ឈ្មោល និងញីមានពណ៌សំបុរដូចគ្នា។ ទីជំរក: តំបន់កសិកម្ម វាលស្មៅ និងព្រៃត្រែង ដំណុះព្រៃក្មេង តំបន់វាល។ ឋានៈ: វត្តមានពេញមួយឆ្នាំ ជាប្រភេទកំរ។ រដូវបន្តពូជ: ពេញមួយឆ្នាំ ជាពិសេសចាប់ខែ ធ្នូ ដល់ មិថុនា ពងចំនួនពី ២-៥ ពណ៌ស។

**180 -ចាបពូកទ្រូងឆ្នូត:** Streaked Weaver *Ploceus manyar* ១៣,៥ ស.ម
ឈ្មោលរដូវបន្តពូជ: បន្ទូលក្បាលលឿង មុខពណ៌ខ្មៅ ទ្រូងពណ៌ត្នោតចាស់ និងមានឆ្នូតៗខ្មៅជាជួរ ខ្នងពណ៌ក្រម៉ៅ និងមានឆ្នូតខ្មៅធំៗ។ ឈ្មោលរដូវមិនបន្តពូជ: ឈ្មោលចិញ្ចើមពណ៌លឿងខ្ចី ត្រចៀកមានពណ៌ខ្មៅឆ្នូតលឿង។ ឈ្មោលប្រភេទ peguensis នៅរដូវបន្តពូជ: ឆ្នូតទ្រូង និងខ្នងមានពណ៌ខ្មៅជាំ។ ជីវសាស្ត្រ: សំបុកមានលក្ខណៈពិសេស ហើយស្អាតជាងគេ ផ្លូវចូលពីក្រោម ឈ្មោលសំបុកវែង ញីសំបុកខ្លី។ ទីជំរក: តំបន់កសិកម្ម វាលស្មៅ វាលភក់ ជាទូទៅក្បែរមាត់ទឹក រយៈកំពស់ មិនលើសពី ៩១៥ម។ រដូវបន្ត: ចាប់ពីខែ ឧសភា ដល់ សីហា ពងចំនួនពី ២-៥ ពណ៌ស។

**181 -ចាបពូកទ្រូងលឿង:** Asian Golden Weaver *Ploecus hypoxanthus* ១៥ ស.ម
ឈ្មោលពេលបន្តពូជ: ក្បាល និងដងខ្លួនពណ៌លឿង គុម្ពត្រចៀក បំពង់ក និងកន្ទុយពណ៌ខ្មៅ។ ញី: ស្រដៀងនឹងចាបពូកទ្រូងត្នោតដែរ តែបន្ទូលក្បាលឆ្នូតៗញឹកជាង។ ទីជំរក: តំបន់វាលភក់រុក្ខជាតិ វាលស្មៅ និងគុម្ពត្រែង តំបន់ផ្សេងៗដែលនៅក្បែរមាត់ទឹក។ ជីវសាស្ត្រ: ធ្វើសំបុកតាមត្រែង ឬស្មៅដែលមានផ្លូវចូលចំហៀង។ ឋានៈ: វត្តមានពេញមួយឆ្នាំ ច្រើនមានតាមតំបន់ទំនាបទន្លេមេគង្គ និងតំបន់ជុំវិញបឹងទន្លេសាបជាប្រភេទកំរ។ រដូវបន្តពូជ: ចាប់ពីខែ មេសា ដល់ តុលា ពងចំនួនពី ២ ទៅ ៤។



178 ចាបមាស ឬ ចាបចង្រ្កង់ក្រហម



179 ចាបពូកទ្រូងត្នោតហោត



180 ចាបពូកទ្រូងឆ្នូត



181 ចាបពូកទ្រូងលឿង

# ប្រភេទសត្វស្លាបរស់នៅ
# តំបន់ព្រៃ



Forest Birds





**182 -ទទាជើងបែតងឬមាន់ក្រូច:** Scaly-breasted Partridge *Arborophila chloropus*
ផ្នែកខ្នង និងទ្រូងពណ៌ត្នោតចាស់ ដើមពោះពណ៌ទឹកក្រូច ពោះពណ៌ស ជើងពណ៌បៃតង គល់ចំពុះក្រហមចុងចំពុះបៃតង កន្ទុយវែងជាងទទាដទៃ។ ទីជំរក: ព្រៃស្រោង ពាក់កណ្ដាលស្រោង ។ ឋានៈ: វត្តមានពេញមួយឆ្នាំ សំបូរគ្រប់ទីកន្លែង។ រដូវបន្តពូជ: ចាប់ពីខែ មេសា ដល់ ឧសភា ពងចំនួន ៣។

**183 -ក្រូចសំពៅឬមាន់ក្រិច:** Chestnut-headed Partridge *Arborophilia cambodiana* បណ្ដោយខ្លួន ២៨ ស.ម។
ក្បាល និងទ្រូងពណ៌ក្រហមជាំ បន្ទួលក្បាលខ្មៅ ឆ្នូតខ្មៅកាត់ភ្នែក។ នៅចំហៀងពោះរោមតំរៀបជាស្រកាធំៗ ពណ៌សខ្មៅ និងនៅលើស្លាបផងដែរ។ ទីជំរក: ក្នុងព្រៃស្រោងរយ:កំពស់ចាប់ពី៤០០-១០០០ម។ ជីវសាស្ត្រ: រស់នៅ និងរកស៊ីលើដីឆាប់ផ្អើលបំផុត អាចស្គាល់បានតាមរយ:សំឡេង។ ឋានៈ: វត្តមានពេញមួយឆ្នាំ ជាប្រភេទស្ថានិក ដែលមាននៅតែភូមិភាគនិរតីនៃប្រទេសកម្ពុជាប៉ុណ្ណោះ (ជួរភ្នំក្រវាញ)។ រដូវបន្តពូជ: ចាប់ ពីខែ ឧសភា ដល់ មិថុនា និង ពតិមានផ្សេងទៀត មិនទាន់ ដឹងច្បាស់លាស់ នៅឡើយ។

**184 -ទទាទ្រូងលឿង:** Orange-necked Partridge *Arborophila davidi* ២៧ ស.ម
ពណ៌នា: ស្រដៀងទទាខ្នងបង្គង់ ប៉ុន្តែឆ្នូតខ្មៅកាត់តាមភ្នែកធំជាង វីណ្ឌកពណ៌ទឹកក្រូច ខ្មៅ និងឈាមជ្រូក។ ចិញ្ចើមសក្រាស់ពីក្រោយភ្នែក និងមានអង្កន់ខ្មៅសចំហៀងខ្លួន។ ទីជំរក: ព្រៃស្រោង ពាក់កណ្ដាលស្រោង ព្រៃឫស្សី។ ឋានៈ: ជាប្រភេទស្ថានិកមានក្នុងតំបន់រវាងប្រទេសកម្ពុជា និងវៀតណាម កំណត់ត្រានៅខេត្តមណ្ឌលគីរី។ ពតិមានផ្សេងទៀតគ្មាន។

**185 -ទទា:** Chinese Francolin *Francolinus pintadeanus* ៣០,៥-៣៣,៥ ស.ម
ពណ៌នា: ដងខ្លួនអុជៗខ្មៅសបង្កើតបានជារាងស្រកាពេញខ្លួន ដោយមានថ្ពាល់ និងបំពង់កពណ៌ស គល់ស្លាប និងរោមគូថពណ៌ឈាមជ្រូក។ ញី: ពណ៌ស្រអាប់ជាងឈ្មោល ផ្នែកពោះមានឆ្នូតៗអង្កន់ខ្មៅញឹក។ ទីជំរក: ព្រៃរបោះ គុម្ពោតព្រៃ និងវាលស្មៅ។ ឋានៈ: វត្តមានពេញមួយឆ្នាំ សំបូរគ្រប់ទីកន្លែង។ រដូវបន្តពូជ: ចាប់ពីខែ មិនា ដល់ កញ្ញា ពងចំនួនពី ៣ ទៅ ៧។

**186 -មាន់ព្រៃ:** Red Junglefowl *Gallus gallus* ៦៥-៧៨ ស.ម
ពណ៌នា: មានជើងពណ៌ប្រផេះ រោមសលើគល់កន្ទុយ ក និងចុងខ្នងមានរោមពណ៌ទង់ដែងលាយពណ៌មាសភ្លឺ ផ្នែកលើខ្នងពណ៌ក្រហមជាំ កន្ទុយពណ៌បៃតងរលោង ផ្នែកពោះពណ៌ខ្មៅ។ ញី: មានពណ៌ត្នោតទុំ កន្ទុយមានរាងដូចផ្លិត និងកពណ៌មាស។ ទីជំរក: តាមជាយព្រៃ ព្រៃពាក់កណ្ដាលស្រោង វាលស្មៅ គុម្ពោតព្រៃ។ ឋានៈ: វត្តមានពេញមួយឆ្នាំ សំបូរគ្រប់ទីកន្លែង។ រដូវបន្តពូជ: ពេញមួយឆ្នាំ ពងចំនួនពី ៤ ទៅ ៩។





182 ទទាជើងបៃតង ឬ មាន់ក្រច



183 ក្រួចសំពៅ ឬ មាន់ក្រិច



184 ទទាទ្រូងលឿង



185 ទទា



186 មាន់ព្រៃ





**187 -មាន់ទោច្រាក់ពណ៌ប្រផេះបៃតង**: Germain's Peacock Pheasant *Polyplectron germaini* ៥៦-៦០ ស.ម

ឈ្មោល: ខ្លួនមានពណ៌ប្រផេះបៃតង នៅលើស្លាប និងកន្ទុយមានដៅរាងដូចជាភ្នែកពណ៌បៃតងខៀវ ស្បែកជុំវិញរង្វង់ភ្នែកក្រហម។ ញី: ស្រដៀងឈ្មោលដែរ តែមាឌតូច និងកន្ទុយខ្លីជាង។ ទីជំរក: ព្រៃស្រោង ពាក់កណ្ដាលស្រោង ព្រៃឬស្សី។ ឋានៈ: វត្តមានពេញមួយឆ្នាំ ជាប្រភេទស្ថានិក មានក្នុងតំបន់នៅភាគខាងត្បូងឥណ្ឌូចិន នៅកម្ពុជាមានវត្តមាននៅភាគឦសាននៃប្រទេស។ រដូវបន្ត: គ្មានពតិមាន ច្បាស់លាស់។

**188 -ស្ដេចកូលីត**: Siamese Fireback *Lophura diardi* បណ្ដោយខ្លួន ៧០-៨០ ស.ម

ឈ្មោល: ស្បែកមុខក្រហម មានរោមកំប៉ោយតូចមួយ ដងខ្លួនពណ៌ប្រផេះ ដែលមានអង្កន់ខ្មៅសនៅតាមចំហៀងខ្លួន និងលើស្លាប ចុងខ្នងមានប៉ាតពណ៌លឿង និងពណ៌ក្រហមជាំ កន្ទុយវែងពណ៌បៃតងជាំរលោង។ ញី: មានរោមតំរៀបជាស្រកានៅពោះ កន្ទុយ ចំហៀងទ្រូង ដងខ្លួនទាំងមូលពណ៌ឈាមជ្រូក ក្បាលប្រផេះ។ ទីជំរក: ព្រៃស្រោង ពាក់កណ្ដាលស្រោង តាមជាយព្រៃ ដំណុះព្រៃក្មេង។ ជីវសាស្ត្រ: រស់នៅ និងរកចំណីលើដីក្នុងស្ថានភាពលាក់ខ្លួនស្ងៀមស្ងាត់។ ឋានៈ: វត្តមានពេញមួយឆ្នាំ មានសំបូរគ្រប់ទីកន្លែង។ រដូវបន្តពូជ: ចាប់ពីខែ មេសា ដល់ មិថុនា ពងចំនួន៤-៨។

**189 -មាន់ទោចណ៌ប្រាក់**: Silver Pheasant *Lophura nycthemera* ៨០-១២៧ ស.ម

ឈ្មោល: ផ្នែកពោះពណ៌ខ្មៅ ផ្នែកខ្នង និងកន្ទុយពណ៌ប្រាក់ក្រម៉ៅ កំប៉ោយខ្មៅវែង។ ញី: មានពណ៌ត្នោតទុំ មានរោមផ្នែកខាងលើពោះរាងដូចស្រកាត្រី។ ទីជំរក: ព្រៃស្រោង ព្រៃពាក់កណ្ដាលស្រោង។ ឋានៈ: វត្តមានពេញមួយឆ្នាំ មានសំបូរគ្រប់ទីកន្លែង។ រដូវបន្តពូជ: ចាប់ពីខែ កុម្ភៈ ដល់ ឧសភា ពងចំនួនពី ៤ ទៅ ១០។

**190 -ក្ងោក**: Green Peafowl *Pavo muticus* ១៨០-២៥០ ស.ម

ឈ្មោល: មានបណ្ដោយខ្លួនធំ ជើងវែង កវែង ស្លាប និងខ្លួនមានពណ៌បៃតងភ្លឺ កំប៉ោយឈរត្រង់ មានកន្ទុយធំវែងមានដៅពណ៌លឿងលាយខៀវរាងដូចជាភ្នែករាប់រយ។ ញី: ស្រដៀងឈ្មោលដែរ តែពណ៌ស្រអាប់ជាង កន្ទុយខ្លី។ ទីជំរក: ព្រៃរបោះចំរុះ តាមមាត់ទឹក ជាយព្រៃ ព្រៃឬស្សី ព្រៃស្រោង និងពាក់កណ្ដាលស្រោងផងដែរ។ ឋានៈ: វត្តមានពេញមួយឆ្នាំ មានគ្រប់ទីកន្លែង។ រដូវបន្តពូជ: ចាប់ពីខែ មិនា ដល់ តុលា ពងចំនួន៣-៨។





187 មាន់ទោប្រាក់ពណ៌ប្រផេះបៃតង



188 ស្តេចកូលីត



189 មាន់ទោពណ៌ប្រាក់



190 ក្ងោក

**191 -ខ្លែងអាតឃ្មុំ**: Oriental Honey-buzzard *Pernis ptilorhyncus* ៥៥-៦៥ ស.ម
ឈ្មោល: មាឌធំ ក្បាលតូច កវែង ផ្នែកខ្នងពណ៌ប្រផេះក្រម៉ៅ បំពង់កសព្រលែត ផ្នែកពោះអង្កន់ញឹកពណ៌ត្នោត ជាទូទៅផ្នែកក្រោមស្លាបពណ៌សព្រលែត ដែលមានឆ្នូតតែមក្រោមនៃស្លាបពណ៌ខ្មៅ ឆ្នូតទទឹងធំខ្មៅក្បែរចុងកន្ទុយ។ ញី: ឆ្នូតទទឹងចុងកន្ទុយ និងឆ្នូតតែមក្រោមនៃស្លាបតូចជាងឈ្មោល។ ជីវសាស្ត្រ: ស៊ីកូនឃ្មុំ ឬ ឱម៉ាល់ក្នុងសំបុក។ ទីជំរក: ព្រៃរបោះ តំបន់វាលលំហ។ ចរាចរ: វត្តមានពេញមួយឆ្នាំ មានគ្រប់ទីកន្លែង។ រដូវបន្តពូជ: ចាប់ពីខែមិនាដល់ឧសភា។

**192 -អកព្រៃច្រើនពណ៌**: Changeable Hawk Eagle *Spizaetus cirrhatus* ៦១-៧៥ ស.ម
ពេញវ័យ: ខ្នងសំបុរត្នោតខ្ចី ឆ្នូតៗខ្មៅផ្នែកពោះ អង្កន់រោមភ្លៅ មានកំប៉ោយតូចមួយ។ មិនទាន់ពេញវ័យ: មានពណ៌ខ្មៅ។ ទីជំរក: ព្រៃស្រោង ព្រៃរបោះ។ ចរាចរ: វត្តមានពេញមួយឆ្នាំ មានគ្រប់ទីកន្លែងតែកំរ។ រដូវបន្តពូជ: ចាប់ពីខែ វិច្ឆិកា ដល់ ឧសភា ពងមានតែមួយគត់។

**193 -អកពស់ព្រៃ**: Crested Serpent Eagle *Spilornis cheela* ៥៦-៧៤ ស.ម
ស្លាបពណ៌ត្នោតក្រម៉ៅ ពេលហើរមានឆ្នូតតែមក្រោមនៃស្លាបពណ៌ខ្មៅ បន្ទាប់មកពណ៌ស ដងខ្លួនមានអុជៗសពាសពេញ និងមានកំប៉ោយក្រាស់មានឆ្នូតទទឹងខ្មៅធំចុងកន្ទុយ។ ទីជំរក: ព្រៃស្រោង ព្រៃល្បោះ និងដំណុះព្រៃក្មេង ព្រៃជាំ។ ជីវសាស្ត្រ: ស៊ីពស់ជាអាហារ។ ចរាចរ: វត្តមានពេញមួយឆ្នាំ មានគ្រប់ទីកន្លែង។ រដូវបន្តពូជ: ចាប់ពីខែ មករា ដល់ តុលា ពងចំនួន ១។

**194 -ស្ទាំងត្នោតស្លាបឆែកកំប៉ោយ**: Jerdon's Baza *Aviceda jerdoni* ៤៦ ស.ម
កំប៉ោយខ្មៅវែងឈរត្រង់ដោយមានពណ៌សនៅចុងកំប៉ោយ ផ្នែកខ្នងពណ៌ត្នោតចាស់ លើកលែងតែក្បាល និងកន្ទុយពណ៌ត្នោតខ្ចី ផ្នែកពោះពណ៌សអង្កន់លឿង។ ទីជំរក: ព្រៃស្រោង តំបន់ដីសើម និងព្រៃជាំ។ ចរាចរ: វត្តមានពេញមួយឆ្នាំ ជាប្រភេទកម្រ។ រដូវបន្តពូជ: ចាប់ពីខែមេសា ដល់ មិថុនា។

**195 -ខ្លែងអាតត្នោត**: Rufous-winged Buzzard *Butastur liventer* ៣៨-៤៣ ស.ម
ក្បាល និងពោះពណ៌ប្រផេះ ស្លាប និងកន្ទុយពណ៌ច្រេះ ក្រោមស្លាបពណ៌ស។ ទីជំរក: ព្រៃរបោះ ដំណុះព្រៃក្មេង។ ចរាចរ: វត្តមានពេញមួយឆ្នាំ មានគ្រប់ទីកន្លែង។ រដូវបន្តពូជ: ចាប់ពីខែ កុម្ភៈ ដល់ ឧសភា។

**196 -ស្ទាំងខ្មៅសស្លាបឆែក**: Black Baza *Aviceda leuphotes* ៣១,៥-៣៣ ស.ម
ខ្លួនពណ៌ខ្មៅសមានកំប៉ោយវែងដុះត្រង់ឡើងលើ ផ្នែកពោះពណ៌សដែលមានឆ្នូតអង្កន់ញឹកពណ៌ត្នោត និងអង្កន់ខ្មៅមួយនៅដើមទ្រូង។ ទីជំរក: ព្រៃរបោះ ព្រៃជាំ។ ចរាចរ: វត្តមានពេញមួយឆ្នាំ មានគ្រប់ទីកន្លែង។ រដូវបន្តពូជ: ចាប់ពីខែ កុម្ភៈ ដល់ ឧសភាពងចំនួនពី២ទៅ៣។



191 រអាតឃ្មុំ



192 អកព្រៃច្រើនពណ៌



193 អកពស់ព្រៃ



194 ស្ទាំងត្នោតស្លាបវែកកំប៉ោយ



195 រអាតត្នោត



196 ស្ទាំងខ្មៅសស្លាបវែក

**197 –ត្មាតទេះ:** White-rumped Vulture *Gyps bengalensis* ៧៥-៨៥ ស.ម

ពេញវ័យចុងខ្នង រោមក និងផ្នែកក្រោមស្លាបពណ៌ស ក្បាល ក ពណ៌ប្រផេះ ដងខ្លួនពណ៌ខ្មៅ។ ទីជំរក: តំបន់ព្រៃលំហ និងតាមជ្រលងភ្នំ។ ជីវសាស្ត្រ: ជារឿយៗរស់នៅជាហ្វូងដោយ ស៊ីសាកសពសត្វជាអាហារ។ ចរាចរ: វត្តមានពេញមួយឆ្នាំ ភាគច្រើនមាននៅភាគខាងជើង និងខាងកើតនៃប្រទេសកម្ពុជា។ រដូវបន្តពូជ: ចាប់ពីខែ តុលា ដល់ កុម្ភៈ ពងចំនួន១ពណ៌ស។

**198 –ត្មាតត្នោត:** Slender-billed Vulture *Gyps teniurostris* ៨០-៩៥ ស.ម

ដងខ្លួនពណ៌ខ្យាច់ ក្បាល និងកវែងខ្មៅ មានរោមក និងចុងខ្នងពណ៌ស ស្លាបហើរពណ៌ខ្មៅ។ ទីជំរក: តំបន់ព្រៃលំហរ។ ជីវសាស្ត្រ: ជារឿយៗរស់នៅជាហ្វូងដោយស៊ីសាកសពសត្វជាអាហារ។ ចរាចរ: វត្តមានពេញមួយឆ្នាំ មាននៅភាគខាងជើង និងខាងកើតនៃប្រទេសកម្ពុជា។ រដូវបន្តពូជ: ចាប់ពីខែ តុលា ដល់ មិនា ពងចំនួន១ ពណ៌ស។

**199 –ត្មាតភ្លើង:** Red-headed Vulture *Sarcogyps calvus* ៨១-៨៥ ស.ម

ដងខ្លួនពណ៌ខ្មៅ ក្បាល និងជើងក្រហម ភ្លៅមានរោមពណ៌ស និងមានឆ្នូតសតាមបណ្ដោយកណ្ដាលស្លាប។ ទីជំរក: តំបន់ព្រៃលំហរ ព្រៃរបោះដែលមានអូរ។ ជីវសាស្ត្រ: ជារឿយៗរស់នៅតែក្នុងព្រៃស៊ីសាកសពសត្វជាអាហារ។ ចរាចរ: វត្តមានពេញមួយឆ្នាំ ភាគច្រើននៅភាគខាងជើង និងខាងកើតនៃប្រទេសកម្ពុជា បច្ចុប្បន្នយើងកំពុងសិក្សាពីរបាយសត្វត្មាតនៅខេត្តព្រះវិហារដោយប្រើវិធីអាហារដ្ឋានត្មាត។ រដូវបន្តពូជ: ចាប់ពីខែ តុលា ដល់ មេសា។

**200 –ត្មាតខ្មៅ:** Cinereous Vulture *Aegypus monachus* ១០០-១១០ ស.ម

បណ្ដោយខ្លួនធំខ្លាំងជាងត្មាតនានា ក្បាលត្រងោល សំបុរខ្មៅទាំងអស់ ចំពុះធំ ត្រដាងស្លាបត្រង់ភ្លីងស្មើមុំ១៨០ ដឺក្រេ។ ទីជំរក: តំបន់ព្រៃលំហរ និងតំបន់ទីវាលទំនាប។ ជីវសាស្ត្រ: ស៊ីសាកសពជាអាហារ។ ចរាចរ: ជាប្រភេទខ្វាត់ព្រាត់ជាសត្វកម្រហូតមកដល់បច្ចុប្បន្ន យើងកត់ត្រាបានតែពីរដងគត់គឺ លើកទី១នៅខេត្តបាត់ដំបងឆ្នាំ១៩៩៣ និងលើកទី២ នៅខេត្តកំពតចុងឆ្នាំ១៩៩៩។



197 ត្មាតផេះ



198 ត្មាតត្នោត



199 ត្មាតភ្លើង



200 ត្មាតខ្មៅ

**201 -ស្ទាំងស្លាបស្រួចចុងខ្នងស**: White-rumped Falcon *Polihierax insignis* ២៥-២៦.៥ សម

ឈ្មោល: ក្បាលពណ៌ប្រផេះ មានឆ្នូតខ្មៅពាសពេញខ្លួន ចុងខ្នងស។ ញី: មានក្បាល ពណ៌ច្រេះ ពោះពណ៌ស និងស្លាបពណ៌ខ្មៅ។ ទីជំរក: ព្រៃរបោះ តំបន់ចំការ។ របាយ: វត្តមាន ពេញមួយឆ្នាំ មានគ្រប់ទីកន្លែង។ រដូវបន្តពូជ: ចាប់ពីខែ កុម្ភៈ ដល់ ឧសភា ពងចំនួន២ពណ៌ស។ ជីវសាស្ត្រ: ជារឿយៗទំលើមែកឈើខ្ពស់ស្រលះ រួចទំលាក់ខ្លួនមកដីដើម្បីឆាបសត្វល្អិតដែល ជាចំណី។

**202 -ស្ទាំងតូចស្លាបស្រួច**: Collared Falconet *Microhierax caerulescens* ១៥,៥-១៨ ស.ម

មានបណ្ដោយខ្លួនតូច ឆ្នូតពណ៌ខ្មៅកាត់តាមភ្នែក ថ្ងាស ចិញ្ចើម និងចំកំកស បំពង់ក និងគូថ ពណ៌ច្រេះ ក្រោមស្លាបមានអង្កន់ញ្ជីក។ ទីជំរក: ព្រៃល្បោះ ទីវាល និងជាយព្រៃស្រោង។ របាយ: វត្តមានពេញមួយឆ្នាំ មានគ្រប់ទីកន្លែង។ រដូវបន្តពូជ: ចាប់ពីខែ កុម្ភៈ ដល់ ឧសភា ពងចំនួនពី ៤ ទៅ ៥។

**203 -ត្រចៀកកាំព្រៃ**: Crested Treeswift *Hemiprocne coronata* ២១-២៣ ស.ម

ខ្លួនពណ៌ប្រផេះ ដោយមានកំប៉ោយតូចនៅលើថ្ងាស។ ឈ្មោល: មានគុម្ពត្រចៀកពណ៌ត្នោត មានស្លាបតូចស្រួចវែង កន្ទុយឆែកខ្លាំង។ ញី: មានឆ្នូតសពីរកាត់តាមលើ និងក្រោមភ្នែក ដង ខ្លួនពណ៌ត្នោតទុំ ចុងខ្នង និងគូថពណ៌ស។ ទីជំរក: ព្រៃល្បោះ តំបន់វាល និងតំបន់កសិកម្ម។ របាយ: វត្តមានពេញមួយឆ្នាំ មានគ្រប់ទីកន្លែង។ រដូវបន្តពូជចាប់ពីខែ មិនា ដល់ មិថុនា ពងចំនួន១។

**204 -ត្រចៀកកាំធំខ្នងត្នោត**: Brown-backed Needletail *Hirundapus giganteus* ២១-២៤.៥ ស.ម

មានមាឌធំជាងត្រចៀកកាំដទៃ ជាទូទៅដងខ្លួនពណ៌ខ្មៅ ផ្នែកគូថ និងចំហៀងពោះពណ៌ស។ មានដៅសនៅដើមភ្នែក។ ទីជំរក: គ្រប់ប្រភេទព្រៃទាំងអស់ និងតំបន់ទីវាល។ របាយ: វត្តមាន ពេញមួយឆ្នាំ មានគ្រប់ទីកន្លែង។ រដូវបន្តពូជ: ចាប់ពីខែ កុម្ភៈ ដល់ មិនា ពងចំនួនពី ៣ ទៅ ៥។



201 ស្ទាំងស្លាបស្រួចចុងខ្នងស



202 ស្ទាំងតូចស្លាបស្រួច



203 ត្រចៀកកាំព្រៃ



204 ត្រចៀកកាំធំខ្នងត្នោត

**205 –មៀមតូចព្រៃ**: Asian Barred Owlet *Glaucidium cucloides* ២០.៥-២៣ ស.ម
ក្បាល មុខ និងផ្នែកខ្នងពណ៌ត្នោតចាស់ ដោយមានស្នាមឆ្នូតអង្កន់ៗពេញខ្លួន។ ក្បាលមូលធំ មានដៅពណ៌សនៅដើមទ្រូង ចំហៀងខ្លួន និងក្រោមគូថ។ ទីជំរក: គ្រប់ប្រភេទព្រៃទាំងអស់។ ចរាចរ: វត្តមានពេញមួយឆ្នាំ មានគ្រប់ទីកន្លែង។ រដូវបន្តពូជ: ចាប់ពីខែ មិនាដល់ មិថុនា ពងចំនួនពី ៣ ទៅ ៥។

**206-ទីទុយធំព្រៃ**: Spot -bellied Eagle Owl *Bubo nipalensis*
មានបណ្ដោយខ្លួនធំ កញ្ចុំត្រចៀកបះឡើង ចំពុះពណ៌លឿង ផ្នែកពោះពណ៌សមានអុជធំៗ នៅពាសពេញ។ ទីជំរក: ព្រៃស្រោង ពាក់កណ្ដាលស្រោង ព្រៃរបោះ។ ជីវសាស្ត្រ: រកចំណី និងស្រែកនៅពេលយប់ សំលេងស្រែកអាចឮបានឆ្ងាយ។ ចរាចរ: វត្តមានពេញមួយឆ្នាំ មានគ្រប់ទីកន្លែង។ រដូវបន្តពូជ: ចាប់ពីខែ កុម្ភៈ ដល់ មិថុនា ពងចំនួន១។

**207 –ទីទុយត្រីថ្ងាសត្នោត**: Brown Fish Owl *Ketupa zeylonensis* ៤៩-៥៤ ស.ម
ជាទូទៅដងខ្លួនមានពណ៌ត្នោតចាស់ផ្នែកពោះមានឆ្នូតធំពណ៌ខ្មៅ និងអង្កន់កាត់ទទឹងទៅដោយឆ្នូតតូចៗជាច្រើនទៀត។ ទីជំរក: ព្រៃស្រោង ព្រៃពាក់កណ្ដាលស្រោង និងព្រៃរបោះក្បែរមាត់ទឹក។ ចរាចរ: វត្តមានពេញមួយឆ្នាំ មានគ្រប់ទីកន្លែង។ រដូវបន្តពូជ: ចាប់ពីខែ ធ្នូ ដល់ មិនា ពងចំនួនពី១ ទៅ ២។

**208 –មៀមខ្លែង**: Brown Hawk Owl *Ninox scutulata* ៣០-៣១ ស.ម
ខ្លួនពណ៌ឈាមជ្រូក ក្បាលតូច ខ្លួនស្រឡូន កន្ទុយវែង ថ្ងាសស ផ្នែកពោះឆ្នូតធំៗ ពណ៌ឈាមជ្រូក កន្ទុយពណ៌ប្រផេះ ភ្នែកពណ៌លឿងឆ្អិន។ ទីជំរក: ព្រៃកោងកាង តំបន់ព្រៃ។ ចរាចរ: វត្តមាននៅរដូវប្រាំង មានដោយកម្រ។ រដូវបន្តពូជ: ចាប់ពីខែ មិនា ដល់ មិថុនា ធ្វើសំបុកក្នុងរន្ធឈើ ពងចំនួនពី២ ទៅ ៣។

**209 –ពព្លាក់ចង់**: Large-tailed Nightjar *Caprimulgus macrurus* ៣១.៥-៣៣ ស.ម
ដងខ្លួនមានពណ៌ត្នោតក្រម៉ៅ ពេញវ័យ: ឆ្នូតខ្មៅបន្ទូលក្បាល មានចំកំបំពង់កស មានដៅសនៅចុងកន្ទុយឆ្លាស់ក្រៅ មានដៅសមួយដុំលើស្លាបសងខាង។ ញី: ដៅសលើស្លាប និងកន្ទុយទំហំតូចជាងឈ្មោល និងពណ៌ស្រអាប់។ ទីជំរក: ជាយព្រៃ តំបន់វាល ព្រៃគុម្ពោត និងតំបន់កសិកម្ម។ ជីវសាស្ត្រ: ដេកលាក់ខ្លួននៅពេលថ្ងៃ រកចំណី និងស្រែកនៅពេលយប់។ ចរាចរ: វត្តមានពេញមួយឆ្នាំ មានគ្រប់ទីកន្លែង។ រដូវបន្តពូជ: ចាប់ពីខែ មករា ដល់ តុលា ពងចំនួន២ ។



205 មៀមតូចព្រៃ



206 ទីទុយធំព្រៃ





207 ទីទុយត្រីថ្វាសត្នោត



208 មៀមខ្លែង



209 ពញ្ញាក់ចង់

**210 -សេកកន្ទុយខៀវលឿង**: Grey-headed Parakeet *Psittacula finschii* ៣៦-៤០ ស.ម
ខ្លួនពណ៌បៃតង ក្បាលពណ៌ប្រផេះចាស់ ចំពុះពណ៌ក្រហម ចំកក់ខ្មៅតូច មានកន្ទុយវែងជាងសេកដទៃដោយ មានពណ៌លឿងនៅផ្នែកខាងចុង ។ ទីជំរក: ព្រៃល្បោះ និងដំណុះព្រៃក្មេង។ ជីវសាស្ត្រ: គំរាមកំហែងដោយសារការចាប់យកមកចិញ្ចឹម។ របាយ: មានគ្រប់ទីកន្លែង ពិសេសភូមិភាគខាងកើតនៃប្រទេសកម្ពុជា។ រដូវបន្តពូជ: ចាប់ពីខែ មិនា ដល់ មេសា។

**211 -សេកសក**: Red-breasted Parakeet *Psittacula alexandri* ៣៣-៣៧ ស.ម
ឈ្មោល: ទ្រូងពណ៌ផ្កាឈូកចាស់ បំពង់កពណ៌ខ្មៅ និងមានស្នាមឆ្នូតខ្មៅលើថ្ងាស។ ញី: ទ្រូងក្រហមដូចឈ្មោលដែរ តែចំពុះខ្មៅ។ ទីជំរក: ព្រៃល្បោះ ដំណុះព្រៃក្មេង និងតំបន់កសិកម្ម។ ជីវសាស្ត្រ: ច្រើនហើរជាហ្វូងធំៗ គំរាមកំហែងដោយសារការចាប់យកមកចិញ្ចឹម។ របាយ: វត្តមានពេញមួយឆ្នាំ សំបូរគ្រប់ទីកន្លែង។ រដូវបន្តពូជ: ចាប់ពីខែ ធ្នូ ដល់ មេសា។

**212 -សេកសោម**: Alexandrine Parakeet *Psittacula eupatria* ៥១ ស.ម
ឈ្មោល: ខ្លួនពណ៌បៃតង ចំពុះធំពណ៌ក្រហម មានដៅពណ៌ក្រហមមួយដុំធំលើស្លាបផ្នែកស្មា មានចំកក់ខ្មៅ និងក្រហម។ ញី: មាឌតូចជាងឈ្មោល គ្មានចំកក់ទេ។ ទីជំរក: ក្នុងព្រៃរបោះធំៗ និងដំណុះព្រៃក្មេង។ ជីវសាស្ត្រ: ធ្វើសំបុកនៅក្នុងរន្ធឈើធំៗ និងមានការគំរាមកំហែងដោយការចាប់យកមកចិញ្ចឹមជាប្រភេទដែលមានតំលៃថ្លៃជាងគេដោយវាចេះនិយាយភាសាមនុស្ស។ របាយ: វត្តមានពេញមួយឆ្នាំ មានគ្រប់ទីកន្លែង ពិសេសភូមភាគខាងជើងនៃប្រទេស។ រដូវបន្តពូជ: ចាប់ពីខែ កុម្ភៈ ដល់ មេសា។

**213 -សេកអាត់**: Blossom-headed Parakeet *Psittacula roseata* ៣០-៣៦ ស.ម
ឈ្មោល: ខ្លួនពណ៌បៃតង ខ្នងលឿង ផ្ទៃមុខពណ៌ផ្កាឈូក បន្ទូលក្បាលពណ៌ប្រផេះ ចំកក់ក្រោមចង្កាខ្មៅ កន្ទុយវែងខាងចុងលឿង មានដៅក្រហមនៅស្លាបស្មា ចំពុះមានពីរពណ៌ខាងលើពណ៌លឿងខាងក្រោមពណ៌ខ្មៅ។ ញី: មានក្បាលពណ៌ប្រផេះសុទ្ធ គ្មានចំកក់ចង្កាតែមានដៅខ្មៅមួយដុំ។ ទីជំរក: ព្រៃល្បោះ ដំណុះព្រៃក្មេង និងតំបន់កសិកម្ម។ របាយ: វត្តមានពេញមួយឆ្នាំ មានគ្រប់ទីកន្លែង។ រដូវបន្តពូជ: ចាប់ពីខែ មករា ដល់ ឧសភា ពងចំនួនពី ៤ ទៅ ៦។

**214 -សេកត្រិច**: Vernal Hanging Parrot *Loriculus vernalis* ១៣-១៥ ស.ម
ឈ្មោល: ខ្លួនតូចជាងសេកដទៃពណ៌តែតងភ្លឺ កន្ទុយខ្លី ជើងលឿង ចំពុះ និងចុងខ្នងពណ៌ក្រហម មានដៅពណ៌ខៀវមួយដុំនៅដើមទ្រូង។ ញី: ពណ៌ស្រអាប់ជាងឈ្មោល គ្មានពណ៌ខៀវនៅដើមទ្រូងទេ។ ទីជំរក: ព្រៃស្រោង ព្រៃល្បោះ និងដំណុះព្រៃក្មេង។ ជីវសាស្ត្រ: ច្រើនហើរតែឯងឬជាហ្វូងតូចៗ។ របាយ: វត្តមានពេញមួយឆ្នាំ មានគ្រប់ទីកន្លែង។ រដូវបន្តពូជ: ចាប់ពីខែ មករា ដល់ កុម្ភៈ។





210 សេកកន្ទុយខៀវ លឿង

211 សេកសក

212 សេកសោម

213 សេកអាត់

214 សេកក្រិច

**215 -សត្វយំ ឬ សត្វចាំត្រចាំង**: Coral-billed Ground Cuckoo *Carpococcyx renauldi* ៦៨,៥-៦៩ ស.ម

ក្បាល ក ទ្រូង កន្ទុយពណ៌ខ្មៅ ចំពុះ ជើង ភ្នែកពណ៌ក្រហមភ្លឺ ដងខ្លួនពណ៌ប្រផេះ ជុំវិញភ្នែកពណ៌ស្វាយ។ មិនទាន់ពេញវ័យ: ក្បាល និងដងខ្លួនប្រផេះក្រម៉ៅ។ ទីជម្រក: ព្រៃស្រោង ដំណុះព្រៃក្មេង។ ចរាចរ: វត្តមានពេញមួយឆ្នាំ ជាប្រភេទកម្រ កំណត់ត្រាចុង ក្រោយនៅតំបន់ភ្នំបូកគោតាមរយៈម៉ាស៊ីនថតស្វ័យប្រវត្តិ។ រដូវបន្តពូជ: ចាប់ពីខែ ឧសភា ដល់ សីហា។

**216 -តុកកាត្វ**: Green-billed Malkoha *Phaenicophaeus tristis* ៥២-៥៩,៥ ស.ម

ផ្ទាំងស្លាបពណ៌ប្រផេះជាំ ពោះសស្រអាប់ កន្ទុយវែងតំរៀបជាកាំៗ និងមានឆ្នូតសនៅចុងរោមកន្ទុយនិមួយៗ ស្បែករង្វង់ភ្នែកក្រហម ចំពុះបៃតង។ ទីជម្រក: ព្រៃស្រោង ព្រៃល្បោះ ដំណុះព្រៃក្មេង ព្រៃជាំ។ ចរាចរ: វត្តមានពេញមួយឆ្នាំ មានគ្រប់ទីកន្លែង។ រដូវបន្តពូជ: ចាប់ពីខែធ្នូដល់មិថុនា។

**217 -ត្រសក់ត្រចៀង**: Rufous Treepie *Dendrocitta vagabunda* ៤៦-៥០ ស.ម

ដងខ្លួនពណ៌ត្នោតទុំ ក្បាល ក ទ្រូងពណ៌ខ្មៅដូចម្រែងភ្លើង កន្ទុយពណ៌ប្រផេះតំរៀបជាកាំដោយមានចុងជ្រលក់ពណ៌ខ្មៅ។ ទីជម្រក: ព្រៃរបោះ ព្រៃរបោះចំរុះ ដំណុះព្រៃក្មេង។ ចរាចរ: វត្តមានពេញមួយឆ្នាំ មានសំបូរគ្រប់ទីកន្លែង។ រដូវបន្តពូជ: ចាប់ពីខែ មិនា ដល់ មេសា។

**218 -ត្រសក់ត្រខៀវ**: Red-billed Blue Magpie *Urocissa erythrorhyncha* ៦៥-៦៨ ស.ម

កន្ទុយវែងតំរៀបជាកាំ ចុងកន្ទុយអង្កន់សខ្មៅ ចំពុះក្រហមភ្លឺ ក្បាល បំពង់កពណ៌ខ្មៅ ផ្នែកខ្នងពណ៌ខៀវ មានឆ្នូតសនៅកញ្ចឹងក។ ទីជម្រក: ព្រៃល្បោះ ដំណុះព្រៃក្មេង ព្រៃគុម្ពោត ព្រៃឫស្សី និងជួនកាលនៅព្រៃស្រោងស្រឡះផងដែរ។ ចរាចរ: វត្តមានពេញមួយឆ្នាំ មានសំបូរគ្រប់ទីកន្លែង។ រដូវបន្តពូជ: ចាប់ពីខែ មិនា ដល់ ឧសភា ពងចំនួនពី ៣ ទៅ ៦។



215 សត្វយំ ឬ សត្វចាំត្រពាំង



216 តុកកាគូ



217 ឆ្អុងឆ្អូតលឿង



218 ឆ្អុងឆ្អូតខៀវ

**219 –កេងកងធំ**: Great Hornbill *Buceros bicornis* ១១៩-១២២ ស.ម

ពណ៌នា: មានបណ្តោយខ្លួនធំ ក្បាលមានពណ៌ខ្មៅលឿង មានចំពុះ និងមួកធំលឿងឆ្នូតកណ្តាលស្លាបពណ៌លឿង និងឆ្នូតសតាមគែមស្លាបក្រោម កន្ទុយស និងមានឆ្នូតទទឹងខ្មៅធំមួយ ភ្នែកក្រហម។ ញី: ភ្នែកស មួកពុំមានពណ៌ខ្មៅទេ។ សំឡេង: មានពីរវគ្គមុនដំបូង ហ្កុក ហ្កុក រួចបន្ទាប់មកស្រែកខ្លាំងៗ ហ្កាបាំង ហ្កាបាំង។ ទីជំរក: ក្នុងព្រៃស្រោង និងព្រៃរបោះចំរុះ។ ឋានៈ: វត្តមានពេញមួយឆ្នាំ មានស្ទើរតែគ្រប់ទីកន្លែង របាយភាគច្រើននៅភាគនិរតីនៃប្រទេសចាប់តាំងពីភ្នំបូកគោដល់ជួរភ្នំក្រវាញ។ ជីវសាស្ត្រ: រស់នៅ និងធ្វើសំបុក នៅក្នុងរន្ធឈើធំៗ។ រដូវបន្តពូជ: ចាប់ពីខែ មករា ដល់ សីហា ពងចំនួន១-៣។

**220 –ឡាំង**: Wreathed Hornbill *Aceros undulatus* ១០០.៥-១១៥ ស.ម

ពណ៌នា: ចំហៀងបន្ទូលក្បាល ក និងទ្រូងពណ៌សស្រអាប់ កន្ទុយពណ៌ស មានឆ្នូតខ្មៅនៅថង់បំពង់ក ស្បែកជុំវិញភ្នែកពណ៌ក្រហម។ ញី: មានថង់ពណ៌ខៀវ ក្បាលខ្មៅ បំពង់ក និងទ្រូងពណ៌ខ្មៅ។ សំឡេង: ដូចកូនឆ្កែស្រែក ហ្កោកហ្កាក ហ្កោកហ្កាក បន្តគ្នាមិនញាប់ពេក។ ទីជំរក: ក្នុងព្រៃស្រោង ព្រៃរបោះចំរុះ ព្រៃតំបន់ឆ្នេរ។ ជីវសាស្ត្រ: រស់នៅ និងធ្វើសំបុកនៅក្នុងរន្ធឈើធំៗច្រើននៅជាហ្វូង។ ឋានៈ: វត្តមានពេញមួយឆ្នាំ មានគ្រប់ទីកន្លែង វត្តមានភាគច្រើននៅតំបន់ជួរភ្នំបូកគោ។ រដូវបន្តពូជ: ចាប់ពីខែ កុម្ភៈ ដល់ សីហា ពងចំនួន១-៣។

**221 –កេងកងតូច**: Oriental Pied Hornbill *Anthracoceros albirostris* ៦៨-៧០ ស.ម

ពណ៌នា: មានតូចជាងកេងកងដទៃ មានពោះពណ៌ស ចុងកន្ទុយ និងឆ្នូតគែមក្រោមនៃស្លាបពណ៌ស ផ្នែកខ្នង ស្លាប និងក្បាលខ្មៅ មានដៅខ្មៅមួយជុំនៅចុងស្នែងលើចំពុះ។ ញី: ស្នែងលើចំពុះតូចជាងឈ្មោល និងមានដៅពណ៌ខ្មៅប្រឡាក់ពាសពេញចំពុះ។ ទីជំរក: ព្រៃស្រោង ព្រៃល្បោះ និងដំណុះព្រៃក្មេង ជាទូទៅនៅតាមដងទន្លេ និងលើកោះ។ ជីវសាស្ត្រ: ធ្វើសំបុកក្នុងរន្ធនៃដើមឈើធំៗរកទ្រនុំជាហ្វូង។ ឋានៈ: វត្តមានពេញមួយឆ្នាំ មានសំបូរគ្រប់ទីកន្លែង។ រដូវបន្តពូជ: ចាប់ពីខែ មករា ដល់ មិថុនា ពងចំនួនពី ១ ទៅ ៣។

**222 –កេងកងត្នោត**: Brown Hornbill *Anorrhinus tickelli* ៧៣-៧៤ ស.ម

ពណ៌នា: ដងខ្លួនពណ៌ត្នោត ក និងដើមទ្រូងពណ៌ស ផ្នែកពោះពណ៌ត្នោតទុំ ចុងកន្ទុយឆ្លាស់ក្រៅស។ ញី: មានបំពង់កពណ៌ត្នោតទុំ និងមានមួកតូចជាងឈ្មោល។ ទីជំរក: ក្នុងព្រៃស្រោង និងព្រៃរបោះចំរុះ។ ឋានៈ: កំណត់ត្រាជាប្រវត្តិសាស្ត្រមាននៅតំបន់គីរីរម្យ និងនៅឆ្នាំ១៩៩៩ យើងកត់ត្រាបានមួយក្បាលគត់។ រដូវបន្តពូជ: ចាប់ពីខែ កុម្ភៈ ដល់ មិថុនា ។



219 កេងកងធំ



220 ញាំង



221 កេងកងតូច



222 កេងកងត្នោត

**223 -អាល់អែកចង្រៃ**: Large Woodshrike *Tephrodornis vigatus* ១៨.៥-២២.៥ ស.ម ដងខ្លួនពណ៌ប្រផេះ។ ឈ្មោល: មានឆ្នូតខ្មៅកាត់ភ្នែក ចំពុះខ្មៅ ចុងខ្នងពណ៌ស។ ញី: សំបុរពណ៌ទឹកដោះគោ ចំពុះលឿង។ ទីជំរក: ព្រៃស្រោង ពាក់កណ្តាលស្រោង ជួនកាលមាននៅព្រៃកោងកាងផងដែរ។ ចរាចរ: វត្តមានពេញមួយឆ្នាំ មានគ្រប់ទីកន្លែង។ រដូវបន្តពូជ: ចាប់ ពីខែ មិនា ដល់ ឧសភា។

**224 -អាល់អែកធំ**: Large Cuckooshrike *Coracina macei* ២៧-៣០.៥ ស.ម មាឌធំជាងអាល់អែកដទៃ ឈ្មោល: ពណ៌ប្រផេះទាំងអស់ចំពុះធំមានឆ្នូតក្រម៉ៅកាត់តាមភ្នែក ផ្នែកគូថពណ៌ស។ ញី: ពណ៌ប្រផេះព្រាលែតជាងឈ្មោល ផ្នែកពោះពណ៌សដែលមានអង្កន់ស្រាល១។ ទីជំរក: ព្រៃស្រោង ពាក់កណ្តាលស្រោង ព្រៃស្រល់។ ចរាចរ: វត្តមានពេញមួយឆ្នាំ មានគ្រប់ទីកន្លែង។ រដូវបន្តពូជ: ចាប់ពីខែ មិនា ដល់ ឧសភា។

**225 -ត្រសេះតូចខ្នៅស**: Grey-capped Pygmy Woodpecker *Dendrocopos canicapillus* ១៣-១៥,៣ ស.ម
ឈ្មោល: មាឌតូចល្អិត បន្ទូលក្បាលពណ៌ប្រផេះ ពោះពណ៌សលាយស្នាមឆ្នូត១ខ្មៅ មានដៅក្រហមលើបន្ទូលក្បាល។ ញី: គ្មានដៅក្រហមលើក្បាលទេ។ ទីជំរក: ព្រៃល្បោះ ដំណុះព្រៃក្មេង ព្រៃគុម្ពោត និងព្រៃគុម្ពោតតាមឆ្នេរ។ ចរាចរ: វត្តមានពេញមួយឆ្នាំ មានគ្រប់ទីកន្លែង។ រដូវបន្តពូជ: ចាប់ពីខែ ធ្នូ ដល់ មេសា។

**226 -ត្រសេះតូចពោះត្នោតទុំ**: Chestnut-bellied Nuthatch *Sitta castanea* ១៣ស.ម មានពីរប្រភេទ ឈ្មោល: neglecta ផ្នែកខ្នងពណ៌ប្រផេះ ផ្នែកពោះពណ៌ត្នោតខ្ចី។ ញី: ស្រដៀងឈ្មោលដែរ តែផ្នែកពោះពណ៌ទឹកក្រូច។ ឈ្មោល: tonkinensis ផ្នែកខ្នងពណ៌ប្រផេះជាំ ផ្នែកពោះពណ៌ឈាមជ្រូក ចំពុះខ្មៅ។ ញី: ស្រដៀងឈ្មោលដែរ តែផ្នែកពោះពណ៌ព្រលែតជាង។ ទីជំរក: ព្រៃស្រល់ ព្រៃរបោះ ជួនកាលនៅព្រៃស្រោងផងដែរ។ ចរាចរ: វត្តមានពេញមួយឆ្នាំ មានគ្រប់ទីកន្លែង ។ រដូវបន្តពូជ: ចាប់ពីខែ មិនា ដល់ ឧសភា ។

**227 -ត្រសេះតូចចំពុះក្រហម**: Velvet-fronted Nuthatch *Sitta frontalis* ១២-១៣.៥ ស.ម ឈ្មោល: ផ្នែកខ្នងពណ៌ខៀវភ្លឺ ចំពុះក្រហម បំពង់កស មានដៅពណ៌ខ្មៅនៅថ្ងាស និងកាត់តាមភ្នែក។ ញី: ស្រដៀងឈ្មោលតែគ្មានឆ្នូតខ្មៅកាត់តាមភ្នែក។ ទីជំរក: ព្រៃស្រោង ពាក់កណ្តាលស្រោង ព្រៃស្រល់។ ចរាចរ: វត្តមានពេញមួយឆ្នាំ មានគ្រប់ទីកន្លែង។ រដូវបន្តពូជ: ចាប់ពីខែ កុម្ភៈ ដល់ ឧសភា។



223 អល់អែកមធ្យម



224 អល់អែកធំ



225 ត្រសេះតូចខ្មៅ ស



226 ត្រសេះតូចពោះត្នោតទុំ



227 ត្រសេះតូចចំពុះក្រហម

**228 -ត្រសេះត្នោតចំពុះខ្មៅ**: Rufous Woodpecker *Celeus brachyurus* ២៥ ស.ម
ពណ៌នា: មានពណ៌ទឹកក្រូចចាស់ ខ្នងអង្កន់ខ្មៅ ថ្ពាល់ក្រហមមួយដុំ។ ញី: គ្មានដៅពណ៌ក្រហមនៅថ្ពាល់។ ទីជំរក: ព្រៃស្រោង ព្រៃរបោះ។ សភាព: វត្តមានពេញមួយឆ្នាំ មានគ្រប់ទីកន្លែង។ រដូវបន្តពូជ: ចាប់ពីខែ មករា ដល់មិថុនា ពងក្នុងរន្ធឈើចំនួនពី ២ ទៅ ៣។

**229 -ត្រសេះតូចខ្នងភ្លើង**: Common Flameback *Dinopium javanense* ២៨-៣០ ស.ម
បន្ទូលក្បាល និងកំប៉ោយក្រហម មានពុកចង្កាតែមួយជួរខុសពីត្រសេះធំខ្នងភ្លើងដែលមានពុកចង្កាព្រែកជាពីរ កញ្ចឹងកខ្មៅសុទ្ធគ្មានឆ្នូតសដូចត្រសេះធំខ្នងភ្លើងទេ។ ញី: បន្ទូលក្បាល និងកំប៉ោយពណ៌ខ្មៅអង្កន់ឆ្នូត១ស។ ទីជំរក: ព្រៃល្បោះ គុម្ពោតព្រៃ ចំការ ព្រៃកោងកាង។ សភាព: វត្តមានពេញមួយឆ្នាំ មានគ្រប់ទីកន្លែង។ រដូវបន្តពូជ: ចាប់ពីខែ មករា ដល់ សីហា ។

**230 -ត្រសេះបៃតងក្បាលខ្មៅ**: Black-headed Woodpecker *Picus erythropygius*
ពណ៌នា: ក្បាល និងកញ្ចឹងកពណ៌ខ្មៅ បន្ទូលក្បាល និងចុងខ្នងពណ៌ក្រហម បំពង់ក និងទ្រូងពណ៌លឿង។ ញី: បន្ទូលក្បាលខ្មៅសុទ្ធ។ ទីជំរក: ព្រៃរបោះ ព្រៃស្រល់។ សភាព: វត្តមានពេញមួយឆ្នាំ មានគ្រប់ទីកន្លែង។ រដូវបន្តពូជ: ចាប់ពីខែ កុម្ភៈ ដល់ មិថុនា។

**231 -ត្រសេះធំកំប៉ោយលឿង**: Greater Yellownape *Picus flavinucha* ៣១,៥-៣៥ ស.ម
ពណ៌នា: ផ្នែកខ្នងពណ៌បៃតងលាតភ្លឺ កំប៉ោយ និងបំពង់កពណ៌លឿង ផ្នែកពោះពណ៌ប្រផេះ បន្ទូលក្បាលពណ៌ត្នោតទុំ។ ញី: គ្មានបំពង់កលឿងទេ។ ទីជំរក: ព្រៃស្រោង ព្រៃល្បោះ និងព្រៃស្រល់។ សភាព: វត្តមានពេញមួយឆ្នាំ មានគ្រប់ទីកន្លែង។ រដូវបន្តពូជ: ចាប់ពីខែ កុម្ភៈ ដល់ឧសភា ។

**232 -ត្រសេះបៃតងទ្រូងពព្លាក់**: Streak-throated Woodpecker *Picus xanthopgaeus* ២៧.៥-៣០ ស.ម
ពណ៌នា: ខ្លួនពណ៌បៃតង បន្ទូលក្បាលក្រហម ចិញ្ចើម និងឆ្នូតក្រោមភ្នែកពណ៌ស។ ញី: បន្ទូលក្បាលខ្មៅ។ ទីជំរក: ព្រៃរបោះ នៅតាមដើមឈើមួយៗ នៅតំបន់វាល។ សភាព: វត្តមានពេញមួយឆ្នាំ មានគ្រប់ទីកន្លែង។ រដូវបន្តពូជ: ចាប់ពីខែ មិនា ដល់ ឧសភា។

**233 -ត្រសេះចំកកក្រហម**: Red-collared Woodpecker *Picus rabieri* ៣០-៣២ ស.ម
ពណ៌នា: ក្បាល និងទ្រូងក្រហម និងមានអង្កន់ចំហៀងពោះស ពុកចង្កាក្រហម។ ញី: ថ្ងាស និងបន្ទូលក្បាលពណ៌ខ្មៅ គ្មានពណ៌ក្រហមនៅពុកចង្កាដូចឈ្មោល។ ទីជំរក: ព្រៃស្រោង ដំណុះព្រៃក្មេង។ សភាព: វត្តមានពេញមួយឆ្នាំ មានដោយកំរ វត្តមានតែនៅភាគអគ្នេយ៍នៃប្រទេស (កំណត់ត្រាតែម្តងគត់តាមរយៈម៉ាស៊ីនថតស្វ័យប្រវត្តិ)។ រដូវបន្តពូជ: ចាប់ពីខែ ឧសភា ដល់មិថុនា។



228 ត្រសេះត្នោតចំពុះខ្មៅ



229 ត្រសេះតូចខ្នងភ្លើង



230 ត្រសេះបៃតងក្បាលខ្មៅ



231 ត្រសេះធំកំប៉ោយលឿង



232 ត្រសេះបៃតង
ទ្រូងពព្លាក់



233 ត្រសេះធំកកក្រហម

**234 -ត្រសេះដីរ៍**: Great Slaty Woodpecker *Mueller ipicus pulverulentus* ៥០ ស.ម
មាឌធំជាងត្រសេះដទៃ ឈ្មោល: មានបណ្ដោយខ្លួនធំពណ៌ប្រផេះ បំពង់កពណ៌លឿង ពុកមាត់ក្រហម។ ញី: គ្មានពុកមាត់ក្រហមទេ។ ទីជំរក: ព្រៃស្រោង ពាក់កណ្ដាលស្រោងពិសេសតាមដងអូរ ជាយព្រៃ និងព្រៃកោងកាង។ ឋានៈ: វត្តមានពេញមួយឆ្នាំ មានគ្រប់ទីកន្លែង ជាប្រភេទកម្រ។ រដូវបន្តពូជ: ចាប់ពី ខែ មិនា ដល់ សីហា។

**235 -ត្រសេះធំពោះស**: White-bellied Woodpecker *Dryocopus javensis* ៣៧.៥-៤៣ ស.ម
មាឌធំបន្ទាប់ពីត្រសេះដីរ៍ ឈ្មោល: បណ្ដោយខ្លួនធំ ដងខ្លួនខ្មៅស កំប៉ោយ បន្ទូលក្បាល និងពុកមាត់ក្រហម។ ញី: ថ្ងាសខ្មៅ គ្មានពុកមាត់ក្រហមទេ។ សំឡេង: កៀវ កៀវ កៀវ ឬ កៀប កៀប កៀប។ ទីជំរក: ព្រៃល្បោះ ព្រៃស្រោង។ ជីវសាស្ត្រ: រស់នៅ និងធ្វើសំបុកនៅក្នុងរន្ធឈើធំៗ។ ឋានៈ: វត្តមានពេញមួយឆ្នាំ មានគ្រប់ទីកន្លែង។ រដូវបន្តពូជ: ចាប់ ពីខែ ធ្នូ ដល់ ឧសភា។

**236 -ពពូលក្បាលព្រលែត**: Pale-capped Pigeon *Columba punicea* ៣៦-៤០,៥ ស.ម
ឈ្មោល: បន្ទូលក្បាលសព្រលែត ខ្នងពណ៌ត្នោតទុំ កញ្ចឹងកពណ៌បៃតង ស្លាបហើរទី១ទី២ និងកន្ទុយពណ៌ខ្មៅ ចំពុះលឿង គល់ចំពុះពណ៌ក្រហម។ ញី: បន្ទូលក្បាលគ្មានពណ៌សព្រលែតទេ។ ទីជំរក: ព្រៃស្រោង ជួនកាលនៅព្រៃកោងកាង តំបន់កោះ និងតំបន់វាលលំហរ។ ឋានៈ: វត្ត-មាន ពេញមួយឆ្នាំ មាននៅភាគឦសាននៃប្រទេសក្នុងខេត្តមណ្ឌលគិរី។ រដូវបន្តពូជ: ចាប់ពី ខែ មិថុនា ដល់ កក្កដា ពងនៅលើដើមឈើតូចៗ ឬ ដើមឫស្សី ពងចំនួន១។

**237 -ព្រាបព្រៃ**: Green Imperial Pigeon *Ducula aenea* ៤២-៤៧ ស.ម
ផ្នែកខ្នងពណ៌បៃតងភ្លឺលាយលឿងព្រឿងៗ ក្បាល ក ទ្រូង និងពោះពណ៌ប្រផេះ នៅក្រោមកន្ទុយពណ៌ច្រេះ។ សំឡេង: របៀបមនុស្សថ្ងូ ប៊ូ ប៊ូ ប៊ូ។ ទីជំរក: ព្រៃស្រោង ពាក់កណ្ដាលស្រោង ព្រៃរបោះចំរុះ និងព្រៃកោងកាង។ ជីវសាស្ត្រ: រកស៊ីផ្លែឈើនៅលើចុងឈើ។ ឋានៈ: វត្តមានពេញឆ្នាំ មានគ្រប់ ទីកន្លែង។ រដូវបន្តពូជ: ចាប់ពីខែ មករា ដល់ ឧសភា។



234 ត្រសេះដីរ



235 ត្រសេះធំពោះស



236 ពពូលក្បាលព្រលែត



237 ព្រាបព្រៃ

**238 -កំប្លុកឬពពូលចំពុះធំលឿង**: Thick-billed Green Pigeon *Treron curvirostra*
ឈ្មោល: មានចំពុះក្រាស់ពណ៌លឿងក្រហមនៅគល់ចំពុះ រង្វង់ភ្នែកជុំវិញពណ៌បៃតង ក្បាលប្រផេះ ស្លាបលើ និងតួថពណ៌ឈាមជ្រូក។ ញី: ចំពុះ ក្បាល និងរង្វង់ភ្នែកដូចឈ្មោលដែរតែស្លាបលើពណ៌បៃតងចាស់។ ទីជំរក: ព្រៃស្រោង ព្រៃល្បោះ ដំណុះព្រៃក្មេង និងព្រៃកោងកាង។ ឋានៈ: វត្តមានពេញមួយឆ្នាំ មានគ្រប់ទីកន្លែង។ រដូវបន្តពូជ: ចាប់ពីខែ មករា ដល់ កញ្ញា។

**239 -លលកស្លាបបៃតង**: Emerald Dove *Chalcophaps indica* ២៣-២៧ ស.ម
ឈ្មោល: បន្ទួលក្បាលពណ៌ខៀវខ្ចី ថ្ងាស និងចិញ្ចើមពណ៌ស ចុងខ្នងអង្កន់ខ្មៅស ស្មា-សស្លាបលើពណ៌បៃតងចាំង។ ញី: បន្ទួលក្បាលពណ៌ត្នោតទុំ គ្មានដៅសលើស្មាទេ។ ទីជំរក: ព្រៃស្រោង ពាក់កណ្តាលស្រោង ព្រៃចំរុះ។ ឋានៈ: វត្តមានពេញមយឆ្នាំ មានគ្រប់ទីកន្លែង។ ជីវសាស្ត្រ: ជាទូទៅវាច្រើនរកស៊ីនៅតាមដងផ្លូវ។ រដូវបន្តពូជ: ចាប់ពីខែ មេសា ដល់ វិច្ឆិកា ពងនៅ លើដើមឈើទាបៗ។

**240 -ពពូលក្បាលបៃតង**: Orange-breasted Green Pigeon *Treron bicincta* ២៩ស.ម
ឈ្មោល: ក្បាលពណ៌បៃតង កញ្ចឹងកពណ៌ប្រផេះ ទ្រូងពណ៌ទឹកក្រូច កន្ទុយពណ៌ប្រផេះ។ ញី: ទ្រូងគ្មានដៅពណ៌ទឹកក្រូចទេ។ ទីជំរក: ព្រៃរបោះ ព្រៃពាក់កណ្តាលស្រោង ដំណុះព្រៃក្មេង និង ព្រៃឫស្សី។ ឋានៈ: វត្តមានពេញមួយឆ្នាំ មានគ្រប់ទីកន្លែង។ រដូវបន្តពូជ: ចាប់ពីខែ កុម្ភៈ ដល់ ឧសភា។

**241 -ពពូលចំពង់កលឿង**: Pompadour Green Pigeon *Treron pompadora* ២៥.៥
ឈ្មោល: ស្រដៀងកំប្លុកដែរ តែចំពុះពណ៌ប្រផេះ និងតូចស្រឡូនជាង បំពង់កមានដៅពណ៌លឿង និងទ្រូងពណ៌ទឹកក្រូច គ្មានវ័ណ្ណបៃតងជុំវិញភ្នែកទេ។ ញី: ស្រដៀងកំប្លុកញីដែរ តែចំពុះតូចជាង ពណ៌ប្រផេះ គ្មានវ័ណ្ណជុំវិញភ្នែក។ ទីជំរក: ក្នុងព្រៃស្រោង និងពាក់កណ្តាលស្រោង។ជីវសាស្ត្រ: រកស៊ីផ្លែឈើរស់នៅជាហ្វូង។ ឋានៈ: វត្តមានពេញមួយឆ្នាំ មានគ្រប់ទីកន្លែង។ រដូវបន្តពូជ: ចាប់ពី ខែ មេសា ដល់ ឧសភា។

**242 -ពពូលជើងលឿង**: Yellow-footed Green Pigeon *Treron phoenicoptera* ៣៣ ស.ម
ឈ្មោល: ក្បាលពណ៌ប្រផេះ បំពង់ក និងទ្រូងពណ៌លឿងលាយបៃតង ខ្នងពណ៌បៃតង ពោះពណ៌ប្រផេះ ជើងលឿង កន្ទុយឆ្នូតទទឹង២កង់ពណ៌លឿង និងបៃតង។ ញី: ក និងទ្រូងពណ៌លឿងស្រស់ ខ្នងពណ៌បៃតងខ្ចី។ ទីជំរក: ព្រៃរបោះចំរុះ ដំណុះព្រៃក្មេង តំបន់ទំនាប។ ជីវសាស្ត្រ: ឃើញមាននៅលើចុងឈើរកស៊ីផ្លែឈើ។ ឋានៈ: វត្តមានពេញមួយឆ្នាំ មានគ្រប់ទីកន្លែង។ រដូវបន្តពូជ: ចាប់ពី ខែ មិនា ដល់ មិថុនា។





238 កំប្លុក ឬ ពពូលចំពុះធំលឿង



239 លលកស្លាបបៃតង



240 ពពូលក្បាលបៃតង



241 ពពូលបំពង់កលឿង



242 ពពូលជើងលឿង

**243 -ប៉ោលតោកគូថក្រហម**: Red-vented Barbet *Megalaima lagrandieri* ២៩,៥-៣៤ ស.ម

មាឌធំជាងប៉ោលតោកដទៃ គូថពណ៌ក្រហម ក្បាលពណ៌ត្នោត បំពង់កប្រផេះ។ ទីជំរកៈ ព្រៃស្រោង ពាក់កណ្តាលស្រោង។ សំលេងៈ ប៉ោលតូក ប៉ោលតូក...។ឋានៈ: វត្តមាន ពេញមួយឆ្នាំ ជាប្រភេទមានតែក្នុងតំបន់ឥណ្ឌូចិន វត្តមាននៅភាគអគ្នេយ៍សំរាប់ប្រទេសកម្ពុជា។ រដូវបន្តពូជ: ចាប់ពីខែ មេសា ដល់ កក្កដា។ ពតិមានផ្សេងទៀតពុំដឹងប្រាកដ។

**244 -ប៉ោលតោកក្បាលព្រលែត**: Lineated Barbet *Megalaima lineata* ២៧-២៨ ស.ម

ក្បាលពណ៌សព្រលែត ចំពុះ និងស្បែកនៅជុំវិញភ្នែកពណ៌លឿង។ ទីជំរកៈ ព្រៃល្បោះ តំបន់វាលលំហរ គុម្ពោតព្រៃតំបន់ឆ្នេរ។ ឋានៈ: វត្តមានពេញមួយឆ្នាំ មានគ្រប់ទីកន្លែង។ រដូវបន្តពូជ: ចាប់ពីខែ កញ្ញា ដល់ ឧសភា។

**245 -ប៉ោលតោកត្រចៀកបៃតង**: Green-eared Barbet *Megalaima faiostrica* ២៤,៥-២៧ ស.ម

ស្រដៀងប៉ោលតោកក្បាលព្រលែត តែមាឌតូចជាង ចំពុះលើរាងខ្មៅ ត្រចៀកខៀវ មានដៅក្រហមនៅលើទ្រូង។ ទីជំរកៈ ព្រៃស្រោង ពាក់កណ្តាលស្រោង ព្រៃរបោះចំរុះ។ ឋានៈ: វត្ត-មានពេញមួយឆ្នាំ មានគ្រប់ទីកន្លែង។ រដូវបន្តពូជ: ចាប់ពីខែ កុម្ភៈ ដល់ ឧសភា ធ្វើរន្ធនៅក្នុងដើមឈើ។

**246 -ប៉ោលតោកថ្ពាល់ខៀវ**: Blue-eared Barbet *Megalaima australis* ១៧-១៨ ស.ម

ឈ្មោល: ថ្ពាល់ខ្មៅ មានដៅលឿងនៅក្រោមភ្នែក បន្ទូលក្បាលពណ៌ខៀវ មានដៅក្រហមនៅលើក្រោម និងក្រោយភ្នែក។ ញី: ស្រដៀងឈ្មោលដែរតែពណ៌ស្រអាប់មិនសូវច្បាស់។ ទីជំរកៈ ព្រៃស្រោង ព្រៃល្បោះ ដំណុះព្រៃក្មេង។ ឋានៈ: វត្តមានពេញមួយឆ្នាំ មានគ្រប់ទីកន្លែង។ រដូវបន្តពូជ: ចាប់ពីខែ មករា ដល់ សីហា ពងចំនួនពី ២ ទៅ ៤។

**247 -ត្រសេះក្បាលត្នោតខ្ចី**: Chestnut-headed Bee-eater *Merops leschenaulti* ២១-២២.៥ ស.ម

បន្ទូលក្បាល ក្បាល និងកញ្ចឹងកពណ៌ត្នោត បំពង់កពណ៌លឿង និងមានដៅពណ៌ត្នោតមួយដុំតូចចំកណ្តាល កន្ទុយរាងការេ ចុងខ្នងពណ៌ខៀវខ្ចី។ ទីជំរកៈ ព្រៃស្រោង ពាក់កណ្តាលស្រោង ព្រៃរបោះ និងព្រៃឫស្សី។ ជីវសាស្ត្រ: ហើរឆាបចាប់សត្វល្អិតជាអាហារ ធ្វើសំបុកតាមរន្ធដី តាម-មាត់ច្រាំងទន្លេ។ ឋានៈ: វត្តមានពេញមួយឆ្នាំ មានគ្រប់ទីកន្លែង។ រដូវបន្តពូជ: ចាប់ពីខែមករា ដល់ ឧសភា។



243 ប៉ោលតោកគូថក្រហម



244 ប៉ោលតោកក្បាលព្រលែត



245 ប៉ោលតោកត្រចៀកបៃតង



246 ប៉ោលតោកថ្ងាសខ្មៅ



247 ត្រដេវក្បាលត្នោតខ្ចី

**248 -ចេកទុំប្រាក់:** Silver Oriole *Oriolus mellianus* ២៨ ស.ម
ឈ្មោល: ដងខ្លួនពណ៌សលាយប្រាក់ ក្បាល ស្លាប ចំពុះ និងជើងពណ៌ខ្មៅ។ ញី: ក្បាល និងស្លាបពណ៌ខ្មៅស្រាលជាងឈ្មោល មានឆ្នូតៗ ខ្មៅច្បាស់ពាសពេញដងខ្លួន។ ទីជំរក: ព្រៃស្រោងពាក់កណ្តាលស្រោង។ ចរាចរ: វត្តមាននៅរដូវប្រាំង មានដោយកំរ និងកត់ត្រាបានក្នុងពេលថ្មីៗនៅតំបន់ភាគខាងលិចនៃប្រទេស។

**249 -ចេកទុំក្បាលខ្មៅ:** Black-hooded Oriole *Oriolus xanthornus*២២-២៥ ស.ម
ឈ្មោល: ខ្លួនពណ៌លឿងទុំ ក្បាលខ្មៅ ចំពុះលឿង។ ញី: បំពង់កពណ៌សមានឆ្នូតៗ ខ្មៅពាសពេញ។ ទីជំរក: ភាគច្រើននៅព្រៃរបោះ ពាក់កណ្តាលស្រោងដំណុះព្រៃក្មេងព្រៃជាំព្រៃស្រល់។ ចរាចរ: វត្តមានពេញមួយឆ្នាំ មានគ្រប់ទីកន្លែង។ រដូវបន្តពូជ: ចាប់ពីខែ កុម្ភៈ ដល់ សីហា។

**250 -ចេកទុំ:** Black-naped Oriole *Oriolus chinensis* ២៤,៥-២៧,៥ ស.ម
មានមាឌមធ្យម ឈ្មោល: ខ្លួនមានពណ៌លឿងភ្លឺ មានឆ្នូតខ្មៅធំកាត់តាមភ្នែក លើកន្ទុយ និងចុងផ្ទាំងស្លាបពណ៌ខ្មៅ។ ញី: ជាទូទៅខ្លួនមានពណ៌លឿងខ្ចីនៅក្រោមពោះមានឆ្នូតៗ ខ្មៅជាជួរៗពាសពេញ។ ទីជំរក: ព្រៃស្រោង ព្រៃរបោះ ព្រៃកោងកាង សួនច្បារ តំបន់វាលលំហដែលមានដើមឈើរាយប៉ាយ។ ចរាចរ: វត្តមានពេញមួយឆ្នាំ មានគ្រប់ទីកន្លែង។ រដូវបន្តពូជ: ចាប់ពីខែធ្នូ ដល់ មិថុនា។

**251 -ចាបចៀបពោះក្រហម:** Red-headed Trogon *Harpactes erythrocephalus* ៣១-៣៥,៥ ស.ម
ឈ្មោល: មានក្បាល និងពោះពណ៌ក្រហម វ័ណ្ឌទ្រូងស ស្លាបពណ៌ប្រផេះក្រម៉ៅ។ ញី: ខុសពីឈ្មោលត្រង់ក្បាល ដើមទ្រូង និងកពណ៌ឈាមជ្រូក រីឯវ័ណ្ឌទ្រូងមានពណ៌សដូចគ្នា កន្ទុយតំរៀបជាកាំពណ៌សឆ្លាស់ខ្មៅ។ ទីជំរក: ព្រៃស្រោង។ ជីវសាស្ត្រ: ចូលចិត្តលាក់ខ្លួនពិបាករកមើលរូបរាងពិតប្រាកដរបស់វា។ ចរាចរ: វត្តមានពេញមួយឆ្នាំ មានគ្រប់ទីកន្លែង។ រដូវបន្តពូជ: ចាប់ពីខែ មិនា ដល់ មិថុនា។

**252 -ចាបចៀបពោះលឿង:** Orange-breasted Trogon *Harpactes oreskios* ២៦,៥-៣១,៥ ស.ម
ឈ្មោល: ក្បាល និងទ្រូងពណ៌បៃតងភ្លឺ ខ្នងពណ៌ត្នោតទុំ។ ញី: ខុសពីឈ្មោលដោយក្បាលពណ៌ត្នោតខ្ចី ទ្រូងពណ៌ប្រផេះ ពោះពណ៌លឿងខ្ចីជាងឈ្មោល។ ទីជំរក: ព្រៃស្រោងពាក់កណ្តាលស្រោង ព្រៃរបោះចំរុះ និងព្រៃឫស្សី។ ចរាចរ: វត្តមានពេញមួយឆ្នាំមានគ្រប់ទីកន្លែង។ រដូវបន្តពូជ: ចាប់ពីខែ មករា ដល់ ឧសភា ធ្វើរន្ធក្នុងដើមឈើ ឬ ដើមឫស្សីងាប់ ពងម្តងចំនួនពី២-៣។



248 ចេកទុំប្រាក់



249 ចេកទុំក្បាលខ្មៅ



250 ចេកទុំ



251 ចាបចៀបពោះក្រហម



252 ចាបចៀបពោះលឿង

**253 -បក្សីខ្មៅស្លាបខៀវ**: Blue-winged Pitta *Pitta moluccensis* ១៨-២០,៥ ស.ម
ពេញវ័យ: បន្ទុលក្បាលឆ្នូតខ្មៅ ឆ្នូតកាត់តាមភ្នែកពណ៌ខ្មៅ ចិញ្ចើម និងបំពង់កស ខ្នងពណ៌បៃតង គែមលើនៃស្លាបពណ៌ខៀវ មានដៅសលើស្លាបសងខាង ផ្នែកគូថពណ៌ក្រហម។ មិនទាន់ពេញវ័យ: ក្បាល និងផ្នែកខ្នងពណ៌ស្រអាប់។ ទីជម្រក: ព្រៃស្រោង ព្រៃចំរុះ ព្រៃឫស្សី។ ស្ថានភាព: វត្តមាននៅរដូវប្រាំង និងសំបូរគ្រប់ទីកន្លែង។ រដូវបន្តពូជ: ចាប់ពីខែ មេសា ដល់ សីហា។

**254 -បក្សីខ្មៅពោះបង្កង់**: Bar-bellied Pitta *Pitta elliotii* ១៩.៥-២១ ស.ម
ឈ្មោល: បន្ទុលក្បាល និងផ្នែកខ្នងពណ៌បៃតង ផ្ទៃមុខពណ៌ខ្មៅ គ្មានពណ៌សនៅលើស្លាបទេ ផ្នែកពោះពណ៌លឿងដែលមានអង្កន់ៗ ខ្មៅចំកណ្តាលពោះ និងក្រោមកន្ទុយពណ៌ខៀវ។ ញី: បន្ទុលក្បាល និងទ្រូងពណ៌ទឹកក្រូច គ្មានពណ៌ខៀវនៅពោះ និងក្រោមកន្ទុយ។ ទីជម្រក: ព្រៃស្រោង ពាក់កណ្តាលស្រោង ព្រៃរបោះចំរុះ ព្រៃឫស្សី។ ជីវសាស្ត្រ: រស់នៅ និងរកចំណីនៅលើដីដោយលាក់ខ្លួន។ ស្ថានភាព: វត្តមានពេញមួយឆ្នាំ កត់ត្រាបាននៅភូមិភាគឥសាននៃប្រទេស។ រដូវបន្តពូជ: ចាប់ពីខែ មេសា ដល់ មិថុនា។

**255 -បក្សីខ្មៅចុងខ្នងខៀវ**: Blue-rumped Pitta *Pitta soror* ២០-២២ ស.ម
ឈ្មោល: ក្បាល កញ្ចឹងក និងចុងខ្នងពណ៌ខៀវ។ ញី: ពណ៌ស្រអាប់ជាងឈ្មោល ផ្នែកខ្នងពណ៌បៃតង ផ្នែកពោះពណ៌ត្នោត។ ទីជម្រក: ព្រៃស្រោង ពាក់កណ្តាលស្រោង ជួនកាលព្រៃរបោះចំរុះ។ ជីវសាស្ត្រ: រស់នៅ និងរកចំណីនៅលើដីដោយលាក់ខ្លួន។ ស្ថានភាព: វត្តមានពេញមួយឆ្នាំ មានគ្រប់ទីកន្លែង។ រដូវបន្តពូជ: ចាប់ពីខែ ឧសភា ដល់ កក្កដា ។

**256 -សត្វចំពុះធំកន្ទុយវែង**: Long-tailed Broadbill *Psarisomus dalhousiae* ២៤-២៧ ស.ម
ដងខ្លួនពណ៌បៃតង បំពង់កពណ៌លឿងភ្លឺ កន្ទុយវែងពណ៌ខៀវ បន្ទុលក្បាលពណ៌ខ្មៅ។ មិនទាន់ពេញវ័យ: បន្ទុលក្បាលពណ៌បៃតងដែរ។ ទីជម្រក: ព្រៃស្រោង។ ជីវសាស្ត្រ: ជាប្រភេទចូលចិត្តលាក់ខ្លួនជាទីបំផុត ភាគច្រើនយើងអាចកត់ត្រាបានតាមរយៈសំលេងរបស់វា។ យើងបានឃើញតែម្តងគត់នៅតំបន់ភ្នំបូកគោឆ្នាំ ១៩៩៩។ ស្ថានភាព: វត្តមានពេញមួយឆ្នាំ ជាប្រភេទកម្រ។ រដូវបន្តពូជ: ចាប់ពីខែ កុម្ភៈ ដល់ កញ្ញា។



253 ប៉ាក់ខៀវស្លាបខៀវ

254 ប៉ាក់ខៀវពោះបង្កង់

255 ប៉ាក់ខៀវចុងខ្នងខៀវ

256 សត្វចំពុះធំកន្ទុយវែង

**257 -ចាបធូនតាខ្នងត្នោតពោះស**: Burmese Shrike *Lanius collurioides* ១៩-២១ ស.ម

ពេញវ័យ: ខ្នងពណ៌ត្នោតចាស់ ក្បាលពណ៌ប្រផេះ ពោះស មានដៅសលើស្លាបទាំងពីរ កន្ទុយសឆ្លាស់ក្រៅ។ ញី: មានពណ៌ស្រអាប់ជាងឈ្មោល ចុងភ្នែកពណ៌ស។ មិនទាន់ពេញវ័យ: ខ្លួនអង្កន់ស្រកាពាសពេញ។ ទីជំរក: ព្រៃគ្រប់ប្រភេទ។ ជីវសាស្ត្រ: ចឹកសត្វល្អិតស៊ី និងសត្វតូចៗនៅលើបន្លា។ ឋានៈ: វត្តមានពេញមួយឆ្នាំ មានគ្រប់ទីកន្លែង។ រដូវបន្តពូជ: ចាប់ពីខែ មិនា ដល់ មិថុនា។

**258 -ឆាគូ ឬ កាពុតញើង**: Common Hoopoe *Upupa epops* ២៧-៣២.៥ ស.ម

មានកំប៉ោយវែង ដែលជាធម្មតាលាតធំនៅពេលកំពុងរកស៊ី ស្លាប និងកន្ទុយមានបង្កង់ខ្មៅស ចំពុះវែងកោង។ ទីជំរក: ព្រៃរបោះ តាមដំណាំកសិកម្ម និងតំបន់ទីវាល។ ជីវសាស្ត្រ: កកាយដីចាប់សត្វល្អិតស៊ីជាអាហារ។ ឋានៈ: វត្តមានពេញមួយឆ្នាំ មានគ្រប់ទីកន្លែង។ រដូវបន្តពូជ: ចាប់ពីខែ កុម្ភៈ ដល់ ឧសភា ។

**259 -ទៀវព្រៃ**: Dollarbird *Eurystomus orientalis* ២៧.៥-៣១.៥ ស.ម

ខ្លួនពណ៌បៃតងក្រម៉ៅ ចំពុះធំពណ៌ក្រហម និងមានដៅសនៅស្លាបសងខាង ជើងក្រហម។ ទីជំរក: ព្រៃស្រោង ពាក់កណ្តាលស្រោង ព្រៃល្បោះ និងដំណុះព្រៃក្មេង។ ជីវសាស្ត្រ: ហើរឆាបស៊ីសត្វល្អិតជាចំណី។ ឋានៈ: វត្តមានពេញមួយឆ្នាំ មានគ្រប់ទីកន្លែង។ រដូវបន្តពូជ: ចាប់ពីខែ កុម្ភៈ ដល់ មិថុនា។

**260 -ខ្ញប់ចឺព្រៃ**: Forest Wagtail *Dendronanthus indicus* ១៧-១៨ ស.ម

បន្ទុលក្បាល និងខ្នងពណ៌ត្នោតខ្ចី មានឆ្នូតលើស្លាបពណ៌ស និងខ្មៅ និងរំណ្ហកខ្មៅ។ ទីជំរក: ព្រៃស្រោង ព្រៃរបោះ តាមដងផ្លូវតូចធំក្នុងព្រៃ និងព្រៃកោងកាង។ ជីវសាស្ត្រ: បក់កន្ទុយឡើងចុះពេលរកចំណី។ ឋានៈ: ជាប្រភេទឆ្លងកាត់ មានគ្រប់ទីកន្លែង។

**261 -ក្រួចអិនទ្រូងឆ្នូតខ្មៅ**: Olive-backed Pipit *Anthus hodgsoni* ១៦-១៧ ស.ម

ខ្នងពណ៌បៃតងខ្ចី និងមានអុជខ្មៅៗ ពាសពេញទ្រូង ចំហៀងទ្រូង និងចិញ្ចើមស។ ទីជំរក: តំបន់ព្រៃស្រឡះ តាមផ្លូវក្នុងព្រៃ ជាយព្រៃ និងដំណាំកសិកម្ម។ ឋានៈ: ជាប្រភេទឆ្លងកាត់ មានគ្រប់ទីកន្លែង។ រដូវបន្តពូជ: ចាប់ពីខែ ឧសភា ដល់ កក្កដា។



257 ចាបជួនតាខ្នងត្នោតពោះស



258 បាគូ ឬ កាពុតញើង



259 ទៀវព្រៃ



260 ខ្ទប់ដីព្រៃ



261 ក្រួចអិនទ្រូងឆ្នូតខ្មៅ

**262 -ល្វាទេកព្រៃ**: White-rumped Shama *Copsychus malabaricus* ២១.៥-២៨ ស.ម

ឈ្មោល: ក្បាល ទ្រូង ខ្នង និងកន្ទុយពណ៌ខៀវចាស់ ចុងខ្នងពណ៌ស។ ញី: ពណ៌ស្រអាប់ជាងឈ្មោល ក្បាល ទ្រូង និងខ្នងពណ៌ប្រផេះក្រម៉ៅ(ខៀវខ្ចី)។ ទីជំរក: ព្រៃស្រោង ពាក់កណ្តាលស្រោង ព្រៃឫស្សី។ ស្ថានៈ: វត្តមានពេញមួយឆ្នាំ មានគ្រប់ទីកន្លែង។ រដូវបន្តពូជ: ចាប់ពីខែ មិនា ដល់ កញ្ញា។

**263 -ចកវិកកំពោយស**: White-crested Laughingthrush *Garrulax leucolophus* ២៦-៣១ ស.ម

ក្បាល បំពង់ក ទ្រូង និងកំពោយ ពណ៌ស ចំពុះខ្មៅ មានឆ្នូតខ្មៅកាត់តាមភ្នែក។ ទីជំរក: គ្រប់ប្រភេទព្រៃ។ ជីវសាស្ត្រ: រស់នៅជាហ្វូងស្រែកឮខ្លាំង។ ស្ថានៈ: វត្តមានពេញមួយឆ្នាំ មានសំបូរគ្រប់ទីកន្លែង។ រដូវបន្តពូជ: ចាប់ពីខែ កុម្ភៈ ដល់ សីហា។

**264 -ចកវិកកម្ពុជា**: Cambodian Laughingthrush *Garrulax ferrarius* ២៨-៣០ ស.ម

ស្រដៀងនឹង Black-hooded Laughingthrush ប៉ុន្តែក្បាលមានពណ៌ខ្មៅ ផ្ទៃកពោះ និងដើមកមានពណ៌ប្រផេះក្រម៉ៅ មានដៅពណ៌សមួយជុំនៅក។ ទីជំរក: ព្រៃស្រោង។ ស្ថានៈ: ជាប្រភេទមានក្នុងតំបន់។ កំណត់ត្រាតែម្តងគត់នៅតំបន់ជួរភ្នំក្រវ៉ាញនៃប្រទេសកម្ពុជាប៉ុណ្ណោះ។

**265 -ចកវិកវណ្ណទ្រូងខ្មៅ**: Lesser Necklaced Laughingthrush *Garrulax monleger* ២៦.៥-៣១.៥ ស.ម

បំពង់កពណ៌ស មានស្នាមឆ្នូតខ្មៅចាប់ពីគល់ចំពុះកាត់ភ្នែករហូតដល់ទ្រូង និងមានចិញ្ចើមស។ ទីជំរក: គ្រប់ប្រភេទព្រៃ។ ជីវសាស្ត្រ: រស់នៅជាហ្វូងស្រែកឮខ្លាំង។ ស្ថានៈ: វត្តមានពេញមួយឆ្នាំ មានសំបូរនៅគ្រប់ទីកន្លែង។ រដូវបន្តពូជ: ចាប់ពីខែ មិនា ដល់ សីហា។



262 ល្វាចេកព្រៃ



263 ចកវិកកំប៉ោយ ស



264 ចកវិកកម្ពុជា



265 ចកវិកវីណ្ណទ្រូងខ្មៅ

**266 -ចេកទេសផ្កាឈូក**: Swinhoe's Minivet *Pericrocotus cantonensis* ១៩ ស.ម

ឈ្មោល: ស្រដៀងចេកទេសខ្មៅសតែដងខ្លួន និងចុងខ្នងពណ៌លឿងព្រឿងៗ។ ញី: ស្រដៀងឈ្មោលតែពណ៌ស្រអាប់ជាង។ ទីជំរក: ព្រៃស្រោង ពាក់កណ្ដាលស្រោង ព្រៃរបោះ តាមជាយព្រៃ។ ឋានៈ: ជាប្រភេទឆ្លងកាត់ វត្តមានច្រើននៅភាគនិរតីនៃប្រទេស។

**267 -ចេកទេសធំ**: Scarlet Minivet *Pericrocotus flammeus* ១៧-២១.៥ ស.ម

មាឌធំជាងចេកទេសដទៃ ឈ្មោល: ក្បាល ក និងស្លាបពណ៌ខ្មៅ ផ្ចិតពោះ ចុងខ្នង និងកន្ទុយពណ៌ក្រហម មានដៅក្រហមធំលើស្លាប។ ញី: ក្បាលប្រផេះ ថ្ងាសលឿង ខ្លួនលឿង។ ទីជំរក: ព្រៃស្រោង ពាក់កណ្ដាលស្រោង ព្រៃជាំ ព្រៃរបោះ។ ឋានៈ: វត្តមានពេញមួយឆ្នាំ មានគ្រប់ទីកន្លែង។ រដូវបន្តពូជ: ចាប់ពីខែ មិថុនា ដល់ កក្កដា។

**268 -ចេកទេសតូច**: Small Minivet *Pericrocotus cinnamomeus* ១៤.៥-១៦ ស.ម

ឈ្មោល: បន្ទលក្បាល និងខ្នងពណ៌ប្រផេះ បំពង់កពណ៌ខ្មៅ ផ្ចិតពោះ និងចុងខ្នងពណ៌ក្រហម។ ញី: ក្បាលពណ៌ប្រផេះ ផ្ចិតពោះ និងចុងខ្នងពណ៌ទឹកក្រូច ។ ទីជំរក: ព្រៃល្បោះ តំបន់ឆ្នេរតាមជាយព្រៃ ព្រៃស្រល់។ ជីវសាស្ត្រ: ទុំខ្ពស់លើដើមឈើជាហ្វូងតូចៗ។ ឋានៈ: វត្តមានពេញមួយឆ្នាំ មានសំបូរគ្រប់ទីកន្លែង។ រដូវបន្តពូជ: ចាប់ពីខែ មិនា ដល់ កញ្ញា។

**269 -អាល់អែកស្លាបខ្មៅឆ្នូតស**: Bar-winged Flycatcher Shrike *Hemipus picatus* ១២.៥-១៤.៥ ស.ម

ឈ្មោល: បន្ទលក្បាល និងខ្នងពណ៌ខ្មៅ ចុងខ្នង និងគូថពណ៌ស និងឆ្នូតសធំតាមបណ្ដោយលើស្លាប។ ញី: បន្ទលក្បាល និងខ្នងពណ៌ប្រផេះ។ ទីជំរក: ព្រៃស្រោង ពាក់កណ្ដាលស្រោង ព្រៃជាំ ជាយព្រៃ ព្រៃឫស្សី។ ឋានៈ: វត្តមានពេញមួយឆ្នាំ មានគ្រប់ទីកន្លែង។ រដូវបន្តពូជ: ចាប់ពីខែ កុម្ភៈ ដល់ ឧសភា។

## ប្រភេទសត្វស្លាបរស់នៅតំបន់ព្រៃ



266 ចេកទេសផ្កាឈូក

267 ចេកទេសធំ

268 ចេកទេសតូច

269 អល់អែកស្លាបខ្មៅឆ្នូតស

**270 -ចាបកន្លង់តូចពីងពាង:** Little Spiderhunter *Arachnothera longirostra* ១៦-១៦,៥ ស.ម

មាឌតូច ចំពុះវែងកោង ក្បាលពណ៌ប្រផេះចាស់ បំពង់កស ផ្នែកពោះពណ៌លឿង និងផ្នែកខ្នងពណ៌បៃតងខ្ចី។ ទីជំរក: ព្រៃស្រោង ពាក់កណ្តាលស្រោង តាមជាយព្រៃ សួនច្បារ និងតំបន់កសិកម្ម។ ឋានៈ: វត្តមានពេញមួយឆ្នាំ មានគ្រប់ទីកន្លែង។ រដូវបន្តពូជ: ចាប់ពីខែធ្នូដល់តុលា។

**271 -ចេកចៅស្លាបខ្មៅស:** Common Iora *Aegithina tiphia* ១២-១៤,៥ ស.ម

ផ្នែកខ្នងពណ៌បៃតងខ្ចី ផ្នែកពោះពណ៌លឿង ស្លាបខ្មៅ និងមានឆ្នូតសអង្កត់ពីរលើស្លាប ពេលបន្តពូជឈ្មោលមានបន្ទូលក្បាលខ្មៅ។ ទីជំរក: តំបន់វាល ព្រៃកោងកាង តំបន់លិចទឹក ទីក្រុង សួនច្បារ និងដំណាំកសិកម្ម។ ជីវសាស្ត្រ: រកស៊ីនៅលើចុងឈើ ជាធម្មតានៅក្នុងស្លឹក។ ឋានៈ: វត្តមានពេញមួយឆ្នាំ មានគ្រប់ទីកន្លែង។ រដូវបន្តពូជ: ចាប់ពីខែ មករា ដល់ កក្កដា។

**272 -ចេកខ្ចីស្លាបខៀវ:** Blue-winged Leafbird *Chloropsis cochinchinensis* ១៦,៥-១៨,៥ ស.ម

ឈ្មោល: ដងខ្លួនសំបុរបៃតងខ្ចី និងមានស្លាបហើរទី១ទី២ពណ៌ខៀវភ្លឺ ផ្នែកខ្នង និងកន្ទុយពណ៌បៃតងចាស់ មានដៅពណ៌ខ្មៅនៅបំពង់ក។ ញី: គ្មានដៅខ្មៅនៅបំពង់កទេ ស្លាប និងកន្ទុយពណ៌បៃតងខ្ចីជាងឈ្មោល។ ទីជំរក: ព្រៃស្រោង ព្រៃរបោះចំរុះ តាមជាយព្រៃ និងដំណុះព្រៃក្មេង។ ឋានៈ: វត្តមានពេញមួយឆ្នាំ មានគ្រប់ទីកន្លែង។ រដូវបន្តពូជ: ចាប់ពីខែ មេសា ដល់ សីហា។

**273 -ចេកខ្ចីថ្ងាសភ្លើង:** Golden-fronted Leafbird *Chloropsis aurifrons* ១៨-១៩ ស.ម

ជាទូទៅខ្លួនមានពណ៌បៃតងចាស់ ថ្ងាសពណ៌ទឹកក្រូច នៅគល់ស្លាបស្មាមានពណ៌ខៀវភ្លឺ ចំពុះរាងវែងខុប។ ទីជំរក: ព្រៃរបោះ ព្រៃរបោះចំរុះ ជួនកាលមាននៅព្រៃស្រោង និងពាក់កណ្តាលស្រោងផងដែរ។ ឋានៈ: វត្តមានពេញមួយឆ្នាំ មានគ្រប់ទីកន្លែង។ រដូវបន្តពូជ: ចាប់ពីខែ កុម្ភៈ ដល់ កក្កដា ។





270 ចាបកន្ទុយតូចពីងពាង



271 ចេកចៅស្លាបខ្មៅស



272 ចេកខ្ចីស្លាបខៀវ



273 ចេកខ្ចីថ្ងាសភ្លើង

**274 -បព្ចចក្បាលខ្មៅចុងខ្នងស:** Sooty-headed Bulbul *Pycnonotus aurigaster* ១៩-២១ ស.ម

ពេញវ័យ: ផ្ទៃមុខ និងបន្ទួលក្បាលពណ៌ខ្មៅ ក្បាលមានកំប៉ោយបន្តិច ខ្លួនពណ៌ប្រផេះ គូថពណ៌ក្រហម ចុងខ្នងស។ មិនទាន់ពេញវ័យ: គូថពណ៌លឿង។ ទីជំរក: ដំណុះព្រៃក្មេង គុម្ពោតព្រៃវាលស្មៅ ដំណាំកសិកម្ម។ ជីវសាស្ត្រ: ស៊ីផ្លែឈើ ហើរជាហ្វូង។ ឋានៈ: វត្តមានពេញមួយឆ្នាំ មានគ្រប់ទីកន្លែង។ រដូវបន្តពូជ: ចាប់ពីខែ មិនា ដល់ មេសា។

**275 -បព្ចចខ្មៅ:** Black Bulbul *Hypsipetes leucocephalus* ២៣.៣-២៦.៥ ស.ម

ដងខ្លួនខ្មៅទាំងអស់ចំពុះក្រហម ជើងក្រហម ពូជខ្លះមានក្បាលពណ៌ស។ មិនទាន់ពេញវ័យ: ដងខ្លួនទាំងមូលពណ៌ប្រផេះ។ ទីជំរក: ព្រៃស្រោង ព្រៃរបោះចំរុះ ព្រៃស្រល់។ ឋានៈ: វត្តមាននៅរដូវប្រាំង។ រដូវបន្តពូជ: ចាប់ពីខែ មេសា ដល់ មិថុនា។

**276 -បព្ចចបំពង់កសត្រូងលឿងចាស់:** Puff-throated Bulbul *Criniger pallidus* ២២-២៥ ស.ម

មានកំប៉ោយពណ៌ត្នោតទុំ បំពង់កពណ៌ស ផ្នែកពោះ និងខ្នងពណ៌បៃតងខ្ចី គូថលឿង។ ទីជំរក: ព្រៃស្រោង។ ជីវសាស្ត្រ: ស៊ីផ្លែឈើជាហ្វូងក្នុងព្រៃ។ ឋានៈ: វត្តមានពេញមួយឆ្នាំ មានគ្រប់ទីកន្លែង។ រដូវបន្តពូជ: ចាប់ពីខែ ឧសភា ដល់ កញ្ញា។

**277 -បព្ចចក្បាលខ្មៅកំប៉ោយ:** Black-crested Bulbul *Pycnonotus melanicterus* ១៨.៥-១៩.៥ ស.ម

ក្បាលខ្មៅ និងកំប៉ោយត្រង់ ផ្នែកខ្នងពណ៌លឿងក្រម៉ៅ ផ្នែកពោះពណ៌លឿង។ ទីជំរក: ព្រៃស្រោង ព្រៃរបោះចំរុះ តាមជាយព្រៃ ដំណុះព្រៃក្មេង។ ជីវសាស្ត្រ: ស៊ីផ្លែឈើជាហ្វូងក្នុងព្រៃ។ ឋានៈ: វត្តមានពេញមួយឆ្នាំ មានគ្រប់ទីកន្លែង។ រដូវបន្តពូជ: ចាប់ពីខែ មករា ដល់ កញ្ញា។

**278 -បព្ចចពុកចាត់លឿង:** Stripe-throated Bulbul *Pycnonotus finlaysoni* ១៩-២០ ស.ម

ស្នាមឆ្នូតៗពណ៌លឿងនៅលើមុខ បំពង់ក គូថ និងថ្ពាស ខ្លួនពណ៌ប្រផេះបៃតង។ ទីជំរក: ដំពុះព្រៃក្មេង ព្រៃស្រោង ព្រៃរបោះ និងតាមជាយព្រៃ។ ឋានៈ: វត្តមានពេញមួយឆ្នាំ មានគ្រប់ទីកន្លែង។ រដូវបន្តពូជ: ចាប់ពីខែ កុម្ភៈ ដល់ កញ្ញា។



274 ពពិចក្បាលខ្មៅចុងខ្នងស



275 ពពិចខ្មៅ



276 ពពិចបំពង់កស ទ្រូងលឿងចាស់



277 ពពិចក្បាលខ្មៅកំប៉ោយ



278 ពពិចពុកមាត់លឿង

**279 -អន្ទេបខ្មៅថ្លែក:** Bronzed Drongo *Dicrurus aeneus* ២២-២៣.៥ ស.ម
មាឌតូចជាងអន្ទេបដទៃ ខ្លួនខ្មៅភ្លឺរលោង កន្ទុយឆែកល្មម។ ទីជំរក: ព្រៃស្រោង ពាក់កណ្ដាលស្រោង ដំណុះព្រៃក្មេង។ ជីវភាព: ទុំលើទ្រនុំខ្ពស់ ដើម្បីរកចាប់សត្វល្អិត។ ឋានៈ: វត្តមានពេញមួយឆ្នាំ មានគ្រប់ទីកន្លែង។ រដូវបន្តពូជ: ចាប់ពីខែ មិនា ដល់ កក្កដា។

**280 -អន្ទេបទងកន្ទ្រៃ:** Greater Racket-tailed Drongo *Dicrurus paradiseus* ៣៣-៣៥.៥ ស.ម
ពេញវ័យ: សំបុរខ្មៅរលោង មានកំប៉ោយ កន្ទុយទងកន្ទ្រៃ។ ពេលមិនទាន់ពេញវ័យ: កន្ទុយឆែកល្មម។ ទីជំរក: ព្រៃស្រោង ពាក់កណ្ដាលស្រោង ព្រៃរបោះ និងព្រៃជាំ។ ឋានៈ: វត្តមានពេញមួយឆ្នាំ មានគ្រប់ទីកន្លែង។ រដូវបន្តពូជ: ចាប់ពីខែ កុម្ភៈ ដល់ កក្កដា។

**281 -អន្ទេបកំប៉ោយខ្សែ:** Spangled Drongo *Dicrurus hottentottus* ២៩-៣៣ ស.ម
សំបុរខ្មៅសុទ្ធ មាឌធំជាងអន្ទេបដទៃ ចំពុះរាងកោងខុប កន្ទុយរាងត្រីកោណ។ ទីជំរក: ព្រៃស្រោង ពាក់កណ្ដាលស្រោង និងព្រៃ របោះ។ ឋានៈ: វត្តមានពេញមួយឆ្នាំ មានគ្រប់ទីកន្លែង។ រដូវបន្តពូជ: ចាប់ពីខែ មេសា ដល់ មិថុនា។

**282 -អន្ទេបប្រផេះ:** Ashy Drongo *Dicrurus leucophaeus* ២៩ ស.ម
នៅកម្ពុជាមានពីរប្រភេទ ដែលយើងកត់ត្រាបាន។ ប្រភេទទី១: Leucogensis-មានពណ៌ប្រផេះស្រាល ថ្ងាសខ្មៅ ដៅសជុំវិញភ្នែក ត្រចៀក និងតួថស ចុងស្លាបទី១ខ្មៅ ភ្នែកក្រហម។ ប្រភេទទី២: Salangensis-ស្រដៀង Leucogensis ដែរតែសំបុរដងខ្លួនទាំង មូលពណ៌ស្រគាំជាង គុម្ពត្រចៀកឆ្វតសព្រាល១។ ទីជំរក: តំបន់វាល ប្រភេទព្រៃរិចរិល តាមជាយព្រៃកោងកាង និងតំបន់ឆ្នេរ។ ឋានៈ: ក្នុងចំនោម២ប្រភេទនេះ ប្រភេទទី១ Leucogensis វត្តមាននៅរដូវប្រាំងនិង ប្រភេទទី២ Salangensis វត្តមានពេញមួយឆ្នាំ។ ពត៌មានផ្សេងទៀតពុំទាន់ដឹងច្បាស់នៅឡើយ។ រដូវបនពូជ: ចាប់ពីខែមិនា ដល់ មិថុនា។



279 អន្ទេបខ្មៅផ្លែក

280 អន្ទេបទងកន្ទ្រៃ

281 អន្ទេបកំប៉ោយខៀវ

282 អន្ទេបប្រផេះ

**283 -ចាបថ្ងូនតាបំពង់កប៉ោង**: Puff-throated Babbler *Pellorneum ruficeps* ១៦-១៨ ស.ម

បន្ទូលក្បាលពណ៌ច្រែះ ខ្នងពណ៌ត្នោតទុំ ចិញ្ចើមធំវែងសស្រអាប់ ពោះសមានឆ្នូតខ្មៅនៅដើមទ្រូង និងចំហៀងខ្លួន។ ទីជំរក: ព្រៃរបោះចំរុះ ព្រៃស្រោង គុម្ពោតព្រៃ និងព្រៃឫស្សី។ ឋានៈ: វត្តមានពេញមួយឆ្នាំ មានសំបូរគ្រប់ទីកន្លែង។ រដូវបន្តពូជ: ចាប់ពីខែ មករា ដល់ សីហា។

**284 -ចាបថ្ងូនតាទូរស័ព្ទ**: Striped Tit Babbler *Macronous gularis* ១២.៥-១៤ ស.ម

បន្ទូលក្បាលពណ៌ច្រែះ ផ្នែកពោះពណ៌លឿងព្រលែតដោយមានស្នាមឆ្នូតៗពណ៌ត្នោត មានចិញ្ចើមលឿងវែងកាត់តាមភ្នែក។ ទីជំរក: គ្រប់ប្រភេទព្រៃ។ ឋានៈ: វត្តមានពេញមួយឆ្នាំ មានគ្រប់ទីកន្លែង។ រដូវបន្តពូជ: ចាប់ខែ ធ្នូ ដល់ សីហា។

**285 -ចាបថ្ងូនតាត្រចៀកប្រាក់**: Silver-cared Mesia *Leiothrix argentauris* ១៦,៥-១៨ ស.ម

ឈ្មោល galbana: ចំពុះ ថ្ងាស ក និងផ្នែកពោះពណ៌លឿងស្រស់ បន្ទូលក្បាលខ្មៅ ត្រចៀកពណ៌ប្រាក់ ស្លាបពណ៌ប្រផេះក្រហមលឿង ចុងខ្នង និងគូថពណ៌ក្រហម។ ញី: ស្រដៀងឈ្មោលតែពណ៌ស្លេកជាង។ ឈ្មោល cunbaci: ថ្ងាសលឿងធំជាង។ ឈ្មោល ricketti: បំពង់កក្រហម ក និងទ្រូងពណ៌លឿងទុំ។ ទីជំរក: នៅតាមជាយព្រៃស្រោង គុម្ពោតព្រៃ ដំណុះព្រៃក្មេង។ ឋានៈ: វត្តមានពេញមួយឆ្នាំ មាននៅភាគខាងកើតប្រទេសកម្ពុជា។ រដូវបន្តពូជ: ចាប់ពីខែ កុម្ភៈ ដល់ សីហា។

**286 -ចាបថ្ងូនតាកំប៉ោយគូថលឿង**: White-bellied Yuhina *Yuhina zantholeuca* ១២-១៣.៥ ស.ម

ខ្នងពណ៌បៃតង-លឿងខ្ចី មានឧល្អិត មានកំប៉ោយខ្លី ផ្នែកពោះពណ៌សព្រលែត គូថពណ៌លឿង។ ទីជំរក: ព្រៃស្រោង ព្រៃរបោះចំរុះ។ ឋានៈ: វត្តមានពេញមួយឆ្នាំ មានគ្រប់ទីកន្លែង។ រដូវបន្តពូជ: ចាប់ពីខែ កុម្ភៈ ដល់ មិថុនា។



283 ចាបដូនតាបំពង់កប៉ោង



284 ចាបដូនតាទូរស័ព្ទ



285 ចាបដូនតាត្រចៀកប្រាក់



286 ចាបដូនតាកំប៉ោយតូចលឿង

**287 -តចិចបន្ទូលក្បាលខ្មៅ**: Black-naped Monarch *Hypothymis azurea* ១៦-១៧,៥ ស.ម

ឈ្មោល: មានពណ៌ខៀវភ្លឺ ដោយមានពណ៌ខ្មៅនៅលើបន្ទូលក្បាលផ្នែកពយខាងក្រោយ ថ្ងាស និងវណ្ណ៍ទ្រូងខ្មៅ។ ញី: មានក្បាលពណ៌ខៀវស្រអាប់ ខ្នងពណ៌ត្នោត និងគ្មានដៅពណ៌ខ្មៅអ្វីទាំងអស់។ ទីជំរក: គ្រប់ប្រភេទព្រៃទាំងអស់រាប់បញ្ចូលទាំងព្រៃកោងកាង។ ឋានៈ: វត្តមានពេញមួយឆ្នាំ មានគ្រប់ទីកន្លែង។ រដូវបន្តពូជ: ចាប់ពីខែ មិនា ដល់ សីហា។

**288 -ចាបស៊ីរុយក្បាលប្រផេះ**: Grey-headed Canary Flycatcher *Culicicapa ceylonensis* ១១,៥-១៣ ស.ម

ជាទូទៅក្បាល និងដើមទ្រូងមានពណ៌ប្រផេះ ផ្នែកពោះពណ៌លឿងភ្លឺ ផ្នែកខ្នងពណ៌បៃតងខ្ចី។ ទីជំរក: ព្រៃស្រោង ពាក់កណ្តាលស្រោង និងព្រៃរបោះ។ ឋានៈ: វត្តមានពេញមួយឆ្នាំមានគ្រប់ទីកន្លែង។ រដូវបន្តពូជ: ចាប់ពីខែ មិនា ដល់ មិថុនា។

**289 -ចាបស៊ីរុយវាលទំនាប**: Tickell's Blue Flycatcher *Cyornis ticklelliae* ១៣,៥-១៥,៥ ស.ម

ឈ្មោល: ដើមទ្រូងមានពណ៌ទឹកក្រូចចាស់ និងខ្នងពណ៌ខៀវចាស់ ពោះស។ ញី: ផ្នែកខ្នងពណ៌ខៀវខ្ចីទៅប្រផេះស្រាល។ ទីជំរក: ព្រៃស្រោង ពាក់កណ្តាលស្រោង និងព្រៃរបោះ។ ឋានៈ: វត្តមានពេញមួយឆ្នាំ មានគ្រប់ទីកន្លែង។ រដូវបន្តពូជ: ចាប់ពីខែ មេសា ដល់ សីហា។

**290 -ចាបស៊ីរុយខៀវខ្ចីលាត**: Verditer Flycatcher *Eumyias thalassina* ១៥-១៧ ស.ម

ឈ្មោល: ខ្លួនមានពណ៌ខៀវខ្ចី និងដៅខ្មៅនៅដើមភ្នែក។ ញី: ពណ៌កាន់តែខៀវខ្ចីជាងឈ្មោល។ ទីជំរក: ព្រៃស្រោង ព្រៃចំការ។ ឋានៈ: វត្តមានពេញមួយឆ្នាំ មានគ្រប់ទីកន្លែង។ រដូវបន្តពូជ: ចាប់ពីខែ មេសា ដល់ កក្កដា។

**291 -ចេកទុំខៀវ**: Asian Fairy Bluebird *Irena puella* ២៤,៥-២៦,៥ ស.ម

ឈ្មោល: ផ្នែកខ្នង និង គូថពណ៌ខៀវចាស់ ស្លាប កន្ទុយ ពោះពណ៌ខ្មៅ។ ញី: មានពណ៌ខៀវខ្ចីជាងឈ្មោល។ ទីជំរក: ព្រៃស្រោង និងពាក់កណ្តាលស្រោង។ ឋានៈ: វត្តមានពេញមួយឆ្នាំ មានគ្រប់ទីកន្លែង។ រដូវបន្តពូជ: ចាប់ពីខែ កុម្ភៈ ដល់ ឧសភា។





287 ពពិចបន្ទូលក្បាលខ្មៅ



288 ចាបស៊ីរុយក្បាលប្រផេះ



289 ចាបស៊ីរុយវាលទំនាប



290 ចាបសីរុយខៀវខ្ចីលាត



291 ចេកទុំខៀវ

**292 -កញ្ចៀចកន្ទុយត្នោត**: Chestnut-tailed Starling *Sturnus malabaricus* បណ្ដោយខ្លួន ១៨.៥-២០.៥ ស.ម ។

កន្ទុយផ្លាស់ក្រៅពណ៌ត្នោត ក្បាលពណ៌ប្រផេះព្រលែត គល់ចំពុះខៀវចុងលឿង។ មានដៅសនៅចុងស្លាបស្មាសងខាង។ ទីជំរក: តំបន់ព្រៃស្រឡះ ទីវាលមានដើមឈើរាយប៉ាយៗ។ ចរាចរ: វត្តមាននៅរដូវប្រាំង មានគ្រប់ទីកន្លែង។ រដូវបន្តពូជ: ចាប់ពីខែ មេសា ដល់ មិថុនា។

**293 -សារិកាកែវវង**: Hill Myna *Gracula religiosa* បណ្ដោយខ្លួន ២៧-៣១ ស.ម ។

ខ្លួនពណ៌ខ្មៅរលោង ដោយមានស្បែកមុខ ពណ៌លឿង មានដៅសមួយដុំលើស្លាបនៅពេលហើរ។ ទីជំរក: ព្រៃស្រោង ព្រៃរបោះ តាមជាយព្រៃ និងតំបន់កាប់ឆ្ការ។ ជីវសាស្ត្រ: ជាប្រភេទកំពុងរងការគំរាមកំហែងយ៉ាងខ្លាំងដោយការទាក់ចាប់កូនមកចិញ្ចឹមដើម្បីលក់ ព្រោះជាប្រភេទដែលចេះនិយាយ។ ចរាចរ: វត្តមានពេញមួយឆ្នាំ មានគ្រប់ទីកន្លែង។ រដូវបន្តពូជ: ចាប់ពីខែ កញ្ញា ដល់ មិថុនា។

**294 -សារិកាកែវក្បាលលឿង**: Golden-crested Myna *Ampeliceps coronatus* ២២-២៤ ស.ម ។

ពេញវ័យ: ដងខ្លួនខ្មៅរលោង បន្ទូលក្បាល និងកពណ៌លឿង មានដៅពណ៌លឿងមួយដុំនៅលើស្លាប ជុំវិញរង្វង់ភ្នែកពណ៌លឿង។ ញី: បន្ទូលក្បាល និងកមានដៅលឿងបន្តិចបន្តួចប៉ុណ្ណោះ។ ទីជំរក: ព្រៃស្រោង និងព្រៃរបោះចំរុះ តាមជាយព្រៃ។ ចរាចរ: វត្តមានពេញមួយឆ្នាំ របាយមានច្រើននៅខេត្តមណ្ឌលគិរី និងចំណែកតំបន់គិរីរម្យយើងកត់ត្រាតែម្ដងគត់ ក្នុងរយៈប៉ុន្មានឆ្នាំចុងក្រោយនេះ។ ជីវសាស្ត្រ: ជាប្រភេទកំពុងរងការគំរាមកំហែងដោយការទាក់ចាប់យកមកចិញ្ចឹម ឬ លក់ចេញទៅក្រៅប្រទេសព្រោះជាប្រភេទដែលចេះនិយាយ។ រដូវបន្តពូជ: ចាប់ពីខែ មេសា ដល់ សីហា។





292 កញ្ចៀកន្ទុយត្នោត

293 សារិកាកែវវង



294 សារិកាកែវក្បាលលឿង

**295 -ចាបតេតព្រៃ:** Dark-necked Tailorbird *Orthotomus atrogularis* ខ្លួន ១០,៥-១២ ស.ម

ពណ៌នា: ស្រដៀងចាបតេតដែរតែមានបំពង់កពណ៌ខ្មៅ ផ្នែកខ្នងពណ៌បៃតងភ្លឺ គ្មានចិញ្ចើមសទេ។ ញី: បំពង់កពណ៌ខ្មៅព្រាលៗ។ ទីជម្រក: ព្រៃស្រោង ពាក់កណ្ដាលស្រោង ដំណុះព្រៃក្មេង គុម្ពោតព្រៃ ព្រៃកោងកាង សួនច្បារ។ ឋានភាព: វត្តមានពេញមួយឆ្នាំ មានគ្រប់ទីកន្លែង។ រដូវបន្តពូជ: ចាប់ពីខែ កុម្ភៈ ដល់ កញ្ញា។

**296 -ចាបចង្កូវស្លាបពណ៌ច្រេះ:** Rufescent Prinia *Prinia rufescens* ១០,៥-១២,៥ ស.ម

ដងខ្លួនពណ៌ច្រេះ ចិញ្ចើមស កន្ទុយតំរៀបជាកាំ។ ទីជម្រក: វាលស្មៅ តាមជាយព្រៃ ព្រៃរបោះ។ ឋានភាព: វត្តមានពេញមួយឆ្នាំ មានគ្រប់ទីកន្លែង។ រដូវបន្តពូជ: ចាបពីខែ មករា ដល់ កញ្ញា។

**297 -ចាបថ្ងូនតាចំពុះធំវែង:** Arctic Warbler *Phylloscopus borealis* ១២,៥-១៣ ស.ម

ផ្នែកខ្នង ពណ៌បៃតងខ្ចី ចិញ្ចើមវែងលឿង ពោះពណ៌សព្រលែត និង ទ្រូងពណ៌ប្រផេះ។ មានឆ្នូតស្លាបពីរមួយរាងធំហើយវែង និងមួយទៀតខ្លី និងចុងស្លាបស្រួច។ ទីជម្រក: ព្រៃស្រោង និងព្រៃល្បោះ ដំណុះព្រៃក្មេង សួនច្បា ព្រៃកោងកាង តាមធម្មតា នៅតាមតំបន់ទំនាបៗ។ ជីវសាស្ត្រ: ជាសត្វផ្លាស់ប្ដូរទីកន្លែងច្រើន។ ឋានភាព: វត្តមាន នៅរដូវប្រាំង។

**298 -ចាបថ្ងូនតាក្បាលប្រផេះ:** Pale-legged Leaf Warbler *Phylloscopus tenellipes* ១២,៥-១៣ ស.ម

មានមាឌប្រ ហាក់ប្រហែលនឹង Arctic និង Greenish Warbler ដែរប៉ុន្តែវា មានបន្ទូលក្បាលពណ៌ចាស់ ចុងខ្នងពណ៌ត្នោតខ្ចីជា ទូទៅមានឆ្នូតស្លាបពីរ។ ទីជម្រក: ព្រៃរបោះចំរុះ ព្រៃស្រោង និងពាក់កណ្ដាលស្រោង។ ឋានភាព: វត្តមាននៅរដូវប្រាំង មានគ្រប់ទីកន្លែង។



295 ចាបតេតព្រៃ



296 ចាបដង្កូវស្លាបពណ៌ច្រេះ



297 ចាបដូនតាចំពុះធំវែង



298 ចាបដូនតាក្បាលប្រផេះ

**299 –ចាបកន្លង់ទ្រូងភ្លើង:** Fire-breasted Flowerpecker *Dicaeum ignipectus* ៨-៩ ស.ម
ឈ្មោល: ផ្នែកខ្នងមានពណ៌ខៀវក្រម៉ៅរលោង ផ្នែកទ្រូងមានវិល្លក្រហម មានឆ្នូតខ្មៅចំកណ្ដាលពោះ និងមុខខ្មៅ។ ញី: ក្បាល និង ខ្នងពណ៌បៃតងខ្ចី ផ្នែកពោះពណ៌សព្រាលែត។ ទីជំរក: ព្រៃស្រោង ដំណុះព្រៃក្មេង។ ជីវសាស្ត្រ: រកស៊ីលំអងផ្កា។ ចរាចរ: វត្តមានពេញមួយឆ្នាំ មានគ្រប់ទីកន្លែង។ រដូវបន្តពូជ: ចាប់ពីខែ មិនា ដល់ សីហា។

**300 –ចាបកន្លង់ចំពុះធំ:** Thick-billed Flowerpecker *Dicaeum agile* ១០ ស.ម
ផ្នែកខ្នងពណ៌ត្នោត-ប្រផេះ ផ្នែកពោះមានស្នាមឆ្នូតៗស្រាលពណ៌ប្រផេះ ភ្នែកក្រហម ជ្រលក់សចុងកន្ទុយ។ ទីជំរក: ព្រៃស្រោង ពាក់កណ្ដាលស្រោង ព្រៃរបោះចំរុះ។ ចរាចរ: វត្តមានពេញមួយឆ្នាំ មានគ្រប់ទីកន្លែង។ រដូវបន្តពូជ: ចាប់ពីខែ មករា ដល់ មិថុនា។

**301 –ចាបកន្លង់បំពង់កត្នោតខ្ចី:** Ruby-cheeked Sunbird *Anthreptes singalensis* ១០.៥-១១ស.ម
ឈ្មោល: ផ្នែកខ្នងពណ៌បៃតងភ្លឺ ត្រចៀកក្រហម ចំពុះ ជើង និងស្លាបពណ៌ខ្មៅ បំពង់ក និងទ្រូងពណ៌ទឹកក្រូច ពោះពណ៌លឿង។ ញី: ខ្នងពណ៌បៃតងខ្ចី ស្លាបពណ៌ត្នោតខ្ចី។ ទីជំរក: ព្រៃស្រោង ព្រៃរបោះ ព្រៃជាំ ដំណុះព្រៃក្មេង។ ចរាចរ: វត្តមានពេញមួយឆ្នាំសំបូរគ្រប់ទីកន្លែង។ រដូវបន្តពូជ: ចាប់ពីខែ កុម្ភៈ ដល់ សីហា។

**302 –ចាបកន្លង់ក្រហម:** Crimson Sunbird *Aethopyga siparaja* ១១ ស.ម
ឈ្មោល: ក្បាល ទ្រូង និងខ្នងពណ៌ក្រហម បន្ទួលក្បាល និងកន្ទុយពណ៌បៃតងជាំ ពោះពណ៌ប្រផេះ ចុងខ្នងពណ៌លឿង។ ឈ្មោលពេលបន្តពូជ: សំបុរស្រដៀងញីតែបំពង់ក និងទ្រូងពណ៌ក្រហម។ ញី: ខ្នងពណ៌បៃតងខ្ចីស្រអាប់ ពោះលឿងខ្ចីស្រអាប់។ ទីជំរក: គ្រប់ប្រភេទព្រៃទាំងអស់។ ជីវសាស្ត្រ: ហើរសំកាំងស៊ីលំអងផ្កា។ ចរាចរ: វត្តមានពេញមួយឆ្នាំ មានគ្រប់ទីកន្លែង។ រដូវបន្តពូជ: ចាប់ពី ខែ កុម្ភៈ ដល់ សីហា។

**303 –ចាបកន្លង់ខៀវ:** Purple Sunbird *Nectarinia asiatica* ១០,៥-១១,៥ ស.ម
ឈ្មោល: ជាទូទៅឈ្មោលមានពណ៌ខៀវចាស់ភ្លឺចាំង ស្លាបខ្មៅ វិល្លទ្រូងក្រហម ប៉ុន្តែក្រោយពីបន្តពូជហើយក្នុងរយៈពេលខ្លីសត្វឈ្មោលវាដូរពណ៌ទៅជាបំពង់កមានពណ៌ខៀវឆ្នូតតាមបំពង់ក និងស្លាបពណ៌ខៀវចាស់។ ញី: ផ្នែកពោះពណ៌លឿង ផ្នែកខ្នងពណ៌ប្រផេះស្រអាប់។ ទីជំរក: ព្រៃរបោះ គុម្ពោតព្រៃតាមឆ្នេរ សួនច្បារ និងតាមដំណាំកសិកម្ម។ ចរាចរ: វត្តមានពេញមួយឆ្នាំ មានគ្រប់ទីកន្លែង។ រដូវបន្តពូជ: ចាប់ពីខែ កុម្ភៈ ដល់ មិថុនា។





299 ចាបកន្លង់ទ្រូងភ្លើង



300 ចាបកន្លង់ចំពុះធំ



301 ចាបកន្លង់បំពង់កក្តោតខ្ចី





302 ចាបកន្លង់ក្រហម





303 ចាបកន្លង់ខៀវ

## បញ្ជីឈ្មោះសត្វស្លាបប្រទេសកម្ពុជា:

បញ្ជីឈ្មោះសត្វស្លាបត្រូវបានរៀបចំឡើងដោយក្រុមអ្នកបក្សីវិទ្យាជាតិ និងអន្តរជាតិមួយក្រុមដែលលទ្ធផលទាំងអស់នេះបានមកពីការសិក្សាស្រាវជ្រាវក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ។ យើងសង្ឃឹមថាចាប់ពីពេលពេលនេះរហូតដល់ថ្ងៃអនាគតការសិក្សាស្រាវជ្រាវដើម្បីស្វែងរកនូវប្រភេទសត្វស្លាបថ្មីៗថែមទៀតកំពុងត្រូវបានបន្ត នោះគឺដើម្បីអភិរក្សប្រភេទសត្វស្លាបទាំងអស់សំរាប់ជាតិយើង។

លក្ខណៈសំខាន់ៗរបស់អង្គការ *CITES*:

១-ឧបសម្ព័ន្ធទី *I*: បណ្តាប្រភេទសត្វដែលត្រូវរងការគំរាមកំហែង អាចឈានទៅរកការផុតពូជ និងផ្នែកណាមួយរបស់វាធ្វើពាណិជ្ជកម្មទៅបានត្រូវស្ថិតនៅក្រោមការត្រួតពិនិត្យយ៉ាងតឹងរឹងបំផុត។

២-ឧបសម្ព័ន្ធទី *II*: បណ្តាប្រភេទសត្វដែលទទួលការគំរាមកំហែង នឹងឈានទៅរកការផុតពូជព្រមទាំងផ្នែកណាមួយរបស់វាធ្វើពាណិជ្ជកម្មទៅបានត្រូវស្ថិតនៅក្រោមការត្រួតពិនិត្យយ៉ាងតឹងរឹងបំផុតពីភ្នាក់ងារមានសមត្ថកិច្ច។

៣-ឧបសម្ព័ន្ធទី *III*: បណ្តាប្រភេទសត្វ និងផ្នែកណាមួយរបស់វា ដែលត្រូវបានកំណត់អោយធ្វើពាណិជ្ជកម្មត្រូវស្ថិតនៅក្រោមការត្រួតពិនិត្យ។

**ស្ថានភាពគំរាមកំហែង:**

*Ex* : ជាប្រភេទផុតពូជ
*Cr* : ជាប្រភេទជិតផុតពូជបំផុត
*En* : ជាប្រភេទជិតផុតពូជ
*nt* : ជាប្រភេទជិតរងគ្រោះ
*GT* : ជាប្រភេទកំពុងទទួលរងការគំរាមកំហែងលើពិភពលោក
*GNT* : ជាប្រភេទជិតទទួលរងការគំរាមកំហែងលើពិភពលោក
*LKL* : មានមួយចំនួនទទួលរងគ្រោះនៅប្រទេសឡាវ

**ស្ថានភាពក្នុងតំបន់:**

*LaR* : កំពុងទទួលរងគ្រោះនៅប្រទេសឡាវ
*LaP* : មានខ្លះទទួលរងគ្រោះនៅប្រទេសឡាវ
*ThEx* : ផុតពូជក្នុងប្រទេសថៃ
*ThT* : ទទួលការគមរាមកំហែងក្នុងប្រទេសថៃ
*ThNt* : ជិតទទួលការគំរាមកំហែងក្នុងប្រទេសថៃ

**លេខកូដសំគាល់ស្ថានភាពផ្លាស់ប្តូររបស់សត្វស្លាបៈ**

*e* : ផុតពូជនៅក្នុងប្រទេសកម្ពុជា

*p* : ប្រភេទផ្លាស់ប្តូរទីកន្លែងមិនសូវឆ្លងកាត់

*P* : ប្រភេទផ្លាស់ប្តូរទីកន្លែងឆ្លងកាត់ញឹកញាប់

*r* : មិនសូវសំបូរ

*R* : មានគ្រប់ទីកន្លែង

*v* : កម្រ

*w*: មានវត្តមាននៅរដូវប្រាំងដោយកម្រ

*W* : មានវត្តមាននៅរដូវប្រាំងគ្រប់ទីកន្លែង

? : ពតិមានមិនច្បាស់លាស់

**ឈ្មោះតំបន់:**

*sw*: *south-west*: ភាគនិរតី

*se*: *south-east*: ភាគអាគ្នេយ៍

*nw*: *north-west*: ភាគពាយព្យ

*ne*: *north-east*: ភាគឦសាន

**សទ្ទានុក្រមៈ**

*ប្រភេទស្ថានិកៈ* ជាប្រភេទដែលរស់នៅតែក្នុងតំបន់មួយជាក់លាក់។ គ្មាននៅក្នុងតំបន់ច្រើន។

*ប្រភេទវត្តមាននៅរដូវប្រាំងៈ* ជាប្រភេទអន្តោប្រវេសន៍។

*ប្រភេទខ្សាត់ព្រាត់ៈ* ជាប្រភេទអន្តោប្រវេសន៍ តែត្រូវវង្វេងផ្លូវ ហើយមិនអាចត្រឡប់ទៅប្រភពដើមវិញ។

*វត្តមានពេញមួយឆ្នាំៈ* ជាប្រភេទដែលរស់នៅ និង បន្តពូជតែក្នុងតំបន់មួយជាក់លាក់។

*មានគ្រប់ទីកន្លែងៈ* មានគ្រប់តំបន់ ទូទាំងប្រទេស។

**បណ្ណាល័យសាស្ត្រ**

*Goes, F. and Tan Setha (eds) Cambodia Bird News 1-10.*

*Lekagul B. and P. Round (1991) A guide to the birds of Thailand. Bangkok: Saha Karn Bhaet Co. Ltd.*

*Robson, C. (2002) A field guide to the birds of Thailand and South-east Asia. Bangkok: Asia Books.*

*Seng Kim Hout, Pech Bunnat, Poole, C. M., Tordoff, A. W., Davidson, P. and E. Delattre (2002) Directory of Important Bird Areas in Cambodia: key sites for conservation. Phnom Penh: Department of Forestry and Wildlife, Department of Nature Conservation and Protection, BirdLife International in Indochina and the Wildlife Conservation Society Cambodia Program.*

*Sun Hean, Seng Kim Hout, Keo Omaliss and Poole, C.M. (1998) The birds of Cambodia. Phnom Penh: SPEC.*

*Tan Setha and Goes, F. (2003) An introduction to bird identification techniques. A training manual for beginners. Phnom Penh: Wildlife Conservation Society Cambodia Program.*

| No. | Species no. (in Robson) | No. in Birds of Thailand | ឈ្មោះជាភាសាខ្មែរ | English Name | Scientific Name | Provisonal Status in Cambodia | Global Threat Status | Thai Threat Status | Lao Threat Status | CITES |
|---|---|---|---|---|---|---|---|---|---|---|
| 1 | 2 | 137 | ទទា | Chinese Francolin | *Francolinus pintadeanus* | R | | | | |
| 2 | 6 | 138 | ក្រួចទ្រូងស | Japanese Quail | *Coturnix japonica* | v | | | LKL | |
| 3 | 7 | 139 | ក្រួចទ្រូងខ្មៅ | Rain Quail | *Coturnix coromandelica* | r? | | | | |
| 4 | 8 | 140 | ក្រួចទ្រូងខៀវ | Blue-breasted Quail | *Coturnix chinensis* | w | | NT | LKL | |
| 5 | 12 | 129 | ទទាខ្នងបង្កង់ | Bar-backed Partridge | *Arborophila brunneopectus* | r (ne) | | | | |
| 6 | 14 | | ទទាទ្រូងលឿង | Orange-necked Partridge | *Arborophila davidi* | r (e) | En | | | |
| 7 | 15 | 130 | ក្រួចសំពៅឬមាន់ក្រិច | Chestnut-headed Partridge | *Arborophila cambodiana* | r (sw) | Vu | En | | III |
| 8 | 17 | 131 | ទទាជើងបៃតង ឬមាន់ក្រួច | Scaly-breasted Partridge | *Arborophila chloropus* | r | | | | |
| 9 | 28 | 122 | មាន់ព្រៃ | Red Junglefowl | *Gallus gallus* | r | | | | |
| 10 | 30 | 119 | មាន់ទោពណ៌ប្រាក់ | Silver Pheasant | *Lophura nycthemera* | r | | | | |
| 11 | 36 | 121 | ស្តេចកូលិត | Siamese Fireback | *Lophura diardi* | r | NT | | PARL | |
| 12 | 41 | | មាន់ទោប្រាក់ពណ៌ប្រផេះ-បៃតង | Germain's Peacock Pheasant | *Polyplectron germaini* | r | Vu | | | II |
| 13 | 42 | 124 | មាន់ទោប្រាក់ពណ៌ប្រផេះ | Grey Peacock Pheasant | *Polyplectron bicalcaratum* | r (ne) | | | | II |
| 14 | 46 | 127 | ក្ងោក | Green Peafowl | *Pavo muticus* | r | Vu | En | ARL | II |
| 15 | 48 | 67 | ប្រវឹក | Lesser Whistling-duck | *Dendrocygna javanica* | R | | | | |
| 16 | 57 | 65 | ទាព្រៃស្លាប ស | White-winged Duck | *Cairina scutulata* | r | En | Cr | ARL | I |
| 17 | 58 | 64 | ទាកាផាព្រៃ | Comb Duck | *Sarkidiornis melanotos* | r | | En | ARL | II |
| 18 | 59 | 63 | ប្រវើក | Cotton Pygmy-goose | *Nettapus coromandelianus* | R | | Vu | ARL | |
| 19 | 63 | 54 | ទាព្រៃក្បាលត្នោត | Eurasian Wigeon | *Anas penelope* | w | | | | III |
| 20 | 65 | 52 | ទាកាបព្រៃ | Spot-billed Duck | *Anas poecilorhyncha* | r | | | | |
| 21 | 66 | 56 | ទាព្រៃចំពុះធំ | Northern Shoveler | *Anas clypeata* | w | | | | III |
| 22 | 68 | 50 | ទាព្រៃកន្ទុយវែង | Northern Pintail | *Anas acuta* | w | | | | III |
| 23 | 69 | 55 | ទាព្រៃក្បាលឆ្នូតស | Garganey | *Anas querquedula* | w | | | | III |

| | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| 24 | 71 | 51 | ទាព្រៃតូច | Common Teal | *Anas crecca* | w | | | | III |
| 25 | 83 | 141 | ក្រួចតូច | Small Buttonquail | *Turnix sylvatica* | r | | | LKL | |
| 26 | 84 | 142 | ក្រួចអុីតជើងលឿង | Yellow-legged Buttonquail | *Turnix tanki* | r | | | | |
| 27 | 85 | 143 | ក្រួចអុីត | Barred Buttonquail | *Turnix suscitator* | R | | | | |
| 28 | 89 | 393 | ស្រយាប | Speckled Piculet | *Picumnus innominatus* | r | | | | |
| 29 | 91 | 394 | ស្រយាបចិញ្ចើមស | White-browed Piculet | *Sasia ochracea* | r(sw) | | | | |
| 30 | 93 | 427 | ត្រសេះតូចខ្មៅស | Grey-capped Woodpecker | *Dendrocopos canicapillus* | r | | | | |
| 31 | 94 | 425 | ត្រសេះមធ្យមខ្មៅ-ស | Fulvous-breasted Woodpecker | *Dendrocopos macei* | r | | | LKL | |
| 32 | 96 | 426 | ត្រសេះតូចក្បាលលឿង | Yellow-crowned Woodpecker | *Dendrocopus mahrattensis* | r (ne) | | Cr | ARL | |
| 33 | 97 | 423 | ត្រសេះពោះត្នោត | Rufous-bellied Woodpecker | *Dendrocopos hyperythrus* | r (ne) | | Vu | | |
| 34 | 101 | 412 | ត្រសេះត្នោតចំពុះខ្មៅ | Rufous Woodpecker | *Celeus brachyurus* | r | | | | |
| 35 | 102 | 416 | ត្រសេះធំពោះ ស | White-bellied Woodpecker | *Dryocopus javensis* | r | | Vu | PARL | |
| 36 | 104 | 408 | ត្រសេះតូចកំប៉ោយលឿង | Lesser Yellownape | *Picus chlorolophus* | r | | | | |
| 37 | 106 | 407 | ត្រសេះធំកំប៉ោយលឿង | Greater Yellownape | *Picus flavinucha* | r | | | | |
| 38 | 109 | 402 | ត្រសេះតូចក្បាលក្រហម | Laced Woodpecker | *Picus vittatus* | r | | | | |
| 39 | 110 | 404 | ត្រសេះបៃតងទ្រូងពព្លាក់ | Streak-throated Woodpecker | *Picus xanthopygaeus* | r | | Vu | PARL | |
| 40 | 111 | | ត្រសេះធំកកក្រហម | Red-collared Woodpecker | *Picus rabieri* | r (ne) | NT | | | |
| 41 | 112 | 406 | ត្រសេះបៃតងក្បាលខ្មៅ | Black-headed Woodpecker | *Picus erythropygius* | r | | | | |
| 42 | 113 | 405 | ត្រសេះបៃតងក្បាលប្រផេះ | Grey-headed Woodpecker | *Picus canus* | r | | | | |
| 43 | 116 | 397 | ត្រសេះតូចខ្នងភ្លើង | Common Flameback | *Dinopium javanense* | r | | | | |
| 44 | 118 | 398 | ត្រសេះធំខ្នងភ្លើង | Greater Flameback | *Chrysocolaptes lucidus* | r | | | | |
| 45 | 119 | 400 | ត្រសេះក្បាលព្រលែត | Pale-headed Woodpecker | *Gecinulus grantia* | r (ne) | | Cr | | |
| 46 | 122 | 414 | ត្រសេះចំពុះលឿងព្រលែត | Bay Woodpecker | *Blythipicus pyrrhotis* | r | | | | |
| 47 | 125 | 419 | ត្រសេះពពាលក-ស | Black-and-buff Woodpecker | *Meiglyptes jugularis* | r | | | | |
| 48 | 128 | 420 | ត្រសេះពពាលបំពង់ក-ស | Heart-spotted Woodpecker | *Hemicircus canente* | r | | | | |

| | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| 49 | 129 | 415 | ត្រសេះដី | Great Slaty Woodpecker | *Mulleripicus pulverulentus* | r | | NT | | |
| 50 | 132 | | ប៉ោលតោកគូថក្រហម | Red-vented Barbet | *Megalaima lagrandieri* | r (ne) | | | | |
| 51 | 133 | 379 | ប៉ោលតោកក្បាលព្រលែត | Lineated Barbet | *Megalaima lineata* | R | | | | |
| 52 | 134 | 380 | ប៉ោលតោកត្រចៀកបៃតង | Green-eared Barbet | *Megalaima faiostricta* | R | | | | |
| 53 | 139 | | ប៉ោលតោកបំពង់កលឿង | Black-browed Barbet | *Megalaima oorti* | r (ne) | | | | |
| 54 | 141 | 386 | ប៉ោលតោកតុកកូម្យុក | Moustached Barbet | *Megalaima incognita* | r | | | | |
| 55 | 143 | 388 | ប៉ោលតោកថ្ងាសខ្មៅ | Blue-eared Barbet | *Megalaima australis* | R | | | | |
| 56 | 144 | 389 | ប៉ោលតោកអំបុក | Coppersmith Barbet | *Megalaima haemacephala* | R | | | | |
| 57 | 146 | 374 | កេងកងតូច | Oriental Pied Hornbill | *Anthracoceros albirostris* | r | | NT | | II |
| 58 | 149 | 376 | កេងកងធំ | Great Hornbill | *Buceros bicornis* | r | NT | NT | ARL | I |
| 59 | 151 | 367 | កេងកងត្នោត | Brown Hornbill | *Anorrhinus tickelli* | r | NT | | PARL | II |
| 60 | 156 | 371 | ញ៉ាំង | Wreathed Hornbill | *Aceros undulatus* | r | | NT | ARL | II |
| 61 | 158 | 365 | បាគូ ឬ( កាពុតញើង ) | Common Hoopoe | *Upupa epops* | r | | | | |
| 62 | 163 | 340 | ចាបចៀបពោះលឿង | Orange-breasted Trogon | *Harpactes oreskios* | r | | | | |
| 63 | 164 | 341 | ចាបចៀបពោះក្រហម | Red-headed Trogon | *Harpactes erythrocephalus* | r | | | | |
| 64 | 166 | 363 | ទាវខៀវ | Indian Roller | *Coracias benghalensis* | R | | | | |
| 65 | 167 | 364 | មាវព្រៃ | Dollarbird | *Eurystomus orientalis* | r | | | | |
| 66 | 169 | 345 | ចចាតក្រឹម | Common Kingfisher | *Alcedo atthis* | R | | | | |
| 67 | 170 | 346 | ចចាតត្រចៀកខៀវ | Blue-eared Kingfisher | *Alcedo meninting* | r | | | | |
| 68 | 172 | 348 | ចចាតតូចចុងខ្នងក្រហម | Black-backed Kingfisher | *Ceyx erithacus* | ? | | | | |
| 69 | 174 | 349 | កដបព្រៃ | Banded Kingfisher | *Lacedo pulchella* | r | | | | |
| 70 | 176 | 351 | ងាវកក | Stork-billed Kingfisher | *Halcyon capensis* | r | | | | |
| 71 | 177 | 352 | កដបក្រហម | Ruddy Kingfisher | *Halcyon coromanda* | v | | Vu | LKL | |
| 72 | 178 | 353 | កដបទ្រូង ស | White-throated Kingfisher | *Halcyon smyrnensis* | R | | | | |
| 73 | 179 | 354 | កដបក្បាលខ្មៅ | Black-capped Kingfisher | *Halcyon pileata* | w | | | | |

| | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| 74 | 180 | 355 | កដបខៀវ ស | Collared Kingfisher | *Todiramphus chloris* | r | | | LKL | |
| 75 | 184 | 343 | កដបខ្មៅស | Pied Kingfisher | *Ceryle rudis* | r | | | ARL | |
| 76 | 186 | 362 | ត្រដេវព្រៃ | Blue-bearded Bee-eater | *Nyctyornis athertoni* | r | | | | |
| 77 | 187 | 359 | ត្រដេវតូច | Green Bee-eater | *Merops orientalis* | r | | | | |
| 78 | 188 | 360 | ត្រដេវក្បាលត្នោតចាស់ | Blue-throated Bee-eater | *Merops viridis* | p,r,w | | | | |
| 79 | 189 | 358 | ត្រដេវក្បាលបៃតង | Blue-tailed Bee-eater | *Merops philippinus* | P,R,W | | | PARL | |
| 80 | 190 | 357 | ត្រដេវក្បាលត្នោតខ្ចី | Chestnut-headed Bee-eater | *Merops leschenaulti* | r | | | | |
| 81 | 192 | 281 | តាវៅកំប៉ោយ | Chestnut-winged Cuckoo | *Clamator coromandus* | ? | | | | |
| 82 | 193 | 282 | តាវៅធំ | Large Hawk Cuckoo | *Hierococcyx sparverioides* | r | | | | |
| 83 | 196 | 285 | តាវៅខ្នងប្រផេះ | Hodgson's Hawk Cuckoo | *Hierococcyx fugax* | ?p | | | | |
| 84 | 197 | 286 | តាវៅក្បាលប្រផេះស្រាល | Indian Cuckoo | *Cuculus micropterus* | r,w? | | | | |
| 85 | 199 | 288 | តាវៅពោះអង្កន់លឿង | Oriental Cuckoo | *Cuculus saturatus* | p? | | | | |
| 86 | 201 | 290 | តាវៅខ្នងអង្កន់ត្នោត | Banded Bay Cuckoo | *Cacomantis sonneratii* | v | | | | |
| 87 | 203 | 291 | តាវៅភូមិ | Plaintive Cuckoo | *Cacomantis merulinus* | R | | | | |
